អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវកិច្ចការសភា

# កម្រងព័ត៌មានសភាអន្តរជាតិ និងព័ត៌មានអន្តរជាតិសំខាន់ៗប្រចាំសប្តាហ៍
(ចាប់ពីថ្ងៃទី០៧-១៣ ខែកុម្ភៈ ឆ្នាំ២០២២)

## I.ទ្វីបអាស៊ី-អូសេអានី

| ប្រទេស | ខ្លឹមសារអត្ថបទព័ត៌មាន |
|---|---|
| អាស៊ែបៃហ្សង់ | **លោកស្រី Sahiba Gafarova ប្រធានសភាអាស៊ែបៃហ្សង់ទទួលជួប រដ្ឋមន្ត្រីក្រសួងការបរទេសលីទុយអានី**<br>នាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈនៃសភាអាស៊ែបៃហ្សង់ បានថ្លែងប្រាប់សារព័ត៌មាន News.Az ថា លោកស្រី Sahiba Gafarova ប្រធានសភានៃសាធារណរដ្ឋអាស៊ែបៃហ្សង់ បានទទួលជួបជាមួយ លោក Gabrielius Landsbergis រដ្ឋមន្ត្រីក្រសួងការបរទេសនៃសាធារណរដ្ឋលីទុយអានី ដែលជាផ្នែកមួយនៃដំណើរទស្សនកិច្ចផ្លូវការ របស់លោកស្រីទៅកាន់ប្រទេសមួយនេះ។ លោកស្រីប្រធានសភាអាស៊ែបៃហ្សង់រូបនេះ បានគូសបញ្ជាក់ថា ជម្រើសវិនិយោគដ៏ល្អបំផុតនៅក្នុងតំបន់សេដ្ឋកិច្ចសេរី Alat តំបន់សេដ្ឋកិច្ចសេរី Araz និងសួនឧស្សាហកម្ម Aghadam កំពុងត្រូវបានរៀបចំធ្វើឡើងនៅក្នុងដែនដី ដែលយកបានមកវិញ ក៏ដូចជាសួនកសិកម្ម បច្ចេកវិទ្យាទូរគមន៍និងព័ត៌មានវិទ្យា និងវិស័យថាមពលកកើតឡើងវិញ។<br>អាស៊ែបៃហ្សង់ អញ្ជើញក្រុមហ៊ុនលីទុយអានីមកវិនិយោគ នៅក្នុងគម្រោងដែលកំពុងតែធ្វើឡើងនៅទីនោះផងដែរ លោកស្រី Sahiba Gafarova បានថ្លែងបញ្ជាក់បែបនេះ។ លោកស្រីបានលើកឡើងពីយុទ្ធសាស្រ្តដ៏សំខាន់នៃច្រកផ្លូវ Zangazur ការបើកច្រកផ្លូវនេះនឹងក្លាយជាគំនិតថ្មីមួយ មិនមែនគ្រាន់តែសម្រាប់តំបន់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏សម្រាប់បណ្តារដ្ឋជាសមាជិកសហភាពអឺរ៉ុបផងដែរ៕<br>https://www.news.az/news/chair-of-azerbaijani-parliament-sahiba-gafarova-meets-lithuanian-foreign-minister-photo<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| ចិន | **ប្រធានសភាប្រជាជនចិន ជួបពិភាក្សាការងារជាមួយប្រធានសភាសាធារណរដ្ឋកូរ៉េ**<br>កាលពីថ្ងៃសៅរ៍ ទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ លោក Li Zhanshu ប្រធានសភាប្រជាជនចិន (NPC) បានជួបពិភាក្សាការងារជាមួយ លោក Park Byeong-seug ប្រធានសភានៃសាធារណរដ្ឋកូរ៉េ («ROK» |

| | |
|---|---|
| **ចិន** | ឬកូរ៉េខាងត្បូង) ដែលបានដឹកនាំគណៈប្រតិភូចូលរួមក្នុងពិធី បើកកីឡាអូឡាំពិករដូវរងាទីក្រុងប៉េកាំង ឆ្នាំ២០២២។ លោក Li Zhanshu ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាប្រជាជនចិន បានថ្លែងថា ឆ្នាំ២០២២នេះ គឺជាខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតចំណងការទូតរវាងចិន និងសាធារណរដ្ឋកូរ៉េ ហើយចិនមានឆន្ទៈ ក្នុងការធ្វើការងារជាមួយសាធារណរដ្ឋកូរ៉េ ដើម្បីបន្តភាពជាដៃគូយុទ្ធសាស្ត្រនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែស៊ីជម្រៅថែមទៀត។<br>លោក Li Zhanshu បានអំពាវនាវឱ្យភាគីទាំងពីរ ពង្រឹងជំនឿទុកចិត្តនយោបាយទៅវិញទៅមក លើកកម្ពស់កិច្ចសហប្រតិបត្តិការផលប្រយោជន៍ទៅវិញទៅមក ពង្រឹងប្រជាជននិងប្រជាជន និងការផ្លាស់ប្តូរវប្បធម៌ ព្រមទាំងដោះស្រាយបញ្ហារសើបនានាឱ្យបានសមរម្យ។ សភាប្រជាជនចិន បានត្រៀមរួចជាស្រេចក្នុងការធ្វើការងារជាមួយសភាសាធារណរដ្ឋកូរ៉េ ដើម្បីសម្រេចបាននូវមិត្តភាពជាប្រពៃណីនៃប្រទេសទាំងពីរ ពង្រឹងការផ្លាស់ប្តូរ និងកិច្ចសហប្រតិបត្តិការ ព្រមទាំងបង្កើតនូវការរួមចំណែកមួយថ្មី ដើម្បីអភិវឌ្ឍន៍ចំណងទាក់ទងចិន-សាធារណរដ្ឋកូរ៉េ។<br>លោក Li Zhanshu បានថ្លែងអំណរគុណដល់រដ្ឋាភិបាលសាធារណរដ្ឋកូរ៉េ និងប្រជាជនមកពីគ្រប់មជ្ឈដ្ឋានដែលបានគាំទ្រចិន ដែលទទួលធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិករដូវរងា និងប្តេជ្ញាបន្តគាំទ្រសាធារណរដ្ឋកូរ៉េ ដើម្បីទទួលធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិករដូវរងា យុវជនឆ្នាំ២០២៤ នៅក្នុងខេត្ត Gangwon។ ចិនមានឆន្ទៈក្នុងការថែរក្សា នូវទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយសាធារណរដ្ឋកូរ៉េ ថែរក្សាស្ថិរភាពរួម និងលើកកម្ពស់កិច្ចពិភាក្សា បង្កើតនូវកិច្ចខិតខំប្រឹងប្រែងជាវិជ្ជមាន សម្រាប់ដំណោះស្រាយនយោបាយនៃបញ្ហាឧបទ្វីបកូរ៉េ និងសន្តិភាពយូរអង្វែង ព្រមទាំងស្ថិរភាពនៅក្នុងឧបទ្វីប។<br>សម្រាប់ភាគីសាធារណរដ្ឋកូរ៉េ លោក Park Byeong-seug បានសម្តែងនូវក្តីសង្ឃឹមក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការជាមួយចិន ក្នុងវិស័យនានាដូចជា វិស័យសេដ្ឋកិច្ច វប្បធម៌ កីឡា និងការគ្រប់គ្រងជំងឺរាតត្បាតជាសកលកូវីដ-១៩ជាដើម និងរួមគ្នារៀបចំធ្វើផែនការអភិវឌ្ឍន៍ចំណងទាក់ទងទ្វេភាគី សម្រាប់៣០ឆ្នាំបន្ទាប់ទៀត៕<br>http://www.xinhuanet.com/english/20220205/3908df6c33834912959c75f82b3fcec8/c.html<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **អ៊ីរ៉ង់** | **សមាជិកសភាអ៊ីរ៉ង់ ៥០រូប បានឆ្លងជំងឺកូវីដ-១៩ នៅចំពេលដែលវ៉ារ្យង់អូមីក្រុង កំពុងរីករាលដាលទូទាំងប្រទេស**<br>មានសមាជិកសភាប្រមាណ ៥០រូប នៅក្នុងសភានៃសាធារណរដ្ឋឥស្លាមអ៊ីរ៉ង់ ដែលមាន ២៩០អាសនៈ បានឆ្លងជំងឺកូវីដ-១៩ ក្នុងគ្រាដែលវីរុសក្លាយខ្លួនប្រភេទថ្មីវ៉ារ្យង់អូមីក្រុង កំពុងរីករាលដាលឥតស្រាកស្រាន្តនៅទូទាំងប្រទេស។ នេះបើយោងតាមសមាជិកសភាជាន់ខ្ពស់អ៊ីរ៉ង់ ១រូប បានថ្លែងឱ្យដឹងកាលពីថ្ងៃសៅរ៍ ទី០៥ ខែកុម្ភៈ ឆ្នាំ២០២២។ លោក Alireza Salimi បានថ្លែងប្រាប់ទីភ្នាក់ងារសារព័ត៌មាន YJC ដែលស្និទ្ធជាមួយនឹងទូរទស្សន៍គ្រប់គ្រងដោយរដ្ឋអ៊ីរ៉ង់ បានឱ្យដឹងថា សម័យប្រជុំសភាក្នុងសប្តាហ៍នេះ នឹងត្រូវបានធ្វើឡើងដោយអនុលោមតាមវិធានសុខាភិបាលរបស់រដ្ឋាភិបាលអ៊ីរ៉ង់។<br>គួររំលឹកផងដែរថា សភាអ៊ីរ៉ង់ធ្លាប់បានផ្អាកកិច្ចប្រជុំរយៈពេល ២សប្តាហ៍កាលពីខែមេសា ឆ្នាំ២០២១ |

| | |
|---|---|
| **អ៊ីរ៉ង់** | កន្លងមក ដោយសារតែការផ្ទុះឡើងនៃការឆ្លងជំងឺកូវីដ-១៩ ក្នុងចំណោមសមាជិកសភា។ ក្នុងពេលឆ្លងនោះ មានសមាជិកសភាជាច្រើនរូប បានស្លាប់បាត់បង់ជីវិត ដោយសារតែជំងឺរាតត្បាតជាសកលកូវីដ-១៩មួយនេះ។ ប្រទេសអ៊ីរ៉ង់ត្រូវបានគេមើលឃើញថា មានករណីឆ្លងជំងឺកូវីដ-១៩យ៉ាងគំហុក ក្រោយពីមិនមានការឆ្លងច្រើនមួយរយៈខ្លី បន្ទាប់ពីបានចាក់ថ្នាំបង្ការជំងឺទ្រង់ទ្រាយធំ។ ក្នុងអំឡុងពេលប៉ុន្មានថ្ងៃថ្មីៗនេះ អ៊ីរ៉ង់បានរាយការណ៍ពីករណីឆ្លងថ្មីជាមធ្យមក្នុង១ថ្ងៃ គឺមានចំនួនជាង ៣០,០០០នាក់។ ប៉ុន្តែយ៉ាងណាក៏ដោយ ចំនួនករណីឆ្លងប្រចាំថ្ងៃក្នុងរយៈពេល ២៤ម៉ោងចុងក្រោយនេះ គឺមានចំនួនតែ ២៣,១៣០ករណីប៉ុណ្ណោះ នេះបើយោងតាមក្រសួងសុខាភិបាលអ៊ីរ៉ង់ បានថ្លែងឱ្យដឹងកាលពីថ្ងៃសៅរ៍សប្តាហ៍មុន។<br>ប្រទេសអ៊ីរ៉ង់ ជាមួយនឹងចំនួនប្រជាជនប្រមាណជា ៨៥លាននាក់ បានរាយការណ៍ពីករណីឆ្លងជំងឺកូវីដ-១៩ ជាង ៦.៥លាននាក់ និងជាង ១៣២,៥០០នាក់ បានស្លាប់បាត់បង់ជីវិត ពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ចាប់តាំងពីមេរោគរាតត្បាតជាសកលមួយនេះបានផ្ទុះឡើង។ មកទល់ពេលនេះមានប្រជាជនអ៊ីរ៉ង់ជាង ៥០លាននាក់ បានទទួលការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ បាន២ដូស និងមានប្រជាជនអ៊ីរ៉ង់ជាង ១៩លាននាក់ បានទទួលការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដូសទី៣ រួចរាល់៕<br>https://www.theguardian.com/world/2022/feb/05/fifty-iran-mps-contract-covid-as-omicron-spreads-across-country<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **វៀតណាម** | **ថ្នាក់ដឹកនាំកំពូលនៃរដ្ឋសភាវៀតណាម បើកកិច្ចប្រជុំពិភាក្សាការងារ ជាមួយអគ្គនាយកដ្ឋានស៊ើបការណ៍សម្ងាត់យោធាវៀតណាម**<br>ទីក្រុងហាណូយ៖ កាលពីថ្ងៃចន្ទ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ លោក Vuong Dinh Hue ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានបើកកិច្ចប្រជុំពិភាក្សាការងារជាមួយ អគ្គនាយកដ្ឋានស៊ើបការណ៍សម្ងាត់យោធានៃក្រសួងការពារជាតិ (អគ្គនាយកដ្ឋានទីII) ក្នុងទីក្រុងហាណូយ។ ថ្នាក់ដឹកនាំកំពូលរដ្ឋសភាវៀតណាមរូបនេះ បានសាទរគណៈកម្មាធិការបក្សរបស់អគ្គនាយកដ្ឋានស៊ើបការណ៍សម្ងាត់យោធានៃក្រសួងការពារជាតិវៀតណាម ដែលបានដឹកនាំអង្គភាពក្រោមឱវាទរបស់ខ្លួន បំពេញភារកិច្ចនយោបាយសំខាន់ៗ រួមទាំងតួនាទីប្រឹក្សាយោបល់ ជូនក្រុមប្រឹក្សាអចិន្ត្រៃយ៍នៃគណៈកម្មាធិការកងទ័ពមជ្ឈិម ក្នុងវិស័យស៊ើបការណ៍សម្ងាត់យោធា ឆ្លើយតបទៅនឹងតម្រូវការនៅក្នុងស្ថានភាពថ្មី។<br>លោក Hue បានថ្លែងទៀតថា អគ្គនាយកដ្ឋាននេះ ក៏បានអនុវត្តន៍ការងារទំនើបកម្មយោធាយ៉ាងធំផងដែរ ដែលបានចូលរួមចំណែកក្នុងការកសាងកម្លាំង និងអង្គការបក្សដោយតម្លាភាព។ ដើម្បីបំពេញភារកិច្ចនៅឆ្នាំ២០២២ និងនៅឆ្នាំជាបន្តបន្ទាប់ លោក Hue បានស្នើឱ្យអគ្គនាយកដ្ឋាននេះ ក្តាប់ឱ្យបានណែន និងអនុវត្តន៍សេចក្តីសម្រេច និងសេចក្តីណែនាំនានា ដែលរួមមានសេចក្តីសម្រេចរបស់ការិយាល័យនយោបាយមជ្ឈិមបក្សលេខ ៤៨ និងសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៃគណៈកម្មាធិការកងទ័ពមជ្ឈិមលេខ ១៦០ ស្តីពីការងារស៊ើបការណ៍សម្ងាត់យោធា ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្ថានភាពថ្មីនេះ។<br>លោក Hue បានថ្លែងបន្តទៀតថា អគ្គនាយកដ្ឋាននេះ គួរតែបន្តកសាងកម្លាំងដោយភាពស្មោះត្រង់ |

**វៀតណាម**

ដាច់ខាតចំពោះបក្ស រដ្ឋ និងប្រជាជន ស្ថិរភាពខាងមនោគមវិជ្ជា និងនយោបាយ ត្រៀមខ្លួនជានិច្ចដើម្បីអនុវត្តន៍ និងបំពេញគ្រប់ភារកិច្ចដែលបក្ស រដ្ឋ កងទ័ព និងប្រជាជនប្រគល់ជូន៕

https://en.vietnamplus.vn/top-legislator-holds-working-session-with-general-department-ii/221708.vnp

*ប្រែសម្រួលដោយ កែវ ធារី-ផេង ធារី*

## ប្រធានរដ្ឋសភាវៀតណាម ផ្ញើសារអបអរសាទរដល់សមភាគីអ៊ីរ៉ាក់

លោក Vuong Dinh Hue ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានផ្ញើលិខិតចូលរួមអបអរសាទរចំពោះ លោក Mohammed al-Halbousi ក្នុងការបោះឆ្នោតជ្រើសតាំងជាប្រធានសភានៃសាធារណរដ្ឋអ៊ីរ៉ាក់។ នៅក្នុងសារលិខិតនោះ លោក Hue បានជូនពរដល់ លោក Al-Halbosi ឱ្យមានសុខភាពល្អ និងជោគជ័យក្នុងតួនាទីដ៏ថ្លៃថ្នូ ព្រមទាំងការទទួលខុសត្រូវរបស់លោក។ លោក Hue ក៏បានសង្កត់ធ្ងន់ថា រដ្ឋសភាវៀតណាមជានិច្ចកាលតែងតែយកចិត្តទុកដាក់ ក្នុងការជំរុញនូវទំនាក់ទំនងមិត្តភាពជាប្រពៃណីល្អរវាងវៀតណាម និងអ៊ីរ៉ាក់ ព្រមទាំងរវាងស្ថាប័ននីតិបញ្ញត្តិទាំងពីរ ដើម្បីផលប្រយោជន៍ជាក់ស្តែងរបស់ប្រជាជននៃប្រទេសទាំងពីរ និងដើម្បីសន្តិភាព ស្ថិរភាព ព្រមទាំងការអភិវឌ្ឍក្នុងតំបន់ និងពិភពលោកផងដែរ៕

https://en.vietnamplus.vn/na-chairman-sends-congratulations-to-iraqi-counterpart/221769.vnp

*ប្រែសម្រួលដោយ ផាត់ ត្រដែត*

## ប្រធានរដ្ឋសភាវៀតណាម សាទរចំពោះដំណើរការនៃវិស័យឧស្សាហកម្ម-ពាណិជ្ជកម្ម

កាលពីថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ លោក Vuong Dinh Hue ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានទទួលស្គាល់នូវសមិទ្ធផលនៃវិស័យឧស្សាហកម្ម និងពាណិជ្ជកម្មក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ ក្នុងជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម (MoIT)។

លោក Hue បានលើកឡើងពីកំណើន ៦.៣៧% នៃការកែច្នៃ-ផលិត និងការកើនឡើង ២៣% នៃប្រាក់ចំណូលពីការនាំចូល-នាំចេញពីមួយឆ្នាំទៅមួយឆ្នាំដល់ ៦៧០ពាន់លានដុល្លារក្នុងឆ្នាំ២០២១ ដែលធ្វើឱ្យវៀតណាមក្លាយជាប្រទេសមួយ ក្នុងចំណោមប្រទេសសេដ្ឋកិច្ចកំពូលទាំង២០ លើពិភពលោកដែលមានទំហំពាណិជ្ជកម្មធំបំផុត។ លោកក៏បានទទួលស្គាល់ការរួមចំណែករបស់វិស័យនេះ ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជំនាន់ថ្មីជាច្រើន រួមទាំងកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ និងជឿនលឿនសម្រាប់ភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (CPTPP) កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវៀតណាម-សហភាពអឺរ៉ុប (EVFTA) និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP)។ ដោយចង្អុលបង្ហាញពីបញ្ហាប្រឈមដែលបានព្យាករណ៍នៅឆ្នាំ២០២២ លោក Hue បានស្នើឱ្យវិស័យនេះអនុវត្តន៍វិធានការយ៉ាងខ្លាំង ដើម្បីបត់បែន និងសម្របខ្លួនដោយសុវត្ថិភាពទៅនឹងជំងឺកូវីដ-១៩ និងជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ច រួមទាំងការចេញផែនការសកម្មភាពដំបូង ដើម្បីអនុវត្តន៍សេចក្តីសម្រេចលេខ 43/2022/QH15 របស់រដ្ឋសភាវៀតណាម

| | |
|---|---|
| វៀតណាម | ស្តីពីសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ ដើម្បីគាំទ្រដល់កម្មវិធីស្តារសេដ្ឋកិច្ចសង្គម ក៏ដូចជាសេចក្តីសម្រេចចិត្តលេខ 11/NQ-CP របស់រដ្ឋាភិបាលស្តីពីការស្តារ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។ ដោយកត់សម្គាល់ថា រដ្ឋសភាវៀតណាមនឹងរៀបចំកម្មវិធីត្រួតពិនិត្យលើការអនុវត្តច្បាប់ ស្តីពីផែនការនៅឆ្នាំ២០២២ លោកបានស្នើឱ្យ MoIT ពន្លឿនការកែសម្រួលយុទ្ធសាស្ត្រ និងផែនការក្រោមការគ្រប់គ្រងរបស់ខ្លួន។ លោក Hue ក៏បានក្រើនរំលឹកដល់ MoIT ឱ្យយកចិត្តទុកដាក់កាន់តែខ្លាំងលើការកសាងបក្ស និងការសិក្សា ព្រមទាំងធ្វើតាមមនោគមវិជ្ជា របៀបរស់នៅ និងគំរូសីលធម៌របស់លោកប្រធានហូជីមិញ។<br>នាថ្ងៃដដែលនោះ លោក Hue ក៏បានអញ្ជើញធ្វើទស្សនកិច្ចនៅក្រុមហ៊ុនវាយនភណ្ឌ និងកាត់ដេរជាតិវៀតណាម (Vinatex) ក្នុងអំឡុងពេលនោះលោកបានស្នើឱ្យក្រុមនេះ យកចិត្តទុកដាក់បន្ថែមទៀតក្នុងការកសាងម៉ាកយីហោវៀតណាម និងការបង្កើនតម្លៃបន្ថែមនៃផលិតផលកាត់ដេរ និងវាយនភ័ណ្ឌរបស់ប្រទេស។ ថ្លែងនៅក្នុងជំនួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំ Vinatex លោក Hue បានមានប្រសាសន៍ថា ឧស្សាហកម្មកាត់ដេរបានជម្នះការលំបាក និងបញ្ហាប្រឈមនានា ដែលបណ្តាលមកពីជំងឺរាតត្បាតកូវីដ-១៩ ហើយត្រូវបានវាយតម្លៃថា ជាភូមិសាស្ត្រទិញល្អបំផុតក្នុងចំណោមប្រទេស និងតំបន់ផលិតសម្លៀកបំពាក់ឈានមុខគេចំនួន២៧ ក្នុងឆ្នាំ២០២១។ លោក Hue បានបញ្ជាក់ថា ដោយទទួលបានសមិទ្ធិផលទាំងនេះ Vinatex បានលើកកម្ពស់តួនាទីស្នូល និងនាំមុខរបស់ខ្លួន។ លោក Hue ក៏បានណែនាំក្រុមឱ្យរៀនពីមេរៀននៃរយៈពេលពីរឆ្នាំចុងក្រោយនៃការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ចាប់យកឱកាស និងនិន្នាការនៃការផ្លាស់ប្តូរខ្សែសង្វាក់ផ្គត់ផ្គង់ ព្រមទាំងទំនាក់ទំនងក្នុងខ្សែសង្វាក់ផ្គត់ផ្គង់វាយនភណ្ឌ និងកាត់ដេរ ហើយផ្តោតលើទីផ្សារក្នុងស្រុកនៃអ្នកប្រើប្រាស់ជិត ១០០លាននាក់៕<br>https://en.vietnamplus.vn/na-leader-hails-industrytrade-sectors-performance/221762.vnp<br>*ប្រែសម្រួលដោយ ផាត់ ត្រដែត* |
| អូស្ត្រាលី | **ប្រធានរដ្ឋសភាអូស្ត្រាលីសុំទោស ចំពោះការរំលោភបំពានផ្លូវភេទលើមន្ត្រីបម្រើការក្នុងរដ្ឋសភាអូស្ត្រាលី**<br>លោក Andrew Wallace ប្រធានរដ្ឋសភានៃសហគមន៍រដ្ឋឯករាជ្យអូស្ត្រាលី (Commonwealth of Australia) បានសុំទោសជាផ្លូវការចំពោះមន្ត្រីមួយចំនួន ដែលត្រូវបានគេធ្វើទុក្ខបុកម្នេញ ប្រើអំណាចរំលោភបំពាន និងបៀតបៀនផ្លូវភេទ នៅកន្លែងបំពេញការងារក្នុងរដ្ឋសភាអូស្ត្រាលី។ នៅថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២នេះ ប្រធានរដ្ឋសភាអូស្ត្រាលីរូបនេះ បានបញ្ជូនសេចក្តីថ្លែងការណ៍វិសាមញ្ញមួយទៅសម័យប្រជុំដំបូងនៃរដ្ឋសភាអូស្ត្រាលីសម្រាប់ឆ្នាំ២០២២។ សេចក្តីថ្លែងការណ៍ខាងលើនេះ គឺជាអនុសាសន៍លើកដំបូងក្នុងចំណោមអនុសាសន៍ចំនួន ២៨ នៃការពិនិត្យមើលលើវប្បធម៌បំពុល នៅក្នុងសភារបស់លោកស្រី Kate Jenkins ស្នងការទទួលបន្ទុកការរើសអើងផ្លូវភេទ នៃស្នងការសិទ្ធិមនុស្សប្រចាំប្រទេសអូស្ត្រាលី៕<br>https://www.northerndailyleader.com.au/story/7611891/parliament-apologises-for-staff-harassment/<br>*ប្រែសម្រួលដោយ កែវ ដារី-ឆេង ដារី* |

**អូស្ត្រាលី**

## ប្រធានសភាតំណាងអូស្ត្រាលី៖ អូស្ត្រាលីត្រៀមរួចជាស្រេចក្នុងការលើកកម្ពស់ចំណងទាក់ទងគ្រប់ជ្រុងជ្រោយជាមួយភាគីវៀតណាម

លោក Andrew Bruce Wallace ប្រធានសភាតំណាងអូស្ត្រាលី បានបង្ហាញក្តីសង្ឃឹមរបស់លោកក្នុងការលើកកម្ពស់ចំណងទាក់ទងគ្រប់ជ្រុងជ្រោយជាមួយភាគីវៀតណាម ក្នុងអំឡុងពេលទទួលជួបជាមួយលោក Nguyen Tat Thanh ឯកអគ្គរដ្ឋទូតវៀតណាមប្រចាំប្រទេសអូស្ត្រាលី កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។ លោកប្រធានសភាតំណាងរាស្ត្ររូបនេះ បានធ្វើការកត់សម្គាល់ដោយក្តីសោមនស្សចំពោះការអភិវឌ្ឍជាវិជ្ជមាននៃភាពជាដៃគូយុទ្ធសាស្ត្រវៀតណាម-អូស្ត្រាលី និងបានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លាដែលបានធ្វើឡើងដោយភាគីទាំងពីរ ដើម្បីពង្រឹងទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពខ្ពស់ និងភាពខ្លាំងក្លា ជាមួយនឹងយុទ្ធសាស្ត្រពង្រឹងការចូលរួមសេដ្ឋកិច្ចអូស្ត្រាលី-វៀតណាម(EEES) ដែលបានដាក់ចេញ។

លោក Andrew Bruce Wallace បានអបអរសាទរដល់វៀតណាម ចំពោះការសម្រេចបានកំណើនសេដ្ឋកិច្ច-សង្គម កាលពីឆ្នាំ២០២១ ដោយលោកបានថ្លែងថា វៀតណាមរក្សាបាននូវកំណើនសេដ្ឋកិច្ចជាវិជ្ជមានរបស់ខ្លួន ហើយប្រទេសអូស្ត្រាលីបានក្លាយជាដៃគូពាណិជ្ជកម្មធំបំផុតទី១០ របស់ប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះ បើទោះបីជាពិភពលោកមានការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ក៏ដោយ។ លោក Andrew Bruce Wallace បានកោតសរសើរដល់ទង្វើរបស់វៀតណាម ក្នុងការប្រយុទ្ធនឹងជំងឺរាតត្បាតជាសកល និងការចាក់ថ្នាំបង្ការជំងឺកូវីដ-១៩ ដែលលោកយល់ថា វាគឺជាមូលដ្ឋានគ្រឹះសម្រាប់ប្រទេសទាំងពីរក្នុងការស្តារពាណិជ្ជកម្មជើងហោះហើរក្នុងពេលឆាប់ៗនេះ និងបង្កើនចំណងទាក់ទងសេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគ ក៏ដូចជាការផ្លាស់ប្តូរប្រជាជន និងប្រជាជនទៅវិញទៅមក។

ជាការឆ្លើយតបសម្រាប់ភាគី លោក Nguyen Tat Thanh បានថ្លែងថា វៀតណាមតែងតែចងចាំទុកក្នុងចិត្ត នូវការឧបត្ថម្ភគាំទ្រដ៏មានតម្លៃរបស់ប្រទេសអូស្ត្រាលី ក្នុងអំឡុងពេលនៃបុព្វហេតុនៃការកសាង និងអភិវឌ្ឍន៍ជាតិក្នុងពេល ៥០ឆ្នាំកន្លងមកនេះ រួមទាំងការផ្តល់អំណោយជាថ្នាំបង្ការជំងឺកូវីដ-១៩ របស់ប្រទេសអូស្ត្រាលី ជូនដល់ប្រទេសវៀតណាមផងដែរ។ មន្ត្រីនៃប្រទេសទាំងពីរ បានព្រមព្រៀងគ្នាបង្កើនចំណងទាក់ទងទ្វេភាគី ជាពិសេសចំណងទាក់ទងផ្នែកនីតិប្បញ្ញត្តិ ឆ្ពោះទៅខួបអនុស្សាវរីយ៍លើកទី៥០ ថ្ងៃបង្កើតចំណងការទូតរវាងវៀតណាម-អូស្ត្រាលី(១៩៧៣-២០២៣)។

ភាគីទាំងពីរបានពិភាក្សាគ្នា ពីការបង្កើតក្រុមសមាជិកសភាអូស្ត្រាលី-វៀតណាម ដើម្បីពង្រឹងចំណងទាក់ទងសភាទាំងពីរ និងចែករំលែកនូវក្តីសង្ឃឹម សម្រាប់ការផ្លាស់ប្តូរទៅវិញទៅមកបន្ថែមទៀតនៃដំណើរទស្សនកិច្ចរបស់មេដឹកនាំនៃប្រទេសទាំងពីរ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បី លើកកម្ពស់ភាពជាដៃគូយុទ្ធសាស្ត្ររបស់ប្រទេសទាំងពីរឈានទៅរកកម្រិតថ្មីមួយទៀត៕

https://en.vietnamplus.vn/australia-ready-to-foster-comprehensive-ties-with-vietnam/221832.vnp

*ប្រែសម្រួលដោយ ឈាវ សុផាត*

<table>
<tr>
<td>អ៊ីរ៉ាក់</td>
<td>

**សភាអ៊ីរ៉ាក់ ផ្អាកការបោះឆ្នោត ជ្រើសតាំងប្រធានាធិបតី ដោយគ្មានកំណត់ពេល**

កាលពីថ្ងៃចន្ទ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ សភានៃសាធារណរដ្ឋអ៊ីរ៉ាក់ បានផ្អាកដោយគ្មានកំណត់ពេលនៃគម្រោងការបោះឆ្នោតប្រធានាធិបតីរបស់ប្រទេសមួយនេះ។ មន្ត្រីសភាអ៊ីរ៉ាក់ ១រូប បានថ្លែងបែបនេះ ក្រោយពីមានសមាជិកសភាតែ ៥៨រូប ប៉ុណ្ណោះនៃសមាជិកសភាអ៊ីរ៉ាក់ ៣២៩រូប បានបង្ហាញវត្តមាននៅនាទីចុងក្រោយ។

ក្រុមគណបក្សនយោបាយដ៏សំខាន់ បានប្រកាសរួចហើយថា ពួកគាត់នឹងធ្វើពហិការការបោះឆ្នោតជ្រើសតាំងប្រធានាធិបតី ដែលការបោះឆ្នោតនេះចាំបាច់ត្រូវមានកូរ៉ុមចំនួន ២ភាគ៣ នៃសមាជិកសភា។ មន្ត្រីសភា ១រូប បានថ្លែងក្នុងល័ក្ខខ័ណ្ឌអនាមិក ដោយអះអាងទៅកាន់ទីភ្នាក់សារព័ត៌មានបារាំង (AFP) ថា នៅថ្ងៃចន្ទនឹងមិនមានការបោះឆ្នោតជ្រើសតាំងប្រធានាធិបតីនោះឡើយ៕

https://english.alarabiya.net/News/middle-east/2022/02/07/Iraq-assembly-postpones-presidential-vote-indefinitely-official

*ប្រែសម្រួលដោយ ឈាវ សុផាត*

**រដ្ឋសភាប្រទេសអ៊ីរ៉ាក់ ប្រកាសបើកទ្វារចុះឈ្មោះបេក្ខជនប្រធានាធិបតី**

កាលពីថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ រដ្ឋសភានៃសាធារណរដ្ឋអ៊ីរ៉ាក់ បានប្រកាសបើកទ្វារចុះឈ្មោះបេក្ខជនប្រធានាធិបតីឡើងវិញ។ សេចក្តីប្រកាសរបស់រដ្ឋសភាអ៊ីរ៉ាក់នេះ បានធ្វើឡើងមួយថ្ងៃបន្ទាប់ពីខ្លួនបានបិទបញ្ចប់សម័យប្រជុំបោះឆ្នោតជ្រើសតាំងប្រមុខរដ្ឋអ៊ីរ៉ាក់ថ្មី។ បេក្ខជន ១រូប ក្នុងចំណោមបេក្ខជននាំមុខគេ ២រូប គឺលោក Hoshyar Zebari អតីតរដ្ឋមន្ត្រីក្រសួងការបរទេសអ៊ីរ៉ាក់ ដែលបានកាន់តំណែងយូរជាងគេ ត្រូវបានព្យួរដោយតុលាការ ដែលត្រូវបានគេចោទប្រកាន់លោកថា បានប្រព្រឹត្តអំពើពុករលួយ។ សិទ្ធិឈរឈ្មោះបោះឆ្នោតរបស់ លោក Zebari សម្រាប់តំណែងប្រធានាធិបតីនៅពេលនេះ កំពុងត្រូវបានគេពិនិត្យមើលឡើងវិញ ជាមួយនឹងសេចក្តីប្រកាសរបស់គណបក្សលោក ដែលកំពុងត្រូវបានគេបិទផ្សាយជាមួយនឹងបេក្ខភាពរបស់លោក ហើយបន្ទាប់ពីនោះមកត្រូវបានគេរំពឹងថា សេចក្តីសម្រេចរបស់តុលាការនឹងចេញក្នុងរយៈពេលប៉ុន្មានថ្ងៃខាងមុខនេះ៕

https://english.alarabiya.net/News/middle-east/2022/02/08/Door-reopens-to-candidates-after-Iraq-president-vote-fails

*ប្រែសម្រួលដោយ កែវ ធារី-ឆេង ធារី*

</td>
</tr>
<tr>
<td>តួកគី</td>
<td>

**ប្រធានសភាតួកគី ស្នើចាត់វិធានការតឹងរ៉ឹងប្រឆាំងនឹងការរើសអើងជាតិសាសន៍ ការស្អប់ខ្ពើមជនជាតិឥស្លាម និងការស្អប់ខ្ពើមជនបរទេស**

កាលពីថ្ងៃចន្ទ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ លោក Mustafa Şentop ប្រធានសភានៃសាធារណរដ្ឋតួកគី បានស្នើឱ្យចាត់វិធានការតឹងរ៉ឹង ប្រឆាំងនឹងការរើសអើងជាតិសាសន៍ ការស្អប់ខ្ពើមជនជាតិឥស្លាម និងការ

</td>
</tr>
</table>

| | |
|---|---|
| តួកគី | ស្អប់ខ្ពើមជនបរទេស។ "ថ្ងៃនេះយើងទាំងអស់គ្នាសុទ្ធតែមានក្តីបារម្ភ អំពីការរំខាននៃការកើនឡើងការរើសអើងជាតិសាសន៍ ការស្អប់ខ្ពើមជនបរទេស ការស្អប់ខ្ពើមជនជាតិឥស្លាម និងការប្រើពាក្យសម្តីបង្កការស្អប់ខ្ពើមនៅជុំវិញពិភពលោក និងជាការគំរាមកំហែងធ្ងន់ធ្ងរ ដល់សន្តិភាព និងសុខដុមនីយកម្មរបស់សង្គមយើងទាំងមូល"។ លោក Mustafa Şentop បានថ្លែងបែបនេះ នៅឯកិច្ចប្រជុំរបស់បណ្តាប្រធានសភានៃក្រុមប្រទេស (MIKTA) លើកទី៧ ដែលធ្វើឡើងតាមបែបនិម្មិត(តាមប្រព័ន្ធអ៊ីនធឺណិត)។<br>ដោយបង្កើតឡើងនៅក្នុងឆ្នាំ២០១៣ MIKTA គឺជាភាពជាដៃគូផ្លូវការ ដែលរួមមានប្រទេសម៉ិកស៊ិក ឥណ្ឌូនេស៊ី កូរ៉េខាងត្បូង តួកគី និងប្រទេសអូស្ត្រាលី។ លោក Mustafa Şentop បានថ្លែងថា ការស្អប់ខ្ពើមជនជាតិឥស្លាម បានក្លាយទៅជាទម្រង់មួយដ៏សាមញ្ញបំផុត នៃការរើសអើងជាតិសាសន៍ ក្នុងអំឡុងពេល ២០ឆ្នាំ ចុងក្រោយនេះ។ លោក Mustafa Şentop បានថ្លែងបន្ថែមថា សម្រាប់ហេតុផលនេះ លោកសូមស្នើដល់សមាជិកទាំងអស់នៃសភារបស់យើង ត្រូវចាត់វិធានការមួយដ៏តឹងរ៉ឹង ប្រឆាំងនឹងការរើសអើងការរើសអើងជាតិសាសន៍ ការស្អប់ខ្ពើមជនជាតិឥស្លាម និងនិន្នាការនៃការប្រើពាក្យសម្តីបង្កការស្អប់ខ្ពើម។<br>ដោយរំលឹកថា អង្គការកិច្ចសហប្រតិបត្តិការឥស្លាម (OIC) បានប្រកាសយកថ្ងៃទី១៥ ខែមីនា ថាជាថ្ងៃទិវាអន្តរជាតិនៃសាមគ្គីភាព ប្រឆាំងនឹងការស្អប់ខ្ពើមជនជាតិឥស្លាមនោះ លោក Mustafa Şentop បានថ្លែងថា "ក្នុងនាមជាប្រធានបច្ចុប្បន្ននៃសហភាពសភា នៃអង្គការកិច្ចសហប្រតិបត្តិការឥស្លាម (OIC) លោកគិតថា វាពិតជាមានសារៈសំខាន់សម្រាប់សហគមន៍អន្តរជាតិ ក្នុងការទទួលស្គាល់ និងការធ្វើពិធីរំលឹកដល់ថ្ងៃមួយនេះ ក្នុងន័យជាការតស៊ូពុះពាររួមគ្នារបស់យើង ប្រឆាំងនឹងគ្រោះថ្នាក់មួយនេះ"៕<br>https://www.aa.com.tr/en/turkey/turkiyes-parliament-head-calls-for-concrete-steps-against-racism-islamophobia/2495918<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| នេប៉ាល់ | **ប្រធានសភាតំណាងរាស្ត្រនេប៉ាល់ ទទូចឱ្យរដ្ឋាភិបាលបញ្ចប់ភាពជាប់គាំងនៅក្នុងសភា**<br>រដ្ឋធានីកាដ្ឋមណ្ឌូ៖ លោក Agni Prasad Sapkota ប្រធានសភាតំណាងរាស្ត្រ («HoR» ឬសភាជាន់ទាប) នៃសភាសហព័ន្ធ នៃសាធារណរដ្ឋសហព័ន្ធប្រជាធិបតេយ្យនេប៉ាល់ បានទទូចឱ្យរដ្ឋាភិបាលដោះស្រាយស្ថានភាពជាប់គាំងនៅក្នុងសភាសហព័ន្ធនេប៉ាល់។ នៅក្នុងជំនួបជាមួយ លោក Dilendra Prasad Badu រដ្ឋមន្ត្រីក្រសួងច្បាប់ យុត្តិធម៌ និងកិច្ចការសភា កាលពីថ្ងៃទីចន្ទ ទី០៧ ខែកុម្ភៈ ឆ្នាំ២០២២ លោកប្រធានសភាតំណាងរាស្ត្រនេប៉ាល់ Agni Prasad Sapkota បានលើកឡើងនូវសំណើខាងលើនេះ។ ដោយលោកបានលើកឡើងថា វាមិនមែនជារឿងល្អនោះឡើយក្នុងការអូសបន្លាយពេល ការបង្អាក់ផាផៅដល់ដំណើរការរបស់សភា លោក Agni Prasad Sapkota បានស្នើឱ្យលោករដ្ឋមន្ត្រីរូបនេះ ត្រូវមានភាពច្បាស់លាស់ក្នុងការដកចេញនូវឧបសគ្គមួយនេះ។ សម័យប្រជុំសភាតំណាងរាស្ត្រនេប៉ាល់ បន្ទាប់គ្រោងនឹងធ្វើឡើងនៅថ្ងៃពុធទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ខាងមុខនេះ។ បើតាម លោក Shreedhar Neupane ទីប្រឹក្សាផ្នែកព័ត៌មានរបស់លោកប្រធានសភាតំណាងរាស្ត្រ Agni Prasad Sapkota បានឱ្យដឹងថា មេដឹកនាំទាំងពីររូបបានពិភាក្សាគ្នាពីការបញ្ចប់ភាពជាប់គាំងនៅក្នុងសភានេប៉ាល់។ |

| | |
|---|---|
| **នេប៉ាល់** | គណបក្សប្រឆាំងដ៏សំខាន់ជាងគេ គឺគណបក្ស CPN-UML បានធ្លាធ្លាបង្អាក់កិច្ចប្រជុំរបស់សភាសហព័ន្ធ ដោយជំទាស់ទៅនឹងបែបបទការងាររបស់លោកប្រធានសភានេប៉ាល់។ បើតាមលោកទីប្រឹក្សាផ្នែកព័ត៌មាន Shreedhar Neupane បានឱ្យដឹងថា លោកប្រធានសភាតំណាងរាស្ត្របានថ្លែងថា ស្ថាប័ននីតិប្បញ្ញត្តិនេប៉ាល់ មិនអាចបំពេញមុខងាររបស់ខ្លួនដោយសមស្រប ហើយកិច្ចពិភាក្សាពីកិច្ចការផ្សេងៗដែលមានសារៈសំខាន់ចំពោះជាតិ មិនអាចធ្វើឡើងបាន ដោយសារតែមានការបង្អាក់ធ្លាធ្លានៅក្នុងសភា។ ដូច្នឹង លោក Agni Prasad Sapkota បានទទូចឱ្យគណបក្សនយោបាយនានា ត្រូវសហការគ្នា និងបង្កើតនូវការមូលមតិគ្នា ដើម្បីធ្វើឱ្យសភាមានដំណើរដោយរលូន៕<br>https://thehimalayantimes.com/nepal/speaker-sapkota-urges-government-to-end-deadlock-in-parliament<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **កូរ៉េខាងត្បូង** | **ប្រធានាធិបតីកូរ៉េខាងត្បូង អំពាវនាវសាជាថ្មីម្តងទៀត ឱ្យរដ្ឋសភាអនុម័តបន្ទាន់លើសេចក្តីព្រាងច្បាប់ថវិកាជាតិបន្ថែម**<br>ទីក្រុងសេអ៊ូល៖ កាលពីថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ លោក Moon Jae-in ប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ (កូរ៉េខាងត្បូង) បានអះអាងជាថ្មីម្តងទៀតអំពីការអំពាវនាវរបស់លោក ឱ្យរដ្ឋសភាអនុម័តបន្ទាន់លើសេចក្តីព្រាងច្បាប់ថវិកាជាតិបន្ថែម ដែលត្រូវបានតាក់តែងឡើង ដើម្បីជួយពាណិជ្ជករខ្នាតតូចដោយលោកបានសង្កត់ធ្ងន់ថា ការជួយគាំទ្របន្ទាន់នេះជារឿងចាំបាច់។ លោក Moon បានថ្លែងក្នុងអង្គប្រជុំគណៈរដ្ឋមន្ត្រីក្នុងវិមានប្រធានាធិបតីថា យើងមិនអាចពន្យារពេលការជួយគាំទ្រពាណិជ្ជករខ្នាតតូច និងសូម្បីតែអ្នកដែលត្រូវបានគេជួលរយៈពេលខ្លីក៏ដោយ។ រដ្ឋាភិបាលកូរ៉េខាងត្បូង នឹងពិនិត្យមើលយ៉ាងល្អិតលើផែនការនានា ដែលសមហេតុផលនៅមុនពេលដាក់ជូនរដ្ឋសភាពិនិត្យ និងអនុម័ត។<br>សំណើថវិកាជាតិដែលមានទំហំទឹកប្រាក់ចំនួន ១១លានលានវ៉ុន ស្មើនឹង (១១.៦ ពាន់លានដុល្លារសហរដ្ឋអាមេរិក) ត្រូវបានគេបញ្ជូនទៅរដ្ឋសភារួចហើយ កាលពីខែមករា ឆ្នាំ២០២២។ លោកប្រធានាធិបតី Moon បានថ្លែងសារដូចគ្នានេះ កាលពីសប្តាហ៍មុនថា ការពន្លឿនអនុម័តសេចក្តីព្រាងថវិកាជាតិបន្ថែមនេះ គឺមានសារៈសំខាន់ណាស់។<br>ការកត់សម្គាល់របស់ លោក Moon នេះបានធ្វើឡើងស្របពេលដែលមានការប្រកួតប្រជែងគ្នា រវាងលោក Hong Nam-ki រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ និងគណបក្សនយោបាយមួយចំនួន ដែលបានទាមទារឱ្យមានការចំណាយថវិកាកាន់តែច្រើនពីរដ្ឋាភិបាល។ គណបក្សកាន់អំណាច គឺគណបក្សប្រជាធិបតេយ្យកូរ៉េ (DP) បានស្នើថវិកាជាតិបន្ថែមចំនួន ៣៥លានលានវ៉ុន ហើយគណបក្សប្រឆាំងដ៏ធំជាងគេក្នុងប្រទេសកូរ៉េខាងត្បូង គឺគណបក្សអំណាចប្រជាជន បានអំពាវនាវឱ្យបង្កើនថវិកាចំនួន ៥០លានលានវ៉ុន បន្ថែមទៀត។ លោក Hong ត្រូវបានគេជំទាស់លើការបង្កើនថវិកាជាតិបន្ថែមនេះ ដែលគិតគូអំពីផលប៉ះពាល់លើថ្លៃអ្នកប្រើប្រាស់ និងទីផ្សារមូលប័ត្របំណុលរបស់រដ្ឋ។<br>ទន្ទឹមពេលជាមួយគ្នានេះ លោក Moon ក៏បានអំពាវនាវផងដែរ ឱ្យអាជ្ញាធរកូរ៉េខាងត្បូងរៀបចំការបោះឆ្នោតជ្រើសរើសប្រធានាធិបតីកូរ៉េខាងត្បូង នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ខាងមុខ ឱ្យបានត្រឹមត្រូវ និងផ្តោតជាសំខាន់លើការទប់ស្កាត់វិបត្តិជំងឺកូវីដ-១៩ ដែលបំប្លែងខ្លួនថ្មីឈ្មោះអូមីក្រុង៕<br>https://en.yna.co.kr/view/AEN20220208003600315<br>*ប្រែសម្រួលដោយ កែវ ដាវី-ផេង ដាវី* |

| | |
|---|---|
| ជប៉ុន | **សភាជប៉ុន អនុម័តសេចក្តីសម្រេចស្តីពីប្រទេសអ៊ុយក្រែន ថ្កោលទោសការផ្លាស់ប្តូរស្ថានការណ៍បច្ចុប្បន្នដោយប្រើកម្លាំងទ័ព**<br>រាជធានីតូក្យូ៖ កាលពីថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ សភាជប៉ុនបានអនុម័តសេចក្តីសម្រេចមួយស្តីពីការកើនឡើងនៃភាពតានតឹងនៅក្នុងប្រទេសអ៊ុយក្រែន ដោយបានថ្កោលទោសរាល់ការប៉ុនប៉ងណាមួយក្នុងការផ្លាស់ប្តូរស្ថានការណ៍បច្ចុប្បន្ន ដោយប្រើកម្លាំងកងទ័ព និងបានទទូចឱ្យរាជរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី Fumio Kishida ប្រឹងប្រែងឱ្យអស់ពីលទ្ធភាព ដើម្បីជួយឱ្យសម្រេចបាននូវសន្តិភាពមួយ។ សេចក្តីសម្រេចរបស់សភាជាន់ទាបជប៉ុននេះ បានកើតមានឡើងក្រោយពីសហព័ន្ធរុស្ស៊ី បានប្រមូលផ្តុំកងទ័ពជាង ១០០,០០០នាក់ នៅតាមបណ្តោយព្រំដែនជាមួយប្រទេសអ៊ុយក្រែន បង្កើនការភ័យខ្លាចពីសង្គ្រាមមួយដែលអាចនឹងកើតមានឡើង។<br>សេចក្តីសម្រេចរបស់រដ្ឋសភាជប៉ុនមានខ្លឹមសារថា "យើងមានក្តីបារម្ភយ៉ាងជ្រាលជ្រៅ អំពីស្ថានការណ៍ខាងលើ សភាជប៉ុនសូមប្រកាសថា យើងនឹងឈរនៅជាមួយនឹងប្រជាជនអ៊ុយក្រែនជានិច្ច ដែលពួកគេមានក្តីសង្ឃឹមចំពោះស្ថិរភាពនៅក្នុងប្រទេសរបស់ខ្លួន និងនៅក្នុងតំបន់។ ការផ្លាស់ប្តូរស្ថានការណ៍បច្ចុប្បន្នដោយប្រើកម្លាំងទ័ពពីសំណាក់ប្រទេសណាមួយ គឺមិនអាចទទួលយកបានជាដាច់ខាត"។ នៅក្នុងជំនួបតាមប្រព័ន្ធនិម្មិតកាលពីខែមករា ឆ្នាំ២០២២ លោក Fumio Kishida និងលោក Joseph Robi nette Biden Jr ប្រធានាធិបតីសហរដ្ឋអាមេរិក បានប្តេជ្ញារួមគ្នា ក្នុងការធ្វើការងាររួមគ្នា ប្រឆាំងនឹងការឈ្លានពានរបស់សហព័ន្ធរុស្ស៊ីមកលើប្រទេសអ៊ុយក្រែន។ លោកនាយករដ្ឋមន្ត្រីជប៉ុនរូបនេះ បានប្តេជ្ញាធ្វើការសម្របសម្រួលជាមួយសហរដ្ឋអាមេរិក និងសហគមន៍អន្តរជាតិ ក្នុងការចាត់វិធានការដ៏ខ្លាំងក្លាមួយ ដើម្បីឆ្លើយតបទៅនឹងការវាយប្រហារណាមួយ ដែលអាចកើតឡើងពីសំណាក់ប្រទេសរុស្ស៊ី។<br>សេចក្តីសម្រេចខាងលើមានខ្លឹមសារបន្តថា "យើងទាមទារយ៉ាងទទូចឱ្យរាជរដ្ឋាភិបាល ត្រូវបង្ហាញនូវចេតនារបស់យើង ដោយធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ប្រើប្រាស់នូវប្រភពធនធានការទូតទាំងអស់ និងធ្វើឡើងដោយអស់ពីចិត្តពីថ្លើម ដើម្បីបន្ធូរបន្ថយភាពតានតឹងនៅក្នុងប្រទេសអ៊ុយក្រែន និងទទួលបាន នូវសន្តិភាពមួយពិតប្រាកដយ៉ាងឆាប់រហ័ស"។ គួរបញ្ជាក់ផងដែរថា ចំណងទាក់ទងរវាងប្រទេសជប៉ុន សហព័ន្ធ និងរុស្ស៊ី ត្រូវបានញាំញីជាយូរមកហើយ ដោយសារតែជម្លោះទឹកដី ពាក់ព័ន្ធនឹងជួរកោះប៉ាស៊ីហ្វិកខាងលិច ដែលទាហានអតីតសហភាពសូវៀតបានរឹបអូសយក នៅពេលបញ្ចប់សង្គ្រាមលោកលើកទី២៕<br>https://wsau.com/2022/02/07/japan-parliament-resolution-on-ukraine-condemns-changing-status-quo-with-force/<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |

| | |
|---|---|
| **អេមីរ៉ាត អារ៉ាប់រួម** | **ប្រធានសភាអេមីរ៉ាតអារ៉ាប់រួម ជួបពិភាក្សាការងារជាមួយ ប្រធានសភាអ៊ីស្រាអែល**<br>លោកបណ្ឌិត Ali Rashid Al Nuaimi ប្រធានគណៈប្រតិភូនៃក្រុមប្រឹក្សាជាតិសហព័ន្ធ («FNC»សភាអេមីរ៉ាតអារ៉ាប់រួម) ដែលកំពុងតែបំពេញទស្សនកិច្ចនៅក្នុងប្រទេសអ៊ីស្រាអែល បានជួបជាមួយ លោក Mickey Levy ប្រធានសភាអ៊ីស្រាអែល។ ក្នុងជំនួបនោះ ភាគីទាំងពីរបានពិភាក្សាគ្នាស្វែងរកមធ្យោបាយ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃកិច្ចព្រមព្រៀង Abraham ដែលបានចុះហត្ថលេខារវាងអេមីរ៉ាតអារ៉ាប់រួម និងអ៊ីស្រាអែល ដែលបានជួយបង្កើតនូវកាលានុវត្តភាព សម្រាប់កិច្ចសហប្រតិបត្តិការជាពិសេសនៅក្នុងវិស័យសភា។<br>សម្រាប់ភាគីលោក Mickey Levy បានសង្កត់ធ្ងន់ថា ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូសភា FNC គឺជាប្រវត្តិសាស្ត្រមួយ ដែលវាជាដំណើរទស្សនកិច្ចសភាជាលើកដំបូងមកកាន់អ៊ីស្រាអែល និងបានកត់សម្គាល់ថា សភាអ៊ីស្រាអែលកំពុងបង្កើតនូវគណៈកម្មាធិការមិត្តភាពសភា ជាមួយអេមីរ៉ាតអារ៉ាប់រួម។ លោកក៏បានគូសបញ្ជាក់ពីតួនាទីគន្លឹះរបស់សភា ក្នុងការធ្វើឱ្យប្រសើរឡើងនូវចំណងទាក់ទងទ្វេភាគី និងបានអញ្ជើញប្រធានសភាអេមីរ៉ាតអារ៉ាប់រួម មកបំពេញទស្សនកិច្ចនៅក្នុងប្រទេសអ៊ីស្រាអែល៕<br>https://menafn.com/1103658450/UAE-Ali-Al-Nuaimi-meets-Knesset-Speaker<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **ប៉ាគីស្ថាន** | **គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រទេសប៉ាគីស្ថាន ពិន័យសមាជិករដ្ឋសភា ១រូប ចំនួន ៤០.០០០ រូបពីប៉ាគីស្ថាន**<br>ទីក្រុង PESHAWAR៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន (ECP) បានពិន័យជាប្រាក់ចំនួន ៤០.០០០រូបពីប៉ាគីស្ថាន លើសមាជិករដ្ឋសភាប៉ាគីស្ថាន ១រូប មកពីគណបក្ស Jamiat Ulema-i-Islam, JUIF ពីបទរំលោភលើក្រមសីលធម៌នៃការបោះឆ្នោត។ មន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ១រូប បានថ្លែងថា ប្រាក់ពិន័យចំនួន ៤០,០០០រូបពីប៉ាគីស្ថាននេះ ត្រូវបានគេពិន័យលើ លោក Mohammad Jamaluddin សមាជិករដ្ឋសភាប៉ាគីស្ថាន ពីបទសម្ដែងមតិយោបល់នៅក្នុងសន្និសីទសារព័ត៌មានមួយ គាំទ្របេក្ខភាពរបស់គណបក្ស Jamiat Ulema-i-Islam, JUIF សម្រាប់ក្រុមប្រឹក្សាក្រុង Dera Ismail Khan ដែលជាការរំលោភលើក្រមសីលធម៌នៃការបោះឆ្នោត។ មន្ត្រីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរូបនេះ បានថ្លែងទៀតថា មន្ត្រីថ្នាក់គ្រប់គ្រងស្រុករូបនេះ នៅក្នុងដីការបស់លោកក៏បានព្រមានផងដែរ អំពីការប្រព្រឹត្តនូវទង្វើរជ្រុលហួសហេតុណាមួយ និងការព្រមានថានឹងបញ្ជូនសំណុំរឿងនេះ ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប៉ាគីស្ថាន ក្នុងករណីរំលោភបំពានណាមួយដោយសមាជិករដ្ឋសភាប៉ាគីស្ថានរូបនេះ៕<br>https://www.thenews.com.pk/print/932017-violation-of-code-of-conduct-ecp-imposes-rs40-000-fine-on-juif-mna<br>*ប្រែសម្រួលដោយ កែវ ដាវី-ឆេង ដាវី* |

| | |
|---|---|
| **ប៉ាគីស្ថាន** | **រដ្ឋសភាប្រទេសប៉ាគីស្ថាន ថ្កោលទោសសកម្មភាពដ៏គឃ្លើនរបស់កងកម្លាំងយោធាឥណ្ឌា ដែលកំពុងបន្តកាន់កាប់តំបន់ជម្លោះកាស្មៀរ**<br>ទីក្រុងអ៊ីស្លាម៉ាបាដ៖ កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ គណៈកម្មាធិការជំនាញនៃរដ្ឋសភានៃសាធារណរដ្ឋឥស្លាមប៉ាគីស្ថានមួយ បានថ្កោលទោសសកម្មភាពដ៏គឃ្លើន របស់កងកម្លាំងយោធាឥណ្ឌា ដែលបានកំពុងបន្តកាន់កាប់តំបន់ Jammu និងតំបន់ Kashmir ដោយខុសច្បាប់ និងបានបង្ហាញពីសាមគ្គីភាពជាមួយប្រជាពលរដ្ឋកាស្មៀ ដែលគ្មានកំហុសនៅក្នុងការដោះស្រាយ ដែលមិនងាករេនូវសិទ្ធិសម្រេចរបស់ខ្លួន។<br>តាមរយៈសេចក្តីសម្រេចមួយដែលត្រូវបានអនុម័តជាឯកច្ឆន្ទ គណៈកម្មាធិការកិច្ចការកាស្មៀ និងតំបន់ Gilgit-Baltistan ភាគខាងជើងប្រទេសប៉ាគីស្ថាន បានរិះគន់តួនាទីអ្នកសង្កេតការណ៍ឯករាជ្យរបស់អង្គការសិទ្ធិមនុស្សអន្តរជាតិ ដែលរួមមានអង្គការសហប្រជាជាតិ (UN) ដែលមិនបានចេញសេចក្តីថ្លែងការណ៍របស់ខ្លួន ស្តីពីការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដោយរដ្ឋាភិបាលឥណ្ឌា នៅជ្រលងភ្នំដែលខ្លួនកំពុងកាន់កាប់។<br>នៅក្នុងកិច្ចប្រជុំដែលត្រូវបានដឹកនាំដោយ លោក Rana Shamim Ahmed Khan ប្រធានគណៈកម្មាធិការកិច្ចការកាស្មៀ និងតំបន់ Gilgit-Baltistan ភាគខាងជើងនៃរដ្ឋសភា និងត្រូវបានចូលរួមដោយសមាជិកគណៈកម្មាធិការរបស់ខ្លួនជាច្រើនរូប ដែលរួមមាន លោក Mehboob Shah, លោក Mohammad Bashir Khan, លោក Mohammad Yaqoob Sheikh, លោក Saleem Rehman, លោក Niaz Ahmed Jakhar, លោកស្រី Rubina Jamil, លោកស្រី Ghazala Saifi, លោក Jamshed Thomas, លោក Syed Imran Ahmed Shah, លោក Nasir Iqbal Bosal, លោកស្រី Shamim Ara Panhwar។<br>គណៈកម្មាធិការនេះបានកត់សម្គាល់ថា សន្តិភាពនៅក្នុងឧបទ្វីប ដែលជាប្រធានបទមួយត្រូវដោះស្រាយជម្លោះនៅតំបន់កាស្មៀ ដែលនៅបន្សល់ទុកអូសបន្លាយពេលជាយូរនោះ គឺអាស្រ័យលើឆន្ទៈរបស់ប្រជាពលរដ្ឋកាស្មៀ និងសេចក្តីសម្រេចនានា របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ។ គណៈកម្មាធិការនេះបានផ្តល់មតិយោបល់ថា សកម្មភាពដ៏គឃ្លើនរបស់កងកម្លាំងយោធាឥណ្ឌាទាំងនេះ មិនអាចបង្ក្រាបប្រជាជនកាស្មៀឱ្យបោះបង់ការទាមទារសិទ្ធិសម្រេចរបស់ខ្លួនបានឡើយ៕<br>http://www.parliament.am/news.php?cat_id=2&NewsID=16028&year=2022&month=02&day<br>*ប្រែសម្រួលដោយ កែវ ធារី-ឆេង ធារី* |
| **អាមេនី** | **រដ្ឋសភាប្រទេសអាមេនី បើកសម័យប្រជុំដើម្បីពិនិត្យ និងអនុម័តលើការពង្រីកតំបន់ដែលប្រើប្រាស់ទង់ជាតិរដ្ឋរបស់ប្រទេសអាមេនី**<br>កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ រដ្ឋសភានៃសាធារណរដ្ឋអាមេនី បានបើកសម័យប្រជុំរបស់ខ្លួនដើម្បីពិនិត្យ និងអនុម័ត លើកញ្ចប់សេចក្តីស្នើច្បាប់ស្តីពីការបំពេញបន្ថែម និងការធ្វើវិសោធនកម្មលើសេចក្តីស្នើច្បាប់ស្តីពីទង់ជាតិនៃសាធារណរដ្ឋអាមេនី និងការបំពេញបន្ថែម លើក្រមស្តីពីបទល្មើសរដ្ឋបាល ដែលត្រូវបានតាក់តែងឡើងដោយសមាជិករដ្ឋសភា ១រូប មកពីក្រុមសម្ព័ន្ធភាពគណបក្សនយោបាយអាមេនីក្នុងដំណាក់កាលទី១។ យោងតាម លោក Aghvan Vardanyan សមាជិករដ្ឋសភាអាមេនី និងជាអតីត |

| | |
|---|---|
| **អាមេនី** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និងការងារបានឱ្យដឹងថា គោលបំណងសំខាន់នៃសេចក្តីស្នើច្បាប់នេះ គឺចង់ផ្សព្វផ្សាយជាសាធារណៈ អំពីអត្តសញ្ញាណជាតិឱ្យបានទូលំទូលាយបំផុតជាអតិបរមា ទង់ជាតិនៃសាធារណរដ្ឋអាមេនី ការពង្រឹងឥរិយាបថគោរពប្រជាពលរដ្ឋអាមេនី ជាពិសេសកុមារ និងយុវជនឆ្ពោះទៅរកភាពជារដ្ឋ។<br>សេចក្តីស្នើច្បាប់នេះ ត្រូវបានគេស្នើឡើងដើម្បីកំណត់ អំពីការតម្រូវឱ្យបង្ហូតទង់ជាតិសាធារណរដ្ឋអាមេនីជាអចិន្ត្រៃយ៍ នៅលើអាគារសាលារៀន អាគារអប់រំទូទៅ គ្រឹះស្ថានអប់រំថ្នាក់ឧត្តមសិក្សា ក្រសួង-ស្ថាប័នវប្បធម៌ និងវិទ្យាសាស្ត្រ និងនីតិបុគ្គលផ្សេងៗទៀត ដែលត្រូវបានបង្កើតដោយរដ្ឋ និងសហគមន៍។ សេចក្តីស្នើច្បាប់នេះ ក៏ត្រូវបានគេស្នើឡើងផងដែរដើម្បីកំណត់ អំពីបញ្ហាប្រើប្រាស់ទង់ជាតិរដ្ឋនៅលើអាគារជាប់ៗគ្នា ដើម្បីជាយុត្តាធិការសាធារណៈ សម្រាប់ប្រើប្រាស់នៅថ្ងៃបុណ្យទិវារដ្ឋធម្មនុញ្ញ និងនៅថ្ងៃបុណ្យឯករាជ្យជាតិ និងសាធារណៈរដ្ឋ។<br>អ្នកតាក់តែងសេចក្តីស្នើច្បាប់នេះ បានគូសបញ្ជាក់ថា ខ្លួនមានបំណងចង់កំណត់ការទទួលខុសត្រូវផ្នែករដ្ឋបាលលើការរំលោភច្បាប់ជាក់លាក់។ នៅក្នុងសហរបាយការណ៍របស់លោកស្រី Alkhas Ghazaryan សមាជិកាគណៈកម្មាធិការកិច្ចការច្បាប់ និងរដ្ឋនៃរដ្ឋសភា លោកស្រីបានបង្ហាញពីការយល់ស្របរបស់គណៈកម្មាធិការខ្លួន។ លោក Arayik Khzmalyan អនុរដ្ឋមន្ត្រីក្រសួងអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និងកីឡា បានផ្តល់មតិយោបល់គាំទ្រលើកញ្ចប់សេចក្តីស្នើច្បាប់នេះ៕<br>http://www.parliament.am/news.php?cat_id=2&NewsID=16028&year=2022&month=02&day=09&lang=eng<br>*ប្រែសម្រួលដោយ កែវ ធារី-ឆេង ធារី* |
| **រុស្ស៊ី** | **រដ្ឋសភារុស្ស៊ី គ្រោងពិចារណាលើសេចក្តីព្រាងច្បាប់ ស្តីពីការទទួលស្គាល់សាធារណរដ្ឋប្រជាមានិត Donetsk និង Lugansk មុននឹងបញ្ជូលទៅលោកប្រធានាធិបតីរុស្ស៊ី**<br>ទីក្រុងមូស្គូ៖ កាលពីថ្ងៃព្រហស្បតិ៍ ទី១០ ខែកុម្ភៈ ឆ្នាំ២០២២ លោក Leonid Kalashnikov ប្រធានគណៈកម្មាធិការកិច្ចការរដ្ឋឯករាជ្យ Commonwealth សមាហរណ៍កម្មប្រជាពលអឺរ៉ុប-អាស៊ី និងទំនាក់ទំនងជាមួយជនរួមជាតិរុស្ស៊ីនៃរដ្ឋសភារុស្ស៊ី បានថ្លែងប្រាប់ទីភ្នាក់ងារសារព័ត៌មាន TASS News ថា គណៈកម្មាធិការទទួលបន្ទុកលើបញ្ហារដ្ឋឯករាជ្យ Commonwealth និងទំនាក់ទំនងជាមួយជនរួមជាតិរុស្ស៊ី ទំនងជានឹងពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីភាពចាំបាច់ក្នុងការទទួលស្គាល់សាធារណរដ្ឋប្រជាមានិត Donetsk និងសាធារណរដ្ឋប្រជាមានិត Lugansk ក្នុងប្រទេសអ៊ុយក្រែនមុននឹងបញ្ជូនទៅ លោក Vladimir Puti ប្រធានាធិបតីសហព័ន្ធរុស្ស៊ី នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២ខាងមុខនេះ៕<br>https://tass.com/politics/1400683<br>*ប្រែសម្រួលដោយ កែវ ធារី-ឆេង ធារី* |

## II.ទ្វីបអាហ្វ្រិក

| ប្រទេស | ខ្លឹមសារអត្ថបទព័ត៌មាន |
|---|---|
| ហ្គីណេ | **សភាបណ្ដោះអាសន្ននៃប្រទេសហ្គីណេ រៀបចំកិច្ចប្រជុំលើកដំបូង ក្រោយរដ្ឋប្រហារ**<br>សភាបណ្ដោះអាសន្ននៃប្រទេសហ្គីណេ បានរៀបចំកិច្ចប្រជុំលើកដំបូងរបស់ខ្លួនរយៈពេល៥ខែ ក្រោយពីផ្ដួលរំលំប្រធានាធិបតីជាប់ឆ្នោត តាមលក្ខណៈប្រជាធិបតេយ្យ លោក Alpha Conde។ ស្ថាប័ននេះដែរត្រូវគេស្គាល់តាមរយៈអក្សរកាត់ភាសាបារាំង CNT និងមានកាតព្វកិច្ចរៀបចំ ឱ្យវិលត្រឡប់ទៅការគ្រប់គ្រងដោយស៊ីវិលឡើងវិញ បានរៀបចំជំនួបនៅរដ្ឋធានី Conakry កាលពីថ្ងៃសៅរ៍។<br>ដោយនិយាយយោងដល់លោក ដែលបានបង្កឱ្យផ្ទុះកំហឹងដោយការកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីឈរឈ្មោះបោះឆ្នោតអាណត្តិទី៣ ប្រធាន CNT លោក Dansa Kourouma បាននិយាយនៅក្នុងការថ្លែងបើកជំនួបនោះថា យន្តការជាច្រើនដែលនាំឱ្យឥស្សរជនឡើងកាន់អំណាច និងអនុញ្ញាតឱ្យពួកគេ ឱ្យបន្តកាន់អំណាចត្រូវតែរៀបចំឱ្យបានត្រឹមត្រូវ។ លោកបានអំពាវនាវឱ្យព្រាងរដ្ឋធម្មនុញ្ញមួយ ដែលនឹងមិនត្រូវបានកែប្រែយ៉ាងស្រួលនោះទេ។<br>លោក Kourouma បានបន្ថែមថា៖ «មាគ៌ារបស់យើងនឹងត្រូវបានរៀបចំដោយមានបញ្ហាជាច្រើនដែលយើងត្រូវបានកោះហៅ ឱ្យចូលរួមចាប់ពីពេលនេះតទៅ រហូតដល់រៀបចំសភាជាតិនៅពេលអនាគត។ លោក Conde ដែលជាប្រធានាធិបតីជាប់ឆ្នោត តាមលក្ខណៈប្រជាធិបតេយ្យលើកដំបូងនៅប្រទេសហ្គីណេ និងឡើងកាន់អំណាច ចាប់តាំងពីឆ្នាំ២០១០ ត្រូវបានទម្លាក់ពីអំណាចកាលពីថ្ងៃទី៥ ខែកញ្ញា។ លោកនាយករដ្ឋមន្ត្រីបណ្ដោះអាសន្ន Mohamed Beavogui ជាអ្នកជំនាញអភិវឌ្ឍន៍បានចូលរួមកិច្ចប្រជុំដែលមានរយៈពេលជាច្រើនម៉ោង។<br>លោកវរសេនីយ៍ឯក Mamady Doumbouya ដែលបានដឹកនាំរដ្ឋប្រហារ ហើយបានស្បថចូលកាន់តំណែងជាប្រធានាធិបតីបណ្ដោះអាសន្ន បានសន្យាកែទម្រង់រដ្ឋឡើងវិញ ប្រយុទ្ធប្រឆាំងអំពើពុករលួយ និងកែទម្រង់ប្រព័ន្ធបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតដោយសេរី មានតម្លាភាពជាតិ និងគួរឱ្យជឿទុកចិត្ត។ សមាជិក CNT ត្រូវបានជ្រើសរើសដោយ លោក Doumbouya ចេញពីបញ្ជីដែលដាក់ជូនគណបក្សនយោបាយ និងសមាគមនានា។ ស្ថាប័ននេះមានកាតព្វកិច្ចព្រាងរដ្ឋធម្មនុញ្ញថ្មីមួយ និងស្នើកាលបរិច្ឆេទមួយដើម្បីវិលត្រឡប់ទៅរកការគ្រប់គ្រងដោយស៊ីវិលឡើងវិញ។ នៅពេលជាមួយគ្នានោះ រដ្ឋាភិបាល និងស្ថាប័នដទៃទៀត ត្រូវបានរំលាយចោលរដ្ឋមន្ត្រី អភិបាលខេត្ត និងអ្វីផ្សេងៗទៀត ត្រូវជំនួសដោយបុគ្គលិករដ្ឋបាល និងទាហាន។<br>សហគមន៍សេដ្ឋកិច្ចនៃបណ្ដារដ្ឋអាហ្វ្រិកខាងលិច (ECOWAS) បានទាមទារថា ប្រទេសហ្គីណេគួរតែរៀបចំការបោះឆ្នោតក្នុងរយៈពេល ៦ខែ ក្រោយរដ្ឋប្រហារដែលនឹងត្រូវធ្វើនៅពាក់កណ្ដាលខែមីនា។ ប្រទេសហ្គីណេ គឺជាប្រទេស១ ក្នុងចំណោមប្រទេសអាហ្វ្រិកខាងលិច៣ រួមមានប្រទេសម៉ាលី និងប៊ួគីណាហ្វាសូ ជាទីដែលបានរឹបអូសអំណាចកាលពី ១៨ខែ កន្លងទៅនេះ។ ប្លុកសមាជិក ១៥ប្រទេស បានព្យួរប្រទេស |

| | |
|---|---|
| **ហ្គីណេ** | ហ្គីណេ និងម៉ាលី នៅជិតខាង និងបានដាក់ទណ្ឌកម្មជុំវិញរដ្ឋប្រហារ។ ការបង្ហាញពីការផ្ដើននោះ ប្រធាននៃក្រុមប្រឹក្សាបណ្ដោះអាសន្ននៃប្រទេសម៉ាលី និងអតីតសមាជិករដ្ឋាភិបាលយោធា លោកវរសេនីយ៍ឯក Malick Diaw បានចូលរួមកិច្ចប្រជុំសភាកាលពីថ្ងៃសៅរ៍។<br>លោក Diaw បាននិយាយថា៖ «អន្តរកាលនយោបាយកំពុងដំណើរការនៅប្រទេសម៉ាលី និងហ្គីណេ ស្ថិតក្នុងស្ថានភាពដ៏ចម្រូងចម្រាស ដោយបានបន្ថែមថា គោលបំណងចុងក្រោយគឺធ្វើឱ្យស្ថានភាពនយោបាយត្រឡប់ទៅរកភាពប្រក្រតីឡើងវិញ។ ជ័យជម្នះរបស់ លោក Conde ក្នុងឆ្នាំ២០១០ បានបញ្ចប់ការគ្រប់គ្រងផ្ដាច់ការជាច្រើនទសវត្សរ៍ ដោយប្រធានាធិបតីដំបូង ២រូប របស់ប្រទេសនេះ គឺលោក Sekou Toure និងលោក Lansana Conte ដែលបានកាន់តំណែង ២៦ឆ្នាំ និង ២៤ឆ្នាំរៀងៗខ្លួន។ លោក Conde បានជាប់ឆ្នោតអាណត្តិទី២ នៅក្នុងឆ្នាំ២០១៥ ប៉ុន្តែលោកត្រូវគេមិនពេញចិត្ត នៅពេលដែលលោកបានជំរុញឱ្យមានប្រជាមតិរដ្ឋធម្មនុញ្ញគាំទ្រដោយរុស្ស៊ី ដែលបានអនុញ្ញាតឱ្យលោកស្វះស្វែងអាណត្តិទី៣ ដ៏ចម្រូងចម្រាស នៅក្នុងការបោះឆ្នោត ខែតុលា ឆ្នាំ២០២០ ដែលលោកបានឈ្នះនោះ៕<br>*ភ្នំពេញប៉ុស្តិ៍ ថ្ងៃអង្គារ ទី៨ ខែកុម្ភៈ ឆ្នាំ២០២២ ទំព័រទី១៨* |
| **លីប៊ី** | **សភាលីប៊ីគ្រោងតែងតាំងនាយករដ្ឋមន្ត្រីថ្មី ស្របពេលភាពតានតឹងកើនឡើង**<br>សភាលីប៊ីនឹងតែងតាំងនាយករដ្ឋមន្ត្រីថ្មី ដើម្បីដឹកនាំរដ្ឋាភិបាលអន្តរកាលក្នុងសប្តាហ៍នេះ ដោយនាំឱ្យមានការព្រួយបារម្ភ អំពីលទ្ធភាពនៃការតស៊ូដើម្បីទាមទារអំណាចជាថ្មី។ បេក្ខជន ២រូប អតីតរដ្ឋមន្ត្រីមហាផ្ទៃ លោក Fathi Bashaga និងទីប្រឹក្សារដ្ឋមន្ត្រី លោក Khalid al-Baibas បានបង្ហាញខ្លួននៅក្នុងកិច្ចប្រជុំសភា កាលពីថ្ងៃចន្ទ នៅក្នុងទីក្រុង Tobruk ភាគខាងកើត និងធ្វើបទបង្ហាញពីផែនការរបស់ពួកគេ និងដាក់ឯកសាររបស់ពួកគេ ដើម្បីជំនួសតំណែងលោកនាយករដ្ឋមន្ត្រី Abdul Hamid Dbeibah។<br>ប្រធានសភា លោក Aguila Saleh បាននិយាយថា ការបោះឆ្នោតមួយដើម្បីតែងតាំងនាយករដ្ឋមន្ត្រី ១រូប ក្នុងចំណោមពួកគេទាំង២ នឹងកើតឡើងនៅថ្ងៃព្រហស្បតិ៍នេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាជាន់ខ្ពស់ ជាស្ថាប័នផ្ដល់យោបល់មួយមានមូលដ្ឋាននៅក្នុងក្រុងទ្រីប៉ូលី។ វិធានការរបស់សភាដើម្បីតែងតាំងរដ្ឋាភិបាលថ្មី គឺជាការឆ្លើយតបមួយចំពោះបេសកកម្ម UN នៅក្នុងប្រទេសនេះ ដែលគាំទ្រឱ្យមានការបោះឆ្នោតប្រធានាធិបតី ដែលពីដំបូងឡើយគ្រោងធ្វើនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ដែលត្រូវបានពន្យារពេល បន្ទាប់ពីជម្លោះជុំវិញច្បាប់ដែលគ្រប់គ្រងការបោះឆ្នោត និងបេក្ខភាពប្រធានាធិបតី។ វិធានការនេះក៏បង្កើនការព្រួយបារម្ភថា ការបោះឆ្នោតនៅថ្ងៃព្រហស្បតិ៍ អាចមើលឃើញពីការកើតឡើងដដែលៗនៃការបែកបាក់នៅក្នុងឆ្នាំ២០១៤ ដែលបានមើលឃើញការកើតឡើងរដ្ឋាភិបាលប្រហាក់ប្រហែលគ្នា២ ដោយនាំឱ្យប្រទេសនេះធ្លាក់ចូលក្នុងជម្លោះប្រដាប់អាវុធ។<br>អ្នកនាំពាក្យរង UN លោក Farhan Haq បាននិយាយកាលពីថ្ងៃចន្ទថា ការចរចាកំពុងបន្តជាមួយភាគីលីប៊ី ដើម្បីបញ្ចៀសការវិលត្រឡប់ទៅរកជម្លោះ និងភាពច្របូកច្របល់ ដែលមានរយៈពេល ១ទសវត្សរ៍កន្លងទៅនេះ។ លោក Haq បាននិយាយនៅពេលគេសួរ អំពីកង្វល់ដែលប្រទេសលីប៊ី អាចវិលត្រឡប់ទៅ |

| | |
|---|---|
| **លីប៊ី** | កេអាផ្ទាធរនយោបាយប្រឆាំងនោះថា៖ «យើងពិតជាស្មើឱ្យភាគីលីប៊ី សម្លឹងថយក្រោយទៅនឹងអ្វីដែលកាលពីប៉ុន្មានឆ្នាំកន្លងទៅបានកើតឡើង និងអ្វីដែលនឹងកើតឡើងនៅពេលអនាគត»។<br>លោក Dbeibah បាននិយាយថា គាត់(Dbeibah) និងរដ្ឋាភិបាលរបស់គាត់ នឹងបន្តកាន់អំណាចរហូតដល់មានការបោះឆ្នោតពិតប្រាកដកើតឡើង ប៉ុន្តែសមាជិកសភាខ្លះបានបញ្ជាក់ថា អាណត្តិរបស់គាត់បានចប់ កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១។ គាត់បានចោទ លោក Saleh ដែលបានដឹកនាំកិច្ចប្រឹងប្រែងដើម្បីឱ្យគេជំនួសតំណែងរបស់គាត់ ជុំវិញការបង្កឱ្យមានការបែកបាក់នៅក្នុងប្រទេស និងជំរុញឱ្យព្រាងរដ្ឋធម្មនុញ្ញថ្មីមួយនៅមុនការបោះឆ្នោត។ លោក Saleh បាននិយាយថា សមាជិកសភាទាំងអស់បានអនុម័តផែនទីផ្លូវមួយ ដើម្បីរៀបចំការបោះឆ្នោតប្រធានាធិបតីក្នុងរយៈពេល ១៤ខែ ក្រោយពីឯកភាពគ្នាទៅលើវិសោធនកម្មរដ្ឋធម្មនុញ្ញ។<br>លោកបានបន្ថែមថា គណៈកម្មាធិការសភាគ្រោងធ្វើការពិភាក្សាជាមួយក្រុមប្រឹក្សារដ្ឋជាន់ខ្ពស់ ដើម្បីព្រាងវិសោធនកម្ម ដែលត្រូវការចាំបាច់ក្នុងរយៈពេល ១សប្តាហ៍។ លោក Khaled al-Mishri ប្រធានក្រុមប្រឹក្សានេះបាននិយាយថា សមាជិកទាំងអស់បានឯកភាពគ្នាជាមួយសភា ដើម្បីអនុម័តផែនទីផ្លូវមួយសម្រាប់ការបោះឆ្នោត នៅពេលដែលរដ្ឋាភិបាលថ្មីមួយត្រូវបានតែងតាំង។ លោកបានថ្លែងប្រាប់សន្និសីទសារព័ត៌មានមួយនៅទីក្រុងទ្រីប៉ូលី កាលពីថ្ងៃអាទិត្យថា៖ «យើងអនុម័តតម្រូវការរបស់សភា ដើម្បីផ្លាស់ប្តូររដ្ឋាភិបាល ប៉ុន្តែវាចាំបាច់ត្រូវកំណត់មាគ៌ាមួយស្របតាមរដ្ឋធម្មនុញ្ញ សម្រាប់ការបោះឆ្នោតលើកដំបូងដើម្បីចៀសវាងបញ្ហាមិនប្រក្រតីណាមួយកើតឡើង»៕<br>https://www.postkhmer.com/international/2022-02-10-1359-231460.html<br>*ដកស្រង់ពីសារព័ត៌មាន postkhmer.com ដោយ ឈាវ សុផាត* |

## III.ទ្វីបអឺរ៉ុប

| ប្រទេស | ខ្លឹមសារអត្ថបទព័ត៌មាន |
|---|---|
| **ម៉ុងតេណេហ្គ្រោ** | **រដ្ឋាភិបាលម៉ុងតេណេហ្គ្រោ ដួលរលំនៅក្នុងការបោះឆ្នោតដកសេចក្តីទុកចិត្តពីសភា**<br>សមាជិកសភាម៉ុងតេណេហ្គ្រោ បានបោះឆ្នោតក្នុងសំឡេង ៤៣ ទល់នឹង ១១សំឡេង លើញត្តិប្រឆាំងរដ្ឋាភិបាលរបស់ លោក Krivokapic។ រដ្ឋាភិបាលចម្រុះម៉ុងតេណេហ្គ្រោ ដឹកនាំដោយលោកនាយករដ្ឋមន្ត្រី Zdravko Krivokapic បានដួលរលំក្រោយពីសភាបានគាំទ្រការបោះឆ្នោតដកសេចក្តីទុកចិត្ត។ ញត្តិខាងលើត្រូវបានគាំទ្រពីសមាជិកសភាចំនួន ៤៣រូប មកពីគណបក្ស Black on White និងគណបក្សប្រឆាំង។ សមាជិកសភាចំនួន ១១រូប មកពីគណបក្សកាន់អំណាច គឺគណបក្សប្រជាធិបតេយ្យម៉ុងតេណេហ្គ្រោ គណបក្សបង្រួបបង្រួមម៉ុងតេណេហ្គ្រោ និងគណបក្ស Prava Crna Gora បានបោះឆ្នោតជំទាស់នឹងញត្តិដកសេចក្តីទុកចិត្តពីរដ្ឋាភិបាលម៉ុងតេណេហ្គ្រោ។<br>រដ្ឋាភិបាលរបស់ លោក Zdravko Krivokapic បានបង្កើតឡើងកាលពីខែធ្នូ ឆ្នាំ២០២០ ដោយគណ |

| | |
|---|---|
| ម៉ុងតេណេហ្គ្រោ | បក្សរណសិរ្សប្រជាធិបតេយ្យដែលគាំទ្រស៊ែបប៊ី គណបក្សប្រជាធិបតេយ្យ និងគណបក្សចលនាសកម្មភាពកំណែទម្រង់រួម។ សមាជិកសភាមកពីក្រុមគណបក្សកាន់អំណាចដ៏ធំបំផុត គណបក្សសិរ្សប្រជាធិបតេយ្យ គណបក្សប្រជាធិបតេយ្យ និងគណបក្សប្រជាជនសង្គមនិយម បានធ្វើពហិការការបោះឆ្នោត៕<br>https://www.yenisafak.com/en/news/montenegro-govt-collapses-in-no-confidence-vote-3588956<br>*ប្រែសម្រួលដោយ ឈាវ សុផាត*<br><br>**សភាម៉ុងតេណេហ្គ្រោ ដកតំណែងប្រធានសភា ខណៈដែលក្រុមគណបក្សកាន់អំណាចទាមទារឱ្យធ្វើការជំទាស់**<br>សមាជិកសភាមកពីក្រុមគណបក្សកាន់អំណាចដ៏តូចបំផុត នៅក្នុងរដ្ឋាភិបាលចម្រុះម៉ុងតេណេហ្គ្រោ គឺគណបក្ស Black on White រួមជាមួយនឹងសមាជិកសភាគណបក្សប្រឆាំង បានដកលោក Aleksa Becic ចេញពីតំណែងប្រធានសភា។ ខណៈដែលក្រុមគណបក្សចំនួន ២ផ្សេងទៀត នៅក្នុងរដ្ឋាភិបាលបានប្រកាសជំទាស់ប្រសិនបើរដ្ឋាភិបាលថ្មីមួយ ត្រូវបានបង្កើតឡើងជាមួយនឹងគណបក្សប្រឆាំង គឺគណបក្សប្រជាធិបតេយ្យជនសង្គមនិយម(DPS)។ ការដកលោក Aleksa Becic ចេញពីតំណែងប្រធានសភា ទទួលបានការគាំទ្រពីសមាជិកសភាចំនួន ៤៣រូប មកពីគណបក្ស Black on White និងគណបក្សប្រឆាំង សមាជិកសភាចំនួន ៣៦រូប មកពីគណបក្សកាន់អំណាចកាន់អំណាចរបស់លោក គឺគណបក្សសន្តិភាពគឺជាជាតិរបស់យើង និងគណបក្សដើម្បីអនាគតម៉ុងតេណេហ្គ្រោ បានបោះឆ្នោតជំទាស់នឹងការដកតំណែងលោកប្រធានសភា។<br>លោក Boris Bogdanovic សមាជិកសភាគណបក្សសន្តិភាពគឺជាជាតិរបស់យើង បានចោទប្រកាន់ថា គណបក្ស Black on White បានក្បត់ទៅនឹងលទ្ធផលនៃការបោះឆ្នោតសភា កាលពីខែសីហា ឆ្នាំ២០២០ ដែលបានបណ្តេញគណបក្សប្រជាធិបតេយ្យជនសង្គមនិយម(DPS) ចេញពីអំណាច ដោយចោទប្រកាន់ថានោះជាការរៀបចំឡើង ដើម្បីបង្កើតរដ្ឋាភិបាលចម្រុះថ្មីមួយ ជាមួយគណបក្សប្រជាធិបតេយ្យជនសង្គមនិយម(DPS) របស់លោក Milo Djukanovic៕<br>https://balkaninsight.com/2022/02/07/montenegrin-parliament-sacks-speaker-ruling-blocs-call-for-protests/<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| អ៊ុយក្រែន | **ប្រធានសភាអ៊ុយក្រែន និងប្រធានសហភាពអន្តរសភា ជួបពិភាក្សាគ្នាអំពីបញ្ហាសន្តិសុខក្នុងប្រទេសអ៊ុយក្រែន**<br>លោក Ruslan Stefanchuk ប្រធានសភាអ៊ុយក្រែន និងលោក Duarte Pacheco ប្រធានសហភាពអន្តរសភា(IPU) ពិភាក្សាគ្នាពីកិច្ចការពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខ នៅក្នុងប្រទេសអ៊ុយក្រែន និងអំពីការគំរាមកំហែងឈ្លានពានពីសំណាក់សហព័ន្ធរុស្ស៊ី។ លោកប្រធានសភាអ៊ុយក្រែន Ruslan Stefanchuk បានថ្លែងបញ្ជាក់បែបនេះ នៅឯសន្និសីទព័ត៌មានរួមគ្នាខ្លីមួយជាមួយ លោក Duarte Pacheco។ នេះបើយោងតាមសេចក្តីរាយការណ៍របស់អ្នកឆ្លើយឆ្លងព័ត៌មានអ៊ុយក្រែន Ukrinform។<br>លោក Stefanchuk បានថ្លែងបន្តថា ចំណាប់អារម្មណ៍ពិសេសមួយបានផ្តោតទៅលើកិច្ចការ ដែល |

| | |
|---|---|
| **អ៊ុយក្រែន** | ពាក់ព័ន្ធនឹងការពង្រីកកិច្ចសន្ទនា រវាងអ៊ុយក្រែន និងសហភាពអន្តរសភា(IPU) ពាក់ព័ន្ធនឹងសន្តិសុខ បូរណភាពដែនដី និងអធិបតេយ្យភាពអ៊ុយក្រែន។ "បន្ថែមពីលើកិច្ចសន្ទនារបស់យើងក្នុងក្របខ័ណ្ឌ សហភាពអន្តរសភា លោកសូមថ្លែងអំណរគុណដល់លោកប្រធានសហភាពអន្តរសភា Duarte Pacheco សម្រាប់កិច្ចសហប្រតិបត្តិការរបស់យើង ជាមួយនឹងប្រទេសព័រទុយហ្គាល់ ដែលជាប្រទេសដែលលោកតំណាងឱ្យ (លោក Duarte Pacheco ជាជនជាតិព័រទុយហ្គាល់)"។ "វាគឺជាជំនួបមួយដ៏មានតម្លៃបំផុត ទាំងការគាំទ្រជាបុគ្គលផ្ទាល់ខ្លួន ទាំងការគាំទ្រក្នុងនាមសហភាពអន្តរសភា សម្រាប់អ៊ុយក្រែនគឺពិតជាមានសារៈសំខាន់ខ្លាំងបំផុត។ យើងសូមវាយតម្លៃខ្ពស់ និងសម្តែងការដឹងគុណបំផុតសម្រាប់ជំនួបមួយនេះ"។<br>ជាការឆ្លើយតប លោកប្រធានសហភាពអន្តរសភា(IPU) Duarte Pacheco បានអំពាវនាវឱ្យមានការគោរពដល់សិទ្ធិរបស់ប្រទេសនីមួយៗ ក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយសេរី លើអនាគតរបស់ខ្លួន លោកបានធានាអះអាងពីការត្រៀមរួចជាស្រេច ក្នុងការជួយបង្កើតកិច្ចសន្ទនារវាងអ៊ុយក្រែន និងសហព័ន្ធរុស្ស៊ី។ លោក Duarte Pacheco បានថ្លែងបន្ថែមថា "សហភាពអន្តរសភាបានត្រៀមរួចរាល់ក្នុងការជួយបង្កើតកិច្ចសន្ទនា រវាងអ៊ុយក្រែន និងសហព័ន្ធរុស្ស៊ី ដើម្បីដោះស្រាយការខ្វែងគំនិតគ្នារវាងប្រទេសទាំងពីរ"៕<br>https://menafn.com/1103653890/Ukraine-Stefanchuk-Inter-Parliamentary-Union-president-discuss-security-issues&source=246<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **អេស្តូនី** | **ប្រធានសភាអេស្តូនី៖ រាល់ការឈ្លានពានណាមួយបន្ថែមទៀតមកលើអ៊ុយក្រែន នឹងមានផលវិបាកធ្ងន់ធ្ងរសម្រាប់រុស្ស៊ី**<br>រដ្ឋធានីតាលិន៖ សហព័ន្ធរុស្ស៊ីត្រូវតែបញ្ចប់នូវសង្គ្រាម នៅភាគខាងកើតប្រទេសអ៊ុយក្រែនជាបន្ទាន់ ហើយរាល់ការប៉ុនប៉ងណាមួយ ក្នុងការបង្កើនការឈ្លានពានរបស់ខ្លួន នោះរដ្ឋាភិលបាលវិមានក្រឹមឡាំងនឹងទទួលបានផលវិបាកធ្ងន់ធ្ងរ។ លោក Juri Ratas ប្រធានសភានៃសាធារណរដ្ឋអេស្តូនីបានថ្លែងបែបនេះ នៅឯសន្និសីទសារព័ត៌មានខ្លីមួយ ជាមួយសមភាគីរបស់លោក គឺលោក Ruslan Stefanchuk ប្រធានសភាអ៊ុយក្រែននៅក្នុងទីក្រៀវនៃប្រទេសអ៊ុយក្រែន កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។ នេះបើយោងតាមអ្នកឆ្លងឆ្លងសារព័ត៌មាន Ukrinform បានធ្វើសេចក្តីរាយការណ៍។<br>លោក Juri Ratas បានថ្លែងថា "សន្តិសុខគឺជាអាទិភាពមួយនៅក្នុងពេលបច្ចុប្បន្ននេះ។ ប្រជាធិបតេយ្យក្នុងពិភពលោក គ្មានការសង្ស័យសោះឡើយថា បូរណភាពដែនដី និងឯករាជ្យភាពរបស់ប្រទេសអ៊ុយក្រែនគឺគ្មានល័ក្ខខ័ណ្ឌ"។ ការឈ្លានពានលើប្រទេសឯករាជ្យមួយ គឺជាការរំលោភបំពានទាំងស្រុងទៅនឹងច្បាប់អន្តរជាតិ។ ចំពោះសង្គ្រាមនៅក្នុងតំបន់ Donbas ដែលបានកើតមានឡើងជាង ៨ឆ្នាំមកហើយនោះ ត្រូវតែបញ្ឈប់ជាបន្ទាន់។ រាល់ការប៉ុនប៉ងណាមួយ ដើម្បីបង្កើនការឈ្លានពាននឹងទទួលបានផលវិបាកធ្ងន់ធ្ងរសម្រាប់រុស្ស៊ី។<br>លោក Juri Ratas បានថ្លែងបន្តថា ចាប់តាំងពីខ្លួនទទួលបានឯករាជ្យឡើងវិញ កាលពី៣០ឆ្នាំមុន ប្រទេសអេស្តូនី បានប្តេជ្ញាមិននៅឯកោតែឯងដាច់ខាត និងបានខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីក្លាយជាសម្ព័ន្ធមិត្ត និងភាពជាដៃគូ ដែលអាចទុកចិត្តបានក្នុងការកសាងនូវសន្តិសុខរួម។ លោក Juri Ratas |

| | |
|---|---|
| **អេស្តូនី** | បានថ្លែងបញ្ជាក់ថា "យើងបានដឹងពីសារៈសំខាន់ និងគុណតម្លៃនៃកិច្ចសហប្រតិបត្តិការរវាងប្រទេសប្រជាធិបតេយ្យ និងប្រទេសប្រជាធិបតេយ្យដូចគ្នា។ យើងសន្យាចំពោះប្រទេសអ៊ុយក្រែនថា អ្នកនឹងមិនត្រូវបានគេទុកចោលឱ្យនៅឯកោតែឯងជាដាច់ខាត"៕<br>https://menafn.com/1103658040/Ukraine-Any-further-aggression-will-have-severe-consequences-for-Russia-Estonian-parliament-speaker<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |

## IV.ទ្វីបអាមេរិក

| ប្រទេស | ខ្លឹមសារអត្ថបទព័ត៌មាន |
|---|---|
| **កូស្តារីកា** | **កូស្តារីកា បើកដំណើរការការបោះឆ្នោតប្រធានាធិបតី និងការបោះឆ្នោតជ្រើសតាំងសមាជិកសភា**<br>ការបោះឆ្នោតនៅក្នុងប្រទេសកូស្តារីកា បានធ្វើឡើងកាលពីថ្ងៃអាទិត្យ ទី០៦ ខែកុម្ភៈ ឆ្នាំ២០២២ ដើម្បីបោះឆ្នោតប្រធានាធិបតី និងបោះឆ្នោតសភានីតិកាលថ្មី សម្រាប់អាណត្តិ ៤ឆ្នាំ។ ស្ថានីយបោះឆ្នោតចំនួន ៦,៧៦៧ ទៅទូទាំងប្រទេស បានបើកនៅម៉ោង ៦៖០០នាទីព្រឹក សម្រាប់អ្នកមានសិទ្ធិបោះឆ្នោតចំនួន ៣.៥លាននាក់ និងស្ថានកុងស៊ុលចំនួន ៥២ នៅជុំវិញពិភពលោក បានបើកបម្រើជូនប្រជាជនកូស្តារីកាចំនួន ៥០,៨៣៣នាក់ ដែលបានចុះឈ្មោះបោះឆ្នោតនៅបរទេស។<br>បេក្ខជនរបស់គណបក្សសេរីកាជាតិ លោក José María Figueres បាននាំមុខនៅក្នុងការបោះឆ្នោតដោយទទួលបាន ១៧% តាមពីក្រោយដោយបេក្ខជន មកពីគណបក្សឯកភាពសង្គមគ្រិស្តសាសនិក លោកស្រី Lineth Saborio ដោយទទួលបាន ១២.៨៦% និងបេក្ខជន គណបក្សសាធារណរដ្ឋថ្មី លោក Fabricio Alvarado ទទួលបាន ១០.២៧%។ នេះបើយោងតាមការស្ទង់មតិដែលធ្វើឡើងដោយសាកលវិទ្យាល័យកូស្តារីកា ដោយបានបន្ថែមថា ប្រមាណជា ១ភាគ៣ នៃអ្នកបោះឆ្នោតនៅមិនទាន់បានសម្រេចចិត្តនៅឡើយនៅមុន ៥ថ្ងៃ នៃការបោះឆ្នោត។ មន្ត្រីកូស្តារីកា បានរំលឹកដល់អ្នកបោះឆ្នោតឱ្យប្រតិបត្តិតាមពិធីសារ អនាម័យ ដូចជា ការពាក់ម៉ាស់ និងការរក្សាគម្លាតសុវត្ថិភាពសង្គមជាដើម ដើម្បីចៀសវាងការរីករាលដាលនៃជំងឺកូវីដ-១៩៕<br>http://www.xinhuanet.com/english/20220207/3164fef6408347339d02b805c4c7a4cb/c.html<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| **ស្លូវ៉ាគី** | **គណៈកម្មាធិការការពារជាតិនៃសភាស្លូវ៉ាគី ផ្តល់អនុសាសន៍ឱ្យសភាអនុម័តកិច្ចព្រមព្រៀងយោធាជាមួយសហរដ្ឋអាម៉េរិក**<br>ប្រព័ន្ធផ្សព្វផ្សាយស្លូវ៉ាគី TA3 បានរាយការណ៍ថា គណៈកម្មាធិការការពារ និងសន្តិសុខជាតិ បានផ្តល់អនុសាសន៍ឱ្យសមាជិកសភាស្លូវ៉ាគី អនុម័តកិច្ចព្រមព្រៀងយោធារវាងស្លូវ៉ាគី និងសហរដ្ឋអាម៉េរិក។ កិច្ចពិភាក្សាសភាពាក់ព័ន្ធនឹងកិច្ចការនេះ បានធ្វើឡើងកាលពីថ្ងៃអង្គារ ទី០៨ ខែកុម្ភៈ ឆ្នាំ២០២២។ កាលពីថ្ងៃទី០៣ |

| | |
|---|---|
| ស្លូវ៉ាគី | ខែឆ្នាំដដែល កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការយោធារវាងប្រជាជាតិទាំងពីរ ត្រូវបានចុះហត្ថលេខានៅក្នុងទីក្រុងវ៉ាស៊ីនតោន ដោយលោក Antony Blinken រដ្ឋមន្ត្រីក្រសួងការបរទេសអាម៉េរិក និងលោក Jaroslav Nad រដ្ឋមន្ត្រីក្រសួងការពារជាតិស្លូវ៉ាគី។ កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅពេលដែលសភាអនុម័ត និងចុះហត្ថលេខាដោយ លោកស្រី Zuzana Caputova ប្រធានាធិបតីស្លូវ៉ាគី។<br>ប្រសិនបើកិច្ចព្រមព្រៀងខាងលើ ត្រូវបានអនុម័តនឹងអនុញ្ញាតឱ្យសហរដ្ឋអាម៉េរិក ប្រើប្រាស់អាកាសយានដ្ឋានយោធារបស់ស្លូវ៉ាគីជាច្រើន និងមូលដ្ឋានយោធានានាដទៃទៀតដោយឥតគិតថ្លៃ។ កិច្ចព្រមព្រៀងខាងលើនឹងមានសុពលភាព ១០ឆ្នាំ ជាមួយនឹងលទ្ធភាពនៃបន្តសុពលភាពជាថ្មី ឬបញ្ចប់កិច្ចព្រមព្រៀង។ តាមរយៈកិច្ចព្រមព្រៀងនេះ សហរដ្ឋអាម៉េរិកនឹងវិភាជន៍ថវិកា ១០០លានដុល្លារ សម្រាប់ការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធវិស័យការពារជាតិស្លូវ៉ាគី៕<br>https://www.urdupoint.com/en/world/slovak-committee-on-defense-recommends-parlia-1464989.html<br>*ប្រែសម្រួលដោយ ឈាវ សុផាត*<br><br>**សមាជិកសភាស្លូវ៉ាគី អនុម័តកិច្ចព្រមព្រៀងវិស័យការពារជាតិជាមួយសហរដ្ឋអាម៉េរិក**<br>រដ្ឋធានីប្រាទីស្លាវ៉ា៖ កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ សភានៃសាធារណរដ្ឋស្លូវ៉ាគីបានអនុម័តកិច្ចព្រមព្រៀងវិស័យការពារជាតិជាមួយសហរដ្ឋអាម៉េរិក។ កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិស័យការពារជាតិ ត្រូវបានសភាអនុម័តក្នុងសំឡេង ៧៩ ទល់នឹង ៦០សំឡេង នៅក្នុងសភាដែលមាន ១៥០អាសនៈ នៅក្នុងការបោះឆ្នោតមួយដែលមានការបែកបាក់គ្នា រវាងសមាជិកសភាមកពីរដ្ឋាភិបាលចម្រុះកាន់អំណាច ៤គណបក្ស និងគណបក្សប្រឆាំង។<br>កិច្ចព្រមព្រៀងខាងលើនឹងអនុញ្ញាតឱ្យសហរដ្ឋអាម៉េរិក ប្រើប្រាស់មូលដ្ឋានកងទ័ពអាកាសរបស់ប្រទេសស្លូវ៉ាគីចំនួន ២កន្លែង គឺនៅក្នុងក្រុង Malacky-Kuchyna និងនៅក្នុងក្រុង Silac សម្រាប់រយៈពេល ១០ឆ្នាំ ខណៈដែលស្លូវ៉ាគី ដែលជាសមាជិកអង្គការអូតង់( NATO ឬ OTAN) នឹងទទួលបានមកវិញនូវទឹកប្រាក់ ១០០លានដុល្លារស.រ.អា ពីសហរដ្ឋអាម៉េរិក ដើម្បីធ្វើទំនើបកម្មវិស័យការពារជាតិរបស់ខ្លួន។ គួរបញ្ជាក់ផងដែរថា កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការវិស័យការពារជាតិ ត្រូវបានចុះហត្ថលេខាដោយលោក Antony Blinken រដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាម៉េរិក និងលោក Jaroslav Nad រដ្ឋមន្ត្រីក្រសួងការពារជាតិស្លូវ៉ាគី កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ នៅក្នុងទីក្រុងវ៉ាស៊ីនតោន។<br>កិច្ចព្រមព្រៀងចាំបាច់ត្រូវមានការអនុម័តពី លោកស្រី Zuzana Caputova ប្រធានាធិបតីស្លូវ៉ាគី ខណៈដែលលោកស្រីបានបង្ហាញការគាំទ្រ ចំពោះកិច្ចព្រមព្រៀងមួយនេះ។ កិច្ចព្រមព្រៀងនេះបានធ្វើឡើងនៅចំពេលដែលមានការព្រួយបារម្ភថា សហព័ន្ធរុស្ស៊ីនឹងធ្វើការឈ្លានពានលើអ៊ុយក្រែន។ ក្នុងពេលដែលរុស្ស៊ីបានប្រមូលផ្តុំកងទ័ពជាង ១០០,០០០នាក់ នៅជិតព្រំដែនអ៊ុយក្រែន ប៉ុន្តែរុស្ស៊ីបានទទូចថា ខ្លួនគ្មានផែនការវាយប្រហារព្រំដែនអ៊ុយក្រែន-ស្លូវ៉ាគីនោះឡើយ។<br>កិច្ចព្រមព្រៀងខាងលើ ទទួលបានការគាំទ្រពីរដ្ឋាភិបាលរបស់លោកនាយករដ្ឋមន្ត្រី Eduard Heger ដែលបានថ្លែងថា កិច្ចព្រមព្រៀងនេះនឹង"ពង្រឹងដល់សន្តិសុខជាតិស្លូវ៉ាគីដ៏សំខាន់"។ ក៏ប៉ុន្តែវាត្រូវបានជំទាស់ |

| | |
|---|---|
| ស្លូវ៉ាគី | យ៉ាងខ្លាំងក្លាពីគណបក្សប្រឆាំង ដែលបានអះអាងថា កិច្ចព្រមព្រៀងនេះធ្វើឱ្យគ្រោះថ្នាក់ដល់អធិបតេយ្យភាពជាតិ និងធ្វើឱ្យមានវត្តមានជាអចិន្ត្រៃយ៍របស់កងទ័ពសហរដ្ឋអាម៉េរិក នៅលើទឹកដីស្លូវ៉ាគី និងអាចមានលទ្ធភាពនៃការដាក់ពង្រាយអាវុធប្រល័យលោកនៅក្នុងប្រទេសស្លូវ៉ាគីទៀតផង។<br>https://www.clickorlando.com/business/2022/02/09/slovakia-lawmakers-approve-defense-military-treaty-with-us/<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| អាម៉េរិក | **សភាតំណាងរាស្ត្រសហរដ្ឋអាម៉េរិក អនុម័តសេចក្តីព្រាងច្បាប់សម្រាប់រយៈពេលខ្លី ដើម្បីបញ្ចៀសការបិទរដ្ឋាភិបាល**<br>កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២ សភាតំណាងរាស្ត្រសហរដ្ឋអាម៉េរិក បានអនុម័តសេចក្តីព្រាងច្បាប់សម្រាប់រយៈពេលខ្លី ដើម្បីឱ្យរដ្ឋាភិបាលសហព័ន្ធទទួលបានថវិកា រហូតដល់ថ្ងៃទី១១ ខែមីនា ដើម្បីបញ្ចៀសការបិទរដ្ឋាភិបាល។ សភាតំណាងរាស្ត្របានបោះឆ្នោតក្នុងសំឡេង ២៧២ ទល់នឹង ១៦២ សំឡេង ដើម្បីអនុម័តសេចក្តីព្រាងច្បាប់ដែលគេស្គាល់ថា ជាសេចក្តីសម្រេចបន្ត(CR) ដើម្បីទុកពេលវេលាបន្ថែមឱ្យសមាជិកសភាសម្រេចបានកិច្ចព្រមព្រៀងមួយ ដើម្បីផ្តល់ថវិកាទៅឱ្យរដ្ឋាភិបាល សម្រាប់ពេលវេលាដែលនៅសេសសល់សម្រាប់សារពើពន្ធឆ្នាំ២០២២។<br>"ការអនុម័តលើសេចក្តីសម្រេច CR ដោយសភាតំណាងរាស្ត្រនៅថ្ងៃនេះ ឆ្លុះបញ្ចាំងនូវការសម្រេចចិត្តក្នុងសំឡេងភាគច្រើនរបស់យើង ដើម្បីធានាដំណើរការការងាររបស់រដ្ឋាភិបាល មិនត្រូវបានរារាំងដោយការបិទរដ្ឋាភិបាល"។ លោក Steny Hoyer មេដឹកនាំសំឡេងភាគច្រើន នៅក្នុងសភាតំណាងរាស្ត្រសហរដ្ឋអាម៉េរិក បានថ្លែងបែបនេះ នៅក្នុងសេចក្តីថ្លែងការណ៍មួយបន្ទាប់ពីការបោះឆ្នោតរួម។<br>http://www.xinhuanet.com/english/20220209/2063589687c34e0f9206300ee7be5996/c.html<br>*ប្រែសម្រួលដោយ ឈាវ សុផាត*<br><br>**លោកស្រី ចូលី ជំរុញរដ្ឋសភាអាម៉េរិកឱ្យប្រញាប់ចេញច្បាប់ ស្តីពីអំពើហិង្សាក្នុងគ្រួសារ**<br>(ដេលីមែល) ៖ តារាភាពយន្ត អ៊ែនជេលីណា ចូលី បានត្រឡប់មកវិមានកាពីតូលហ៊ីល (Capitol Hill) វិញកាលពីថ្ងៃពុធ ទី៩កុម្ភៈ ដោយអង្វរសមាជិកសភាអាម៉េរិកឱ្យអនុម័តវិធានការនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារជាបន្ទាន់។ នៅក្នុងសន្និសីទសារព័ត៌មានមួយ នៅវិមានកាពីតូលរបស់សហរដ្ឋអាម៉េរិក លោកស្រី ចូលី បានសម្តែងការគាំទ្រចំពោះការពិនិត្យឡើងវិញ នូវច្បាប់ដែលនឹងផ្តល់ឱ្យជនរងគ្រោះនៃការរំលោភបំពានបែបនេះ ជាមួយនឹងជំនួយផ្នែកវេជ្ជសាស្ត្រ និងផ្នែកច្បាប់ ក៏ដូចជាការគាំទ្រដល់កុមារដែលរងផលប៉ះពាល់ពីអំពើហិង្សានៅក្នុងផ្ទះ។ ផលិតករភាពយន្ត និងជាម្ចាស់ជ័យលាភីពានរង្វាន់ Academy Award រូបនេះបាននិយាយថា "ការពិតដ៏អាក្រក់គឺថា អំពើហិង្សានៅក្នុងផ្ទះបានក្លាយជារឿងធម្មតានៅក្នុងប្រទេសរបស់យើង"។<br>https://www.rasmeinews.com/archives/606817<br>*ដកស្រង់ពីសារព័ត៌មាន rasmeinews.com ដោយ ជិន ហ្គិចឡាង* |

| អាម៉េរិក | ## លោក McConnell ច្រានចោលគណៈកម្មាធិការបក្សសាធារណរដ្ឋ ដែលជំទាស់តំណាងរាស្ត្របក្ស ចំពោះការចូលរួមការស៊ើបអង្កេតពីកុបកម្មកាពីតូល<br><br>វ៉ាស៊ីនតោន៖ ព្រឹទ្ធសមាជិក លោក Mitch McConnell មេដឹកនាំក្រុមភាគតិចកាលពីថ្ងៃអង្គារ និយាយប្រឆាំងនឹងគណៈកម្មាធិការជាតិនៃគណបក្សសាធារណរដ្ឋ (RNC) សម្រាប់ការបោះឆ្នោតជំទាស់តំណាងរាស្ត្របក្ស លោកស្រី Liz Cheney និងលោក Adam Kinzinger ជុំវិញការចូលរួមរបស់អ្នកទាំង២ ក្នុងការស៊ើបអង្កេតសភាពីការវាយប្រហារនៅវិមានកាពីតូលថ្ងៃទី៦ មករា។ មេដឹកនាំក្រុមភាគតិចនៃបក្សសាធារណរដ្ឋរូបនេះ ក៏ច្រានចោលដាច់អហង្ការជុំវិញការលើកឡើងរបស់គណៈកម្មាធិការដដែល ដែលថាការស៊ើបអង្កេតរបស់សភាជា «ការធ្វើទុក្ខបុកម្នេញពលរដ្ឋសាមញ្ញក្នុងការចូលរួមធ្វើសកម្មភាពនយោបាយដោយស្របច្បាប់» ដោយនិយាយថា កុបកម្មគឺជាការបះបោរដោយហិង្សា។<br><br>លោក McConnell និយាយថា៖ «យើងបានឃើញវាកើតឡើង។ វាគឺជាការបះបោរដោយហិង្សាក្នុងគោលបំណងព្យាយាមទប់ស្កាត់ការផ្ទេរអំណាចដោយសន្តិវិធី បន្ទាប់ពីការបោះឆ្នោតដែលមានការបញ្ជាក់ត្រឹមត្រូវពីរដ្ឋបាលមួយ ទៅរដ្ឋបាលមួយ»។ ការអត្ថាធិប្បាយរបស់ លោក McConnell គឺជាការស្តីបន្ទោសដល់គណបក្សសាធារណរដ្ឋ ដែលបដិសេធពីអំពើហិង្សា ដែលកើតឡើងនៅវិមានកាពីតូលមុនការឡើងកាន់អំណាចរបស់លោកប្រធានាធិបតី ចូ បៃដិន (Joe Biden) ដែលធ្វើឱ្យមនុស្សយ៉ាងហោចណាស់ ១៥០នាក់រងរបួស ៥នាក់ស្លាប់ និងជិត ៧៥០ រងការចោទប្រកាន់ពីបទឧក្រិដ្ឋ។ ការអនុម័តការសម្រេចចិត្តជំទាស់លោកស្រី Cheney តំណាងរាស្ត្ររដ្ឋ Wyoming និងលោក Kinzinger តំណាងរាស្ត្រនៅរដ្ឋ Illinois របស់ RNC ក្នុងកិច្ចប្រជុំកាលពីថ្ងៃសុក្រសប្តាហ៍មុន ក៏ធ្វើឱ្យសមាជិកគណបក្សសាធារណរដ្ឋមួយចំនួនតូចរិះគន់ការផ្លាស់ប្តូរនេះថា ជាការរំខានផ្នែកនយោបាយ និងនាំភាពអាម៉ាស់ដល់គណបក្ស។ សេចក្តីសម្រេចនោះចែងថា RNC នឹង«លែងគាំទ្រពួកគេក្នុងនាមជាសមាជិកនៃគណបក្សសាធារណរដ្ឋទៀតហើយ»។<br><br>ប្រតិកម្មទៅលើការសម្រេចចិត្ត លោក McConnell និយាយថា៖ «តាមប្រពៃណីទស្សនៈរបស់គណៈកម្មាធិការជាតិ គឺគាំទ្រសមាជិកគណបក្សរបស់យើងទាំងអស់ ដោយមិនគិតពីតួនាទីរបស់ពួកគេលើបញ្ហាមួយចំនួនឡើយ។ ប៉ុន្តែបញ្ហា គឺថាតើ RNC គួរតែជ្រើសសមាជិកនៃគណបក្សដែលមានមតិខុសពីភាគច្រើនរបស់យើង ឬអត់នោះមិនមែនជាការងាររបស់ RNC ទេ»។ ផ្ទុយពីព្រឹទ្ធសមាជិក McConnell តំណាងរាស្ត្ររដ្ឋកាលីហ្វ័រនីញ៉ា លោក Kevin McCarthy ដែលជាមេដឹកនាំក្រុមភាគតិច ១រូប គាំទ្រសេចក្តីសម្រេចចិត្តរបស់បក្ស ដោយប្រាប់អ្នកយកព័ត៌មាន CNN ថាទង្វើនោះធ្វើឡើងដើម្បីថ្កោលទោសចំពោះការកំណត់គោលដៅរបស់គណៈកម្មាធិការសភា លើពួកអភិរក្សនិយមដែលមិនមានវត្តមានក្នុងកុបកម្មថ្ងៃទី៦ មករា ២០២១ ហើយមិនមានជាប់ពាក់ព័ន្ធអ្វីទាំងអស់ មិនថាការវាយប្រហារ ឬកិច្ចខិតខំដើម្បីបដិសេធការបោះឆ្នោតឆ្នាំ២០២០។<br><br>ការជំទាស់ដែលជំរុញដោយសម្ព័ន្ធមិត្ត របស់អតីតលោកប្រធានាធិបតី ដូណាល់ ត្រាំ (Donald Trump) មានកម្រាស់ជាង ១ទំព័រ ប៉ុន្តែវាបានធ្វើឱ្យគណបក្សសាធារណរដ្ឋ មានភាពចលាចលរួមទាំងការបង្ហាញពីភាពប្រេះស្រាំផ្ទៃក្នុងរបស់គណបក្ស។ ការជំទាស់នេះ ក៏បង្អាក់កិច្ចខិតខំប្រឹងប្រែងដោយសមាជិកសភាមកពីគណបក្សសាធារណរដ្ឋ ឱ្យបែរពីការនិយាយកូដកម្មនៅវិមានកាពីតូល ទៅផ្តោតលើអ្វីដែលពួកគេមើល |
|---|---|

| | |
|---|---|
| អាមេរិក | ឃើញថា ជាការបរាជ័យរបស់ លោក Biden និងគណបក្សប្រជាធិបតេយ្យវិញ។ តំណាងរាស្ត្រនៃរដ្ឋញូវយ៉ក ១រូប គឺលោកស្រី Elise Stefanik និយាយថា៖ «អ្នកសាធារណរដ្ឋមានភាពច្បាស់លាស់ យើងថ្កោលទោសអំពើហិង្សានៅថ្ងៃទី៦ មករា។ យើងក៏ថ្កោលទោសអំពើហិង្សាក្នុងឆ្នាំ២០២០ផងដែរ ដោយសារឧក្រិដ្ឋជនហិង្សាបានវាយប្រហារអគារសហព័ន្ធ រួមទាំងផ្នែកខ្លះនៃរដ្ឋធានីវ៉ាស៊ីនតោន-ឌីស៊ី»។<br>លោកស្រីនិយាយបែបនេះ ដោយសំដៅលើអំពើហិង្សាដែលកើតឡើង ក្នុងបាតុកម្មទាមទារឱ្យបញ្ឈប់ការរើសអើងពូជសាសន៍ ពណ៌សម្បុរ ដែលធ្វើឡើងបន្ទាប់ពីការស្លាប់របស់ លោក George Floyd ដោយបន្ថែមថា៖ «យើងជឿថាគណៈកម្មការ ៦មករា គឺជាល្បែងនយោបាយអំពីការដាក់ទណ្ឌកម្មលើក្រុមប្រឆាំង»។ សមាជិកគណបក្សសាធារណរដ្ឋមួយចំនួន ការពារសេចក្ដីសម្រេចចិត្តចំពោះ លោកស្រី Cheney និងលោក Kinzinger ដោយកត់សម្គាល់ថា វាបង្កប់នូវទស្សនៈរបស់គណបក្ស អំពីអ្វីដែលកើតឡើងនៅថ្ងៃទី៦ មករា។ លោក Josh Hawley សមាជិកព្រឹទ្ធសភាមកពីរដ្ឋ Missouri នៃបក្សសាធារណរដ្ឋនិយាយថា៖ «ការបោះឆ្នោត RNC ឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកបោះឆ្នោតភាគច្រើននៃគណបក្សសាធារណរដ្ឋ»។ យ៉ាងណាមិញ ព្រឹទ្ធសមាជិក Mitt Romney មកពីគណបក្សសាធារណរដ្ឋនៃរដ្ឋ Utah ដែលចាត់ទុកការសម្រេចចិត្តថាជាការអាម៉ាស់កាលពីថ្ងៃសុក្រ មុនការបោះឆ្នោតរបស់គណបក្សបាននិយាយថា៖ «អ្វីដែលគណបក្សខ្ញុំធ្វើដូចការល្ងីល្ងើនោះ មិនអាចជួយយើងបាននោះទេ»។<br>សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិនៃគណបក្សសាធារណរដ្ឋ ដំបូងឡើយចាប់ផ្ដើមជាកិច្ចខិតខំប្រឹងប្រែងដើម្បីបណ្ដេញ លោកស្រី Cheney និងលោក Kinzinger ដែលធ្លាប់បោះឆ្នោតឱ្យទម្លាក់លោក ត្រាំ ចេញពីដំណែង ចេញពីសន្និសីទសភានៃបក្សសាធារណរដ្ឋ។ ប៉ុន្តែសមាជិកគណៈកម្មាធិការសម្រេចចិត្តប្រឆាំងនឹងការអំពាវនាវឱ្យមានចំណាត់ការបែបនេះ ហើយជំនួសមកវិញដោយជាការជំទាស់។ សេចក្ដីព្រាងដំបូងថ្កោលទោសតំណាងរាស្ត្រទាំង២ ចំពោះការចូលរួមក្នុង «ការធ្វើទុក្ខបុកម្នេញដឹកនាំដោយគណបក្សប្រជាធិបតេយ្យលើប្រជាពលរដ្ឋសាមញ្ញ ដែលចូលរួមក្នុងសកម្មភាពនយោបាយអហិង្សា និងផ្លូវច្បាប់។ ប៉ុន្តែចុងក្រោយពាក្យអហិង្សា និងផ្លូវច្បាប់ ត្រូវបានដកចេញវិញ ហើយជំនួសដោយ«ស្របច្បាប់»។ នេះបើតាមការចុះផ្សាយរបស់កាសែតញូវយ៉កថាមស៍ ដែលស្រង់សម្ដីជាអនាមិកពីប្រភពដែលដឹងពីព័ត៌មាននេះច្បាស់។ សមាជិកមួយចំនួននៃគណៈកម្មាធិការអះអាងថា ពាក្យ«ពលរដ្ឋសាមញ្ញ» និង«ការចូលរួមធ្វើនយោបាយដោយស្របច្បាប់» សំដៅទៅលើមនុស្សមួយចំនួនដូចជា អ្នកស្រី Kathy Berden សមាជិកគណៈកម្មាធិការមកពីរដ្ឋ Michigan ដែលចុះហត្ថលេខាលើវិញ្ញាបនបត្រខុសច្បាប់អះអាងថា លោក ត្រាំ ឈ្នះឆ្នោត។<br>សមាជិកគណៈកម្មាធិការជាតិដដែលគិតថា លោកស្រី Berden ជាជនរងគ្រោះស្លូតត្រង់នៃការស៊ើបអង្កេតប្រកបដោយភាពហួសចិត្តមួយ ដោយកត់សម្គាល់ថា លោកស្រីមានវ័យចំណាស់ និងជាស្ត្រីមេម៉ាយ។ យ៉ាងណាមិញ លោកស្រីត្រូវបានគណៈកម្មាធិការស៊ើបអង្កេត ការវាយប្រហារវិមានកាពីតូលចេញដីកាកោះហៅកាលពីខែមករានេះ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងរកថា អ្នកណាជាអ្នករៀបចំការជំរុញផែនការដែលជាឧក្រិដ្ឋកម្មនេះ៕<br>https://www.postkhmer.com/international/2022-02-11-1350-231543.html<br>*ដកស្រង់ពីសារព័ត៌មាន postkhmer.com ដោយ ជិន ហ្គិចឡាង* |

## V.អន្តរការអន្តរសភា

| | **ខ្លឹមសារអត្ថបទព័ត៌មាន** |
|---|---|
| ក្រុមប្រឹក្សាអន្តរសភា | **ក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការអន្តរសភាកាហ្សាក់ស្ថាន-អ៊ូសបេគីស្ថាន ត្រូវបានបង្កើតឡើង**<br>ក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការអន្តរសភាមួយ រវាងកាហ្សាក់ស្ថាន និងអ៊ូសបេគីស្ថាន ត្រូវបានបង្កើតឡើង កាលពីថ្ងៃពុធ ទី០៩ ខែកុម្ភៈ ឆ្នាំ២០២២។ លោក Yerlan Koshanov ប្រធានសភាកាហ្សាក់ស្ថាន និងលោក Nurdinjon Ismailov ប្រធានសភានីតិប្បញ្ញត្តិ(សភាជាន់ទាប) អ៊ូសបេគីស្ថាន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីពីការបង្កើតក្រុមប្រឹក្សាកិច្ចសហប្រតិបត្តិការអន្តរសភា។ ថ្លែងក្រោយពិធីចុះហត្ថលេខានៅក្នុងប្រទេសកាហ្សាក់ស្ថានរួច លោក Yerlan Koshanov បានឱ្យដឹងថា ក្រុមប្រឹក្សានេះត្រូវបានបង្កើតឡើងក្រោមការចុះហត្ថលេខាព្រមព្រៀង រវាងមេដឹកនាំនៃប្រទេសទាំងពីរ និងមានចរិតលក្ខណៈជាប្រវត្តិសាស្រ្តមួយ។ អន្តរកម្មរវាងសភានៃប្រទេសទាំងពីរនឹងឈានដល់កម្រិតថ្មីមួយ ជាមួយនឹងការបង្កើតក្រុមប្រឹក្សាខាងលើនេះ លោក Yerlan Koshanov បានធ្វើការកត់សម្គាល់បែបនេះ និងបានប្រគល់មេដាយជាតិកាហ្សាក់ស្ថានជូនលោក Nurdinjon Ismailov សម្រាប់ការរួមចំណែករបស់លោក ក្នុងការពង្រឹងមិត្តភាព និងកិច្ចសហប្រតិបត្តិការទ្វេភាគី។ លោក Nurdinjon Ismailov បានថ្លែងអំណរគុណចំពោះការផ្តល់មេដាយជាតិ និងបានសង្កត់ធ្ងន់ថា ការបង្កើនកិច្ចសន្ទនារវាងសភានៃប្រទេសទាំងពីរនឹងបម្រើដោយផ្ទាល់ ដល់ការពង្រីកសក្តានុពលនយោបាយ សេដ្ឋកិច្ច និងវប្បធម៌នៃកិច្ចសហប្រតិបត្តិការ និងដើម្បីពង្រឹងចំណងទាក់ទងនៃមិត្តភាពរវាងប្រជាជនកាហ្សាក់ស្ថាន និងប្រជាជនអ៊ូសបេគីស្ថាន៕<br>https://www.yenisafak.com/en/world/kazakhstan-uzbekistan-inter-parliamentary-cooperation-council-established-3589185<br>*ប្រែសម្រួលដោយ ឈាវ សុផាត* |
| សហភាពអឺរ៉ុប | **ការមិនមូលមតិគ្នារបស់សហភាពអឺរ៉ុប ជាបញ្ហានៅក្នុងការដាក់ទណ្ឌកម្មរុស្ស៊ីជុំវិញវិបត្តិអ៊ុយក្រែន**<br>សហភាពអឺរ៉ុប គំរាមដាក់ទណ្ឌកម្មសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ខ្លាំងជាងអ្វីដែលខ្លួនធ្លាប់ដាក់ក្នុងឆ្នាំ២០១៤ ប្រឆាំងនឹងរុស្ស៊ី ដោយសង្ឃឹមថាអាវុធគ្មានផ្សេងនេះ នឹងរារាំងលោកប្រធានាធិបតី វ្លាឌីមៀរ ពូទីន (Vladimir Putin) ដែលត្រូវបានរាយការណ៍ថា កំពុងប្រមូលផ្តុំកងទ័ពជាង ១សែននាក់ នៅតាមព្រំដែនពីការឈ្លានពានអ៊ុយក្រែន។ ប៉ុន្តែអ្នកវិភាគថា សហភាពអឺរ៉ុបប្រឈមមុខនឹងឧបសគ្គយ៉ាងខ្លាំង នៅពេលអនុវត្តទណ្ឌកម្មដោយសូម្បីតែពេលចាប់ផ្តើមប្លុកនេះ ក៏ត្រូវការឯកភាពពីរដ្ឋសមាជិកទាំងចំនួន២៧ ដែលភាគច្រើនមានទំនាក់ទំនងសេដ្ឋកិច្ចស៊ីជម្រៅជាមួយរុស្ស៊ីសិន។ ម្យ៉ាងទៀតប្លុកនេះក៏រងការចោទប្រកាន់ថា មានភាពរអាក់រអួលនៅពេលនិយាយពីការអនុវត្តកម្មវិធីដាក់ទណ្ឌកម្ម ឱ្យបានឆាប់រហ័សដោយមានទណ្ឌកម្មលើបេឡារុសជាគំរូ។ |

**សហភាព អឺរ៉ុប**

អ្នកជំនាញមួយចំនួននិយាយថា ការពឹងពាក់គ្នាទៅវិញទៅមកនៃសេដ្ឋកិច្ចរុស្ស៊ី និងសហភាពអឺរ៉ុប ធ្វើឱ្យប្លុកនេះមានការលំបាកក្នុងការធ្វើបាបសេដ្ឋកិច្ចរុស្ស៊ី ដោយគ្មានការឈឺចាប់ខ្លួនឯង។ អ្នកស្រី Anastasiya Shapochkina សាស្ត្រាចារ្យភូមិសាស្ត្រនយោបាយនៅវិទ្យាស្ថាន Sciences Po និយាយថា៖ «សហភាពអឺរ៉ុបនឹងធ្វើឱ្យខ្លួនឯងឈឺចាប់ ដោយសារការដាក់ទណ្ឌកម្មលើរុស្ស៊ី ពីព្រោះក្រុមហ៊ុនអឺរ៉ុបដូចជាក្រុមហ៊ុនសាំង Total ក្រុមហ៊ុនផ្គត់ផ្គង់សម្ភារប្រើប្រាស់ Engie ក្រុមហ៊ុននុយក្លេអ៊ែរ Areva និងក្រុមហ៊ុនចំណីអាហារ Dan one ជាដើមនោះ បានវិនិយោគយ៉ាងច្រើន នៅក្នុងប្រទេសរុស្ស៊ីអស់ជាច្រើនទសវត្សរ៍មកហើយ ហើយពួកគេនឹងរងទុក្ខប្រសិនបើទំនាក់ទំនងត្រូវបានកាត់ផ្តាច់»។

យ៉ាងណាមិញក្រុមមន្ត្រីសហភាពអឺរ៉ុបនិយាយថា ខ្លួនមានសុទិដ្ឋិនិយមដោយថា ក្រុមរដ្ឋាភិបាលរបស់ខ្លួនត្រៀមខ្លួនរួចជាស្រេច ដើម្បីទទួលយកផលវិបាក ដែលបណ្តាលមកពីការដាក់ទណ្ឌកម្មលើវិស័យហិរញ្ញវត្ថុថាមពល និងឧស្សាហកម្មបច្ចេកវិទ្យាខ្ពស់របស់ខ្លួនលើរុស្ស៊ី។ លោកស្រី Ursula von der Leyen ប្រធានគណៈកម្មការអឺរ៉ុបនិយាយប្រាប់កាសែត Financial Times កាលពីសប្តាហ៍មុនថា៖ «យើងទាំងអស់គ្នាសង្ឃឹមថា ទំនាក់ទំនងការទូតនឹងទទួលបានជោគជ័យ។ ប៉ុន្តែយើងក៏ដឹងផងដែរថា យើងត្រៀមខ្លួនរួចរាល់នៅពេលដែលត្រូវប្រើកញ្ចប់ទណ្ឌកម្មដ៏រឹងមាំនេះហើយ»។

លោក Edward Fishman មន្ត្រីសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌល សម្រាប់សន្តិសុខអាមេរិកថ្មីបាននិយាយថា៖ «វាមានសារៈសំខាន់ណាស់ដែលលោកខាងលិច រក្សាការរួបរួមរបស់ខ្លួនក្នុងការប្រឈមមុខនឹងការគំរាមកំហែងពីប្រទេសរុស្ស៊ី ហើយនោះមានន័យថា គ្រប់សមាជិកនៃសហភាពអឺរ៉ុបត្រូវឈរលើគោលជំហររួមមួយ»។ លោកបន្តថា៖ «ឥឡូវនេះរាល់សញ្ញាទាំងអស់ពីមេដឹកនាំអាមេរិក និងអឺរ៉ុប ចង្អុលទៅកម្រិតនៃការឯកភាពគ្នាគួរឱ្យកត់សម្គាល់ លើកិច្ចខិតខំប្រឹងប្រែងដាក់ទណ្ឌកម្ម»។ ទន្ទឹមជាមួយគ្នានោះ អ្នករិះគន់និយាយថា គំរូមួយនៃទណ្ឌកម្មដែលប្លុកអឺរ៉ុបធ្លាប់ដាក់លើរដ្ឋាភិបាលបេឡារុស គឺបង្កប់នូវភាពទន់ខ្សោយ និងដែនកំណត់ជាច្រើនរបស់ក្របខ័ណ្ឌសហភាពអឺរ៉ុប។ ទណ្ឌកម្មផ្សេងៗទៅលើបេឡារុស រួមទាំងលើវិស័យហិរញ្ញវត្ថុត្រូវបានព្រមព្រៀងគ្នាជិត ១ឆ្នាំ បន្ទាប់ពីលោកប្រធានាធិបតី Alexander Lukashenko ចាប់ផ្តើមបង្ក្រាបក្រុមប្រឆាំង។

មន្ត្រីសហភាពអឺរ៉ុបម្នាក់ និយាយជាអនាមិកប្រាប់កាសែត Financial Times ថា៖ «វាមិនងាយស្រួលទេសម្រាប់គណៈកម្មការ នៅពេលដែលពួកគេមានរដ្ឋជាសមាជិកមើលពីអំរែករបស់ខ្លួន ពេលនិយាយពីការដាក់ទណ្ឌកម្ម។ វាធ្វើឱ្យយឺតយ៉ាវ និងធ្វើឱ្យលទ្ធផលធ្លាក់ចុះ។ លទ្ធផលមិនមែនជាភាគបែងរួមខ្ពស់បំផុតទេ ប៉ុន្តែជាកម្រិតទាបបំផុតនៃអ្វីដែលរដ្ឋសមាជិកអាចធ្វើបាន»។ គណៈកម្មការប្លុកការពារការដាក់ទណ្ឌកម្មជាច្រើនជុំលើបេឡារុស ដោយទទូចថាវាអាចឡើង ឬចុះក្រោម អាស្រ័យលើអាកប្បកិរិយារបស់រដ្ឋាភិបាលក្រុងមីនស្ក៍។ ប៉ុន្តែមានសំណួរស្រដៀងគ្នានេះ ជុំវិញប្រសិទ្ធភាពនៃទណ្ឌកម្មឆ្នាំ២០១៤ របស់សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបលើរុស្ស៊ី។

ការដាក់ទណ្ឌកម្មនាពេលនោះ រួមមានការរឹតបន្តឹងលើក្រុមហ៊ុន និងបុគ្គល ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយរដ្ឋាភិបាលរុស្ស៊ី ក៏ដូចជាវិធានការទាក់ទងនឹងវិស័យការពារជាតិ ថាមពល និងហិរញ្ញវត្ថុ។ ប៉ុន្តែខណៈដែលអ្នកការទូតលោកខាងលិចមួយចំនួនជឿថា ទណ្ឌកម្មនោះធ្វើឱ្យ លោក Putin មិនពង្រីក

**សហភាព អឺរ៉ុប**

ខ្លួននៅតំបន់ Donbas របស់អ៊ុយក្រែនដែលក្រុមផ្ដាច់ខ្លួនរឹបអូស វានៅតែបរាជ័យក្នុងការបង្ខំរុស្ស៊ីចេញពីតំបន់គ្រីមា ដែលរុស្ស៊ីរាប់ចូលថាជាទឹកដីខ្លួន។ ម្យ៉ាងវិញទៀតទណ្ឌកម្មឆ្នាំ២០១៤ ក៏មិនសូវជាមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ចរបស់រុស្ស៊ី។ យោងតាមរបាយការណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ក្នុងឆ្នាំ២០១៩ កំណើនប្រចាំឆ្នាំរបស់រុស្ស៊ីពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨ ធ្លាក់ចុះតិចជាងការរំពឹងទុកមុនចំនួន ០,២ ភាគរយប៉ុណ្ណោះ។

ទោះបីយ៉ាងណា ក្រុមមន្ត្រីសហភាពអឺរ៉ុបនិយាយថា ភាពខុសគ្នាដ៏សំខាន់រវាងផែនការទណ្ឌកម្មបច្ចុប្បន្ន និងឆ្នាំ២០១៤ គឺការងារលម្អិតរវាងសម្ព័ន្ធមិត្តដែលធ្វើទាន់ពេល និងសកម្ម ដោយសង្ឃឹមថាវានឹងរារាំងលោក Putin ពីការធ្វើសកម្មភាពអរិភាពនៅអ៊ុយក្រែន។ ការពិភាក្សាបែបស៊ីជម្រៅមួយរវាងសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប ជុំវិញការដាក់ទណ្ឌកម្មលើរុស្ស៊ី ឥឡូវនេះបានដំណើរការអស់រយៈពេល ៣ខែមកហើយ។ អ្នកបង្កើតគោលនយោបាយទាំងសងខាងសង្កត់ធ្ងន់ថា គោលដៅគឺមិនមែនដើម្បីរកទណ្ឌកម្មដូចគ្នាប្រឆាំងនឹងរុស្ស៊ីនោះទេ ប៉ុន្តែដើម្បីបង្កើតវិធីសាស្ត្រសម្របសម្រួល ផ្ទុយទៅនឹងព្រឹត្តិការណ៍ដ៏ច្របូកច្របល់របស់រដ្ឋបាល Trump ដែលដាក់ទណ្ឌកម្មលើក្រុមហ៊ុនអាលុយមីញ៉ូមយក្ស Rusal ក្នុងឆ្នាំ២០១៨ ដោយមិនពិគ្រោះជាមួយសម្ព័ន្ធមិត្ត។

កញ្ចប់ទណ្ឌកម្មថ្មីនឹងគ្របដណ្ដប់លើថាមពល ធនាគារ ក្រុមហ៊ុនបច្ចេកវិទ្យាខ្ពស់ និងឥស្សរជននយោបាយ ដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយ លោក Putin ដោយក្រុមលោកខាងលិចមានឆន្ទៈធ្វើឱ្យធនាគាររុស្ស៊ី រងផលប៉ះពាល់ធ្ងន់ធ្ងរជាងកាលពីឆ្នាំ២០១៤។ អ្នកការទូតលោកខាងលិចនិយាយថា ក្រុមហ៊ុន Sberbank ក្រុមហ៊ុន VTB ក្រុមហ៊ុន Gazprombank ក្រុមហ៊ុន Alfa-Bank និងមូលនិធិវិនិយោគផ្ទាល់របស់រុស្ស៊ីទាំងអស់ កំពុងស្ថិតនៅក្រោមការពិចារណា ចំពោះការដាក់ទណ្ឌកម្មលើស្ថាប័នហិរញ្ញវត្ថុធំបំផុតរបស់រុស្ស៊ីនាពេលនេះ៕

*ភ្នំពេញប៉ុស្ដិ៍ ទំព័រទី១៧, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២*

## ទិសដៅការងារថ្មីរបស់សហភាពអន្តរសភា ត្រូវបានចូលជាធរមានជាស្ថាពរ

យុទ្ធសាស្ត្ររបស់សហភាពអន្តរសភា សម្រាប់ឆ្នាំ២០២២-២០២៦ (The 2022-2026 IPU Strategy) ត្រូវបានអនុម័តជាឯកច្ឆន្ទ ដោយសភាជាសមាជិកសហភាពអន្តរសភា ក្នុងសន្និបាតលើកទី១៤៣ របស់សហភាពអន្តរសភាក្នុងខែវិច្ឆិកា ឆ្នាំ២០២១ ក្នុងរាជធានីម៉ាឌ្រីទព្រះរាជាណាចក្រអេស្ប៉ាញ។ យុទ្ធសាស្ត្រថ្មីនេះ គឺជាផែនទីផ្លូវសម្រាប់រយៈពេល៥ឆ្នាំខាងមុខ ជាមួយនឹងការចង្អុលបង្ហាញថ្មី ពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពសភាដើម្បីសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍ។ យុទ្ធសាស្ត្រថ្មីនេះក៏ផ្ដល់ផងដែរនូវមូលដ្ឋានការងារថ្មីៗ សម្រាប់សហភាពអន្តរសភាគាំទ្រសភានៃប្រទេសនានា ក្នុងផ្នែកជាច្រើនបន្ថែមទៀត តួយ៉ាងដូចជាផ្នែកការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាដើម។

យុទ្ធសាស្ត្រថ្មីនេះ កើតចេញពីការពិភាក្សាយ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធជាច្រើន ក្នុងរយៈពេលជាង១៣ទសវត្សរ៍នៃការចាប់បដិសន្ធិរបស់សហភាពអន្តរសភា។ ក្នុងរយៈពេលជាង១២ខែ ក្នុងឆ្នាំ២០២១

| | |
|---|---|
| **សហភាពអឺរ៉ុប** | ក្រោមការចង្អុលបង្ហាញរបស់ លោក Duarte Pacheco ប្រធានសភាអន្តរសភា និងរបស់គណៈកម្មាធិការប្រតិបត្តិសហភាពអន្តរសភា បានធ្វើការពិភាក្សាជាមួយផ្នែកពាក់ព័ន្ធជាច្រើន ដែលរួមមានសមាជិកសភារាប់រយនាក់ មន្ត្រីសភា ដៃគូរបស់សហភាពអន្តរសភា និងសង្គមស៊ីវិល។ យោបល់ដែលបានមកពីកិច្ចពិភាក្សាបានគូសបញ្ជាក់ថា សហភាពអន្តរសភាគួរបន្តពង្រឹងសមត្ថភាពសភានៃប្រទេសនានា បន្តជួយផ្សារភ្ជាប់សភានៃប្រទេសនានា និងគួរបន្តគាំទ្រសមាជិកសភានៅទូទាំងពិភពលោក។ លើសពីនេះទៅទៀត សភាជាសមាជិកសហភាពអន្តរសភា ក៏បានគូសបញ្ជាក់ផងថា វាគឺជារឿងចាំបាច់ដែលសភានៃប្រទេសទាំងអស់ត្រូវធ្វើការរួមគ្នា និងសហការគ្នាជាមួយភាគីពាក់ព័ន្ធ ដើម្បីនាំមកនូវការផ្លាស់ប្ដូរ។ ជាលទ្ធផលកម្មវត្ថុដ៏ចម្បងបំផុតរបស់សហភាពអន្តរសភានៅពេលនេះ គឺការអភិវឌ្ឍនូវ "ប្រព័ន្ធបរិស្ថានសភាសម្រាប់លទ្ធិប្រជាធិបតេយ្យសម្រាប់មនុស្សគ្រប់រូប (Parliamentary ecosy stems for democracy for everyone)។<br>វិធីសាស្ត្រប្រព័ន្ធបរិស្ថានខាងលើ បានផ្លាស់ប្ដូរឥរិយាបថរបស់សហភាពអន្តរសភា ពីការសម្លឹងឃើញសភានីមួយៗជាស្ថាប័នដោយឡែក ទៅជាការសម្លឹងឃើញទូលំទូលាយជាងមុន ដែលនោះគឺការត្រូវសម្លឹងមើលផងដែរដល់តួអង្គ និងកត្តាជំរុញផ្សេងៗ ដែលមានឥទ្ធិពលលើសភា ដូចជារដ្ឋាភិបាល គណបក្សនយោបាយ ស្ថានប័នស្រាវស្រាវ ភាពជាដៃគូជាមួយអង្គការសហប្រជាជាតិ និងប្រព័ន្ធផ្សព្វផ្សាយ។ យុទ្ធសាស្ត្រថ្មីនេះ បានផ្ដោតលើកម្មវត្ថុប្រទាក់ក្រឡាគ្នាចំនួន៥គឺៈ (១)កសាងសភាដែលមានប្រសិទ្ធភាព និងមានអំណាច (២)លើកកម្ពស់ភាពជាតំណាង និងការចូលរួមទូលំទូលាយនៅក្នុងសភា (៣)ជួយគាំទ្រសភាឱ្យមានសមត្ថភាពងើបឡើងវិញឆាប់រហ័ស នៅពេលជួបបញ្ហា និង(៤)ដើរតួជាកាតាលីករនៃការជំរុញឱ្យសភាធ្វើសកម្មភាពរួមគ្នា និង(៥)ពង្រឹងគណនេយ្យភាពរបស់សហភាពអន្តរសភា។<br>កម្មវត្ថុនៃការពង្រឹងសមត្ថភាពសភា ឱ្យងើបឡើងវិញឆាប់រហ័ស (Resilience) នៅពេលជួបបញ្ហា និងការពង្រឹងគណនេយ្យភាព គឺជាការឆ្លើយតបដោយផ្ទាល់ទៅនឹងជំងឺឆ្លងរាតត្បាតកូវីដ-១៩ ដែលកំពុងកើតមានបច្ចុប្បន្ន។ មានវិធីសាស្ត្រជាច្រើនត្រូវបានបង្ហាញនៅក្នុងកម្មវត្ថុនេះ ដើម្បីជួយឱ្យសភាអាចសម្របខ្លួន និងមានការច្នៃប្រឌិត ដើម្បីបន្តកិច្ចការរបស់ខ្លួនក្នុងបុព្វហេតុនៃការបម្រើឱ្យបានឥតខ្ចោះ ចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានបោះឆ្នោតរបស់ខ្លួន។ កម្មវត្ថុទាំង៥ នៅក្នុងយុទ្ធសាស្ត្ររបស់សហភាពអន្តរសភាឆ្នាំ២០២២-២០២៦ គឺជាផែនទីផ្លូវសម្រាប់សហភាពអន្តរសភា ក្នុងការជួយដល់សភានៃប្រទេសនានា ឱ្យមានការផ្លាស់ប្ដូរដែលជាលទ្ធផលសភាអស់នោះ នឹងមានសមត្ថភាពខ្ពស់ក្នុងការដោះស្រាយបញ្ហាមួយចំនួន ដែលពិភពលោកកំពុងប្រឈម។ នៅក្នុងយុទ្ធសាស្ត្រនេះ មានការរៀបរាប់អំពីបញ្ហានានា ដែលពិភពលោកកំពុងប្រឈមដូចជាៈ បញ្ហាបម្រែបម្រួលអាកាសធាតុ, បញ្ហាប្រជាធិបតេយ្យ សមភាពយេនឌ័រ និងការចូលរួមរបស់យុវជន, និងការអភិវឌ្ឍប្រកបដោយចីរភាព។<br>បញ្ហាបម្រែបម្រួលអាកាសធាតុ ត្រូវបានសភាជាសមាជិកសហភាពអន្តរសភា ចាត់ទុកជាបញ្ហាដ៏សំខាន់មួយ ក្នុងចំណោមបញ្ហាដ៏សំខាន់ជាច្រើន ដែលសហភាពអន្តរសភាគួរតែផ្ដោតយកចិត្តទុកដាក់ជាបន្ទាន់។ យុទ្ធសាស្ត្រថ្មីរបស់សហភាពអន្តរសភា បានផ្ដល់នូវក្របខ័ណ្ឌមួយសម្រាប់សហភាពអន្តរសភាដើម្បីគាំទ្រសភានៃប្រទេសនានា ក្នុងការធ្វើឱ្យមានវឌ្ឍនភាពនៃការអនុវត្តកិច្ចព្រមព្រៀងទីក្រុងប៉ារីស (Paris Agreement) ស្ដីពីបម្រែបម្រួលអាកាសធាតុ និងការអនុវត្តសន្ធិសញ្ញាផ្សេងៗទៀត ស្ដីពីអាកាសធាតុ, ក្នុង |

| | |
|---|---|
| សហភាពអឺរ៉ុប | ការបង្កើនល្បឿនកាត់បន្ថយការបំភាយឧស្ម័នកាបូនក្នុងបរិយាកាស, ក្នុងការកាត់បន្ថយការបំភាយឧស្ម័នកាបូនដែលកើតឡើងចេញពីសកម្មភាពការងាររបស់សភាផ្ទាល់តែម្តង។<br><br><br>https://www.ipu.org/resources/publications/about-ipu/2022-01/strategy-2022-2026<br>*ប្រែសម្រួលដោយ មាស តូនី* |

## VI.ព័ត៌មានអន្តរជាតិសំខាន់ៗ

| ប្រទេស | ខ្លឹមសារអត្ថបទព័ត៌មាន |
|---|---|
| អត្ថបទវិភាគ | **អ្នកវិភាគ៖ ការសម្លាប់មេដឹកនាំនៃក្រុមរដ្ឋអ៊ីស្លាម IS មិនមែនជាការបាត់បង់របស់ក្រុមនោះទេ**<br>ក្រោយដឹកនាំក្រុមរដ្ឋអ៊ីស្លាមអស់រយៈពេលជាង ២ឆ្នាំ លោក Abu Ibrahim al-Hashimi al-Qurayshi ដែលខំកំបាំងខ្លួនពីខ្មាំង ទីបំផុតក៏ស្លាប់ក្នុងអំឡុងការវាយឆ្មក់របស់យោធាអាមេរិក លើផ្ទះរបស់លោកនៅភាគខាងជើងនៃប្រទេសស៊ីរីកាលពីសប្តាហ៍មុន។ មន្ត្រីសហរដ្ឋអាមេរិកនិយាយថា មេដឹកនាំក្រុមជ្រុលនិយមវ័យ ៤៥ឆ្នាំរូបនេះ បានបំផ្ទុះខ្លួនឯងដែលសម្លាប់ទាំងសមាជិកក្រុមគ្រួសាររបស់លោក រួមមានទាំងកូនៗ និងប្រពន្ធ។ ប្រតិបត្តិការកាលពីថ្ងៃពុធ ដែលសម្លាប់មនុស្ស ១៣នាក់ រួមទាំងក្មេងៗ ៦នាក់នេះ គឺជាការវាយឆ្មក់ដ៏ធំបំផុតរបស់យោធាសហរដ្ឋអាមេរិកនៅស៊ីរី ចាប់តាំងពីប្រតិបត្តិការសម្លាប់មេដឹកនាំរដ្ឋអ៊ីស្លាមចាស់ លោក Abu Bakral-Bagh- dadi ក្នុងឆ្នាំ២០១៩។<br>មេដឹកនាំសហរដ្ឋអាមេរិកសាទរ ចំពោះការស្លាប់របស់ លោក al- Qurayshi ដែលជាអ្នកស្នងតំណែងបន្តពី លោក al-Baghdadi ថាជាមុខរបួសថ្មីសម្រាប់អង្គនៃពួកជ្រុលនិយម IS។ ប៉ុន្តែក្រុមអ្នកវិភាគខាងភេរវកម្ម ព្រមានការសម្លាប់មេដឹកនាំម្នាក់ទៀតនេះ នឹងមិនលុបបំបាត់វត្តមានរបស់ក្រុម ដែលមានសមាជិកបែកខ្ញែកគ្នា និងរៀបចំផែនការវាយប្រហារនៅក្នុងតំបន់នោះទេ។ អ្នកស្រី Pratibha Thaker បំផ្លាញខ្លាំងបានដែរ។ នាយកវិចារណកថាប្រចាំមជ្ឈិមបូព៌ា និងអាហ្វ្រិក នៅអង្គភាពស៊ើបការណ៍សេដ្ឋកិច្ចនិយាយថា៖ [«វាគឺជាការវាយប្រហារដ៏ឈឺចាប់មួយទៀត ចំពោះអង្គការរដ្ឋអ៊ីស្លាម IS]។ ប៉ុន្តែខ្ញុំគិតថា មនុស្សគ្រប់គ្នាកំពុងឆ្ងល់យ៉ាងខ្លាំងថា តើការសម្លាប់មេដឹកនាំកំពូលពិតជាមានសារៈសំខាន់ប៉ុណ្ណា ចាប់តាំងពីអង្គការនេះផ្លាស់ប្តូរទៅរកការគ្រប់គ្រងបែបវិមជ្ឈការ»។ សហរដ្ឋអាមេរិកបានចំណាយថវិកាយ៉ាងសន្ធឹកសន្ធាប់ក្នុងការសម្លាប់មេដឹកនាំអង្គការភេរវកម្មដូចជា លោក Osama bin Laden ស្ថាបនិកអាល់កៃដា |

| | |
|---|---|
| **អត្ថបទវិភាគ** | លោក Abu Musabal Zar-qawi មេដឹកនាំក្រុមអាល់កៃដា នៅអ៊ីរ៉ាក់ និងលោក al-Bagh- dadi ជាដើម។<br>ប៉ុន្តែខណៈដែលការវាយប្រហារបែបនេះ ជាសមិទ្ធផលធំរបស់អាមេរិក ក្រុមដែលខ្លួនព្យាយាមគ្រប់គ្រងនេះ តែលេចចេញក្នុងទម្រង់ថ្មី ឬគ្រាន់តែផ្លាស់ប្តូរមេដឹកនាំជាដើម។ ក្រុមអ្នកជំនាញខាងភេរវកម្មនិយាយថា ក្រុមរដ្ឋអ៊ីស្លាមកាន់តែរីករាលដាល និងវិមជ្ឈការ ដែលអនុញ្ញាតឱ្យវាបន្តទៅមុខទៀត ហើយទោះបីជាពួកគេ លែងមានអំណាចក្នុងការកាន់កាប់ទឹកដីដូចដែលពួកគេ ធ្លាប់ធ្វើក៏ប៉ុន្មានសប្តាហ៍ថ្មីៗនេះ យុទ្ធជនរបស់ក្រុមរដ្ឋអ៊ីស្លាមនៅអ៊ីរ៉ាក់ បានសម្លាប់ទាហានអ៊ីរ៉ាក់ ១០នាក់ និងមន្ត្រីម្នាក់ នៅក្នុងការវាយប្រហារលើបន្ទាយទ័ពមួយ ហើយកាត់ក្បាលមន្ត្រីប៉ូលិសម្នាក់មុខកាមេរ៉ា។ នៅស៊ីរីក្រុមជីហាដបានវាយប្រហារពន្ធនាគារមួយ ដើម្បីប៉ុនប៉ងដោះលែងអតីតសមមិត្តរាប់ពាន់នាក់ ហើយកាន់កាប់បរិវេណនោះអស់រយៈពេលជាង ១សប្តាហ៍ មុនពេលកងជីវពលដឹកនាំដោយជនជាតិឃើដ ដែលគាំទ្រដោយសហរដ្ឋអាមេរិកបណ្តេញពួកគេចេញវិញ។<br>ក្រុមរដ្ឋអ៊ីស្លាម IS រុងរឿងបំផុតនៅក្នុងឆ្នាំ២០១៥ ដោយក្រុមនេះបានគ្រប់គ្រងទឹកដី ដែលមានទំហំប៉ុនចក្រភពអង់គ្លេសក្នុងប្រទេសស៊ីរី និងអ៊ីរ៉ាក់ ហើយជំនួសឱ្យក្រុមអាល់កៃដាដោយក្លាយជាអង្គការភេរវកម្មដែលមានជាងគេ និងគ្រោះថ្នាក់បំផុតរបស់ពិភពលោក។ ការបាត់បង់ទឹកដីចុងក្រោយរបស់ក្រុមរដ្ឋអ៊ីស្លាមក្នុងឆ្នាំ២០១៩ បន្ទាប់ពីសង្គ្រាមរយៈពេល៤ឆ្នាំកន្លះ គឺជាបរាជ័យដ៏ធំមួយ ហើយការវាយប្រហារឥតឈប់ឈរពីសំណាក់សហរដ្ឋអាមេរិក និងដៃគូ នៅស៊ីរី អ៊ីរ៉ាក់ និងកន្លែងផ្សេងទៀត រំខានដល់បណ្តាញហិរញ្ញវត្ថុរបស់ក្រុមនេះ និងនាំឱ្យមានការស្លាប់របស់កម្មាភិបាលជាច្រើននាក់។ អ្នកជំនាញខាង IS លោក Hassan Hassan សរសេរកាលពីថ្ងៃព្រហស្បតិ៍លើទស្សនាវដ្តីអនឡាញ New Lines ថា ស្របពេលដែលក្រុមរដ្ឋអ៊ីស្លាម IS ស្វែងរកកន្លែងថ្មីក្រុមនេះលែងដូចមុនទៀតហើយ ដោយសារតែការវាយប្រហាររបស់អាមេរិក និងសម្ព័ន្ធមិត្ត ដែលសម្លាប់សមាជិករបស់ក្រុមយ៉ាងច្រើន។ លោក Hassan សរសេរថា ភាពខ្វះចន្លោះនៃភាពជាអ្នកដឹកនាំ ភាពទាក់ទាញនៃក្រុមជីហាដអន្តរជាតិ និងការបង្កើនភាពរឹងមាំរបស់រដ្ឋាភិបាលសត្រូវ និងក្រុមសកម្មប្រយុទ្ធ ដែលប្រកួតប្រជែងអាចរារាំងសមត្ថភាពរបស់ក្រុមក្នុងការវិលត្រឡប់មកវិញ លោកបន្តថា៖ «ការស្លាប់របស់មេដឹកនាំរបស់ខ្លួន ក្នុងកាលៈទេសៈទាំងនេះនឹងធ្វើឱ្យក្រុមនេះ កាន់តែខុសពីទម្រង់ដើមឆ្ងាយ និងធ្វើឱ្យសមត្ថភាពរបស់ក្រុមខ្សោយក្នុងការផ្តោតទៅលើអំពើភេរវកម្មអន្តរជាតិ»។<br>លោក Michael Knights អ្នកវិភាគជំនាញខាងយោធា និងសន្តិសុខនៅអ៊ីរ៉ង់ មកពីវិទ្យាស្ថាន Washington និងសហការី លោក Alex Almeida និយាយតាមការវិភាគថ្មីៗលើទិន្នន័យវាយប្រហារថា របស់ក្រុមរដ្ឋអ៊ីស្លាម IS ហាក់ដូចជាមិនសូវមានគ្រោះថ្នាក់ទេនៅអ៊ីរ៉ាក់នាពេលនេះ ដោយថាការវាយប្រហាររបស់ពួកគេបានថយចុះចាប់តាំងពីឆ្នាំ២០២០ ទាំងបរិមាណ និងគុណភាព ដែលបណ្តាលមកពីការវាយប្រហារពីខ្មាំងសត្រូវរបស់ខ្លួន។ ប៉ុន្តែអ្នកវិភាគទាំង២កត់សម្គាល់ថា ក្រុមរដ្ឋអ៊ិស្លាមនេះក៏ធ្លាប់ត្រូវបានចាត់ទុកថា ជាកម្លាំងទន់ខ្សោយត្រឹមតែប៉ុន្មានឆ្នាំប៉ុណ្ណោះ មុនពេលដែលពួកគេផ្ទុះខ្លាំងឡើង និងពង្រឹងការគ្រប់គ្រងលើទីក្រុងទាំងមូលនៅស៊ីរី និងអ៊ីរ៉ាក់ ក្នុងឆ្នាំ២០១៤ ដែលធ្វើឱ្យអ្នកភាគពិបាកសន្និដ្ឋានថា ពួកគេបាត់បង់ជាតុខ្លាំង។<br>ក្រុម IS ត្រូវបានគេមើលឃើញថាឆ្លៀតឱកាសធ្វើប្រតិបត្តិការ នៅក្នុងរដ្ឋទន់ខ្សោយតំបន់ជម្លោះ និង |

| | |
|---|---|
| **អត្ថបទវិភាគ** | កន្លែងដែលគ្រប់គ្រងមិនបានល្អ។ របាយការណ៍របស់អង្គការសហប្រជាជាតិ ចេញផ្សាយមុនការស្លាប់របស់លោក al-Quray shi និយាយថា ក្រុមរដ្ឋអ៊ីស្លាម IS នៅឆ្ងាយពីការកម្ចាត់ចេញ ហើយនៅតែជាកម្លាំងដ៏ខ្លាំងក្លា និងការគំរាមកំហែងមួយនៅអ៊ីរ៉ាក់ និងស៊ីរី ជាមួយនឹងវត្តមានកាន់តែច្រើនឡើង នៅអាហ្វហ្គានីស្ថាន និងអាហ្វ្រិកខាងលិច។ ក្នុងការវាយតម្លៃអំពីស្ថានភាពនៅអ៊ីរ៉ាក់ និងស៊ីរី របាយការណ៍និយាយថា ក្រុមរដ្ឋអ៊ីស្លាម ISIS អាចនឹងមានអ្នកប្រយុទ្ធចន្លោះពី៦០០០ ទៅ១០០០០នាក់ នៅទូទាំងប្រទេសទាំង២ ជាកន្លែងដែលពួកគេកំពុងបង្កើតកោសិកា និងបណ្តុះបណ្តាលប្រតិបត្តិករ ដើម្បីបើកការវាយប្រហារដោយប្រើកន្លែងលាក់ខ្លួននៅលើវាលខ្សាច់។ របាយការណ៍ដដែលរបស់អ.ស.បន្ថែមថា៖ «ការជាប់គាំងក្នុងស្ថានភាពដ៏អាក្រក់ ហ៊ុមព័ទ្ធដោយឥទ្ធិពលជ្រុលនិយមអាចបណ្តាលឱ្យក្រុមយុវវ័យក្មេង ជាពិសេសនៅជំរុំជនភៀសខ្លួននៅភាគខាងជើងស៊ីរី ក្លាយជាពួកជ្រុលនិយមរឹងរូសដោយទទួលបាននូវការបណ្តុះបណ្តាល [ខាងមនោគមន៍វិជ្ជាជ្រុលនិយម]»៕<br>*ភ្នំពេញប៉ុស្តិ៍, ថ្ងៃចន្ទ ទី៧ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី១៧* |
| **រុស្ស៊ី** | **តើអ្វីទៅគឺជា «សន្តិសុខមិនអាចប្រកែកបាន»? គោលការណ៍នៅចំកណ្តាលកំហឹងរបស់រុស្ស៊ី ចំពោះអង្គការណាតូ**<br>ការខឹងសម្បារបស់ លោក វ្លាឌីមៀរ ពូទីន ចំពោះ លោកខាងលិច និងការពង្រីករបស់អង្គការណាតូមកកាន់អឺរ៉ុបខាងកើត គឺទំនងបង្កដោយបទប្បញ្ញត្តិអាយុរាប់ទសវត្សរ៍មួយ ដែលប្រធានាធិបតីរុស្ស៊ីនេះនិយាយថាកំពុងរងការគំរាមកំហែង៖ «សន្តិសុខមិនអាចបំបែកបាន»។ ក្នុងនិយមន័យទូលំទូលាយគោលការណ៍នេះបានចែងថា សន្តិសុខរបស់រដ្ឋណាមួយគឺមិនអាចបំបែកពីសន្តិសុខ នៃរដ្ឋដទៃទៀតក្នុងតំបន់របស់ខ្លួន។ បើតាមទស្សនៈរបស់ លោក ពូទីន យុទ្ធសាស្ត្របច្ចុប្បន្នរបស់អង្គការណាតូ គឺកំពុងគំរាមកំហែងដល់គោលការណ៍នេះ ហើយជាហេតុផលពីក្រោយការសម្រេចចិត្តរបស់ក្រុងមូស្គូ ដើម្បីដាក់ពង្រាយទាហានជាង ១០០,០០០នាក់ នៅជិតព្រំដែនប្រទេសអ៊ុយក្រែន។<br>កាលពីសប្តាហ៍មុនរដ្ឋមន្ត្រីក្រសួងការបរទេសរុស្ស៊ី លោក ស៊ើហ្គេយ៍ ឡាវរ៉ូវ បានធ្វើការចោទប្រកាន់ម្តងទៀតថា លោកខាងលិចគឺជាអ្នកបង្ករឿងបន្ទាប់លោកខាងលិច បានចេញផ្សាយការវាយតម្លៃចារកម្មថា រុស្ស៊ីកំពុងរៀបចំផែនការបង្កើតលេស ដើម្បីចាប់ផ្តើមការឈ្លានពានចូលអ៊ុយក្រែន។ «រុស្ស៊ីព្រួយបារម្ភយ៉ាងខ្លាំង អំពីការកើនឡើងភាពតានតឹងនយោបាយយោធានៅជិតព្រំដែនខាងលិចរបស់ខ្លួន» លោក ឡាវរ៉ូវ បាននិយាយបែបនេះហើយបន្តទៀតថា មាន«ការខ្វែងគំនិតគ្នា លើការយល់ដឹងអំពីគោលការណ៍នៃសន្តិសុខស្មើគ្នា និងមិនអាចបំបែកបាន ដែលជាមូលដ្ឋានគ្រឹះនៃស្ថាបត្យកម្មសន្តិសុខអឺរ៉ុបទាំងមូល»។ ប៉ុន្តែអ្នកវិភាគមួយចំនួនបាននិយាយថា ការលើកឡើងរបស់រុស្ស៊ី គឺគ្រាន់តែជាការអូសបន្លាយពេលវេលាប៉ុណ្ណោះសម្រាប់ពួកគេធ្វើការរៀបចំយុទ្ធសាស្ត្រ។ បង្កើតឡើងដំបូងអំឡុងពេលនៃសង្គ្រាមត្រជាក់ឃ្លា «សន្តិសុខមិនអាចបំបែកបាននៅអឺរ៉ុប» ត្រូវបានគេលើកឡើង ក្នុងសន្ធិសញ្ញាចុងក្រោយនៃសន្និសីទសន្តិសុខក្រុងហេលស៊ីនគីឆ្នាំ១៩៧៥ ដែលបានកំណត់ច្បាប់មូលដ្ឋាន សម្រាប់អន្តរកម្មរវាងប្លុកប្រឆាំងទាំង២ គឺសម្ព័ន្ធភាពខាងលិចអង្គការណាតូ និងសម្ព័ន្ធភាពខាងកើតកតិកាសញ្ញាវ៉ាសូវី។ ប៉ុន្តែបន្ទាប់ពីដួលរលំនៃសហភាព |

**រុស្ស៊ី**

សូវៀតអតីតសមាជិកកតិកាសញ្ញាវ៉ាសូវីមួយចំនួន បានចាប់ផ្តើមចង់មានសេរីភាព ក្នុងការជ្រើសរើសសម្ព័ន្ធភាពដោយខ្លួនឯង។

ធម្មនុញ្ញក្រុងប៉ារីសឆ្នាំ១៩៩០ សម្រាប់អឺរ៉ុបថ្មីបានចែងថា៖ «សន្តិសុខគឺមិនអាចបំបែកបានហើយ សន្តិសុខនៃរដ្ឋដែលចូលរួមទាំងអស់ ត្រូវបានភ្ជាប់ដោយតំណមិនអាចផ្តាច់បាននឹងរដ្ឋផ្សេងទៀតទាំងអស់»។ កិច្ចប្រជុំកំពូលរបស់អង្គការ សម្រាប់សន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប(OSCE) នៅក្រុងអ៊ីស្តង់ប៊ុល កាលពីឆ្នាំ១៩៩៩ និងក្រុងអាស្តាណា នៅឆ្នាំ២០១០ បានបញ្ជាក់ម្តងទៀតនូវសារៈសំខាន់នៃគោលការណ៍នេះដោយលើកឡើងថា អ្នករំលោភគោលការណ៍នេះ នឹងបង្កផលប៉ះពាល់ដល់សន្តិសុខអ្នកដទៃទៀត។ ប៉ុន្តែកិច្ចប្រជុំកំពូលទាំង២ ក៏បានរំឭកឡើងវិញថាគ្មានរដ្ឋ ឬក្រុមរដ្ឋណាមួយ «អាចចាត់ទុកផ្នែកណាមួយនៃតំបន់(OSCE) ជាផ្នែកនៃដែនឥទ្ធិពលរបស់ពួកគេឡើយ»។ សន្ធិសញ្ញាបង្កើតទំនាក់ទំនងរវាងអង្គការណាតូ និងរុស្ស៊ី កាលពីឆ្នាំ១៩៩៧ ក៏បានទទួលស្គាល់គោលការណ៍នេះហើយ បានសន្យាថា អង្គការណាតូនឹងមិនកសាងមូលដ្ឋានយោធាអចិន្ត្រៃយ៍នៅសមាជិកថ្មីទេ។ គួរឱ្យកត់សម្គាល់បុព្វកថា សន្ធិសញ្ញានេះក៏បាននិយាយថា ណាតូ និងរុស្ស៊ី «មិនចាត់ទុកគ្នាទៅវិញទៅមកជាសត្រូវទេ»។ ប៉ុន្តែសព្វថ្ងៃនេះ ស្ថានការណ៍បានប្រែប្រួលយ៉ាងខ្លាំង។ ប្រទេសរុស្ស៊ីក្រោមការដឹកនាំរបស់ លោក ពូទីន បានព្យាយាមបង្កើតដែនឥទ្ធិពលឡើងវិញ ធ្វើសង្គ្រាមប្រឆាំងប្រទេសហ្សកហ្ស៊ីនៅឆ្នាំ២០០៨ និងកាត់យកឧបទ្វីបគ្រីមាពីប្រទេសអ៊ុយក្រែននៅឆ្នាំ២០១៤។ ស្របពេលជាមួយគ្នានេះ អតីតរដ្ឋបរណបនៃសហភាពសូវៀតដូចជាប៉ូឡូញ ឡេតូនី លីទុយអានី អេស្តូនី រូម៉ានីជាដើម ដោយរក្សាការដាក់ពង្រាយវិលជុំទៅកាន់មូលដ្ឋានក្នុងប្រទេសទាំងនេះ៕

*ភ្នំពេញប៉ុស្តិ៍, ថ្ងៃពុធ ទី៩ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី១៧*

## តើទណ្ឌកម្មរុស្ស៊ី អាចប៉ះពាល់សេដ្ឋកិច្ចអឺរ៉ុប ដោយរបៀបណា?

ការកាត់ផ្តាច់រំហូរឧស្ម័នធម្មជាតិទៅកាន់អឺរ៉ុប គឺជាវិធានការឆ្លើយតបខ្លាំងបំផុតដែលរុស្ស៊ី មានក្នុងដៃ ប្រសិនបើលោកខាងលិច ធ្វើការបន្តឹងទណ្ឌកម្មជុំវិញវិបត្តិនៅប្រទេសអ៊ុយក្រែន។ ប៉ុន្តែចំណុចខ្សោយរបស់សហភាពអឺរ៉ុប ចំពោះវិធានការឆ្លើយតបរបស់រុស្ស៊ី គឺមិនត្រឹមតែមានក្នុងវិស័យថាមពលទេ។ អ្នកវិភាគមួយចំនួនព្រួយបារម្ភថា សហភាពអឺរ៉ុបបានត្រៀមខ្លួនតិចជាងរុស្ស៊ីសេណារីយោអាក្រក់បំផុត។ ក្រុងមូស្គូបានអនុវត្តគោលនយោបាយសំខាន់ៗមួយចំនួន ដែលបានធ្វើឱ្យសេដ្ឋកិច្ចរុស្ស៊ីបំប្លែងខ្លួនទៅជា «បន្ទាយ» ដែលអាចទប់ទល់នឹងការដាក់ទណ្ឌកម្ម។

ចាប់តាំងពីអ្នកផ្គត់ផ្គង់បច្ចេកវិទ្យា និងអ្នកផ្តល់ប្រាក់កម្ចីរហូតដល់អ្នកនាំចេញទំនិញ និងរោងចក្រដែលរំពឹងយ៉ាងខ្លាំង លើការនាំចូលវត្ថុធាតុដើម ការរំខានដល់ទំនាក់ទំនងពាណិជ្ជកម្មនឹងបង្កើនសម្ពាធអតិផរណាទៅលើអឺរ៉ុប នឹងបង្កការទប់ស្កាត់សកម្មភាពយ៉ាងទូលំទូលាយ ដល់បណ្តាអាជីវកម្មរបស់ពួកគេ។ កាលពីសប្តាហ៍មុនប្រធានធនាគារកណ្តាលអឺរ៉ុប លោកស្រី គ្រីស្ទីន ឡាហ្គាដ បាននិយាយថា៖ «ពពកភូមិសាស្ត្រនយោបាយដែលយើងមាននៅលើទ្វីបអឺរ៉ុប ប្រសិនបើពួកវាក្លាយជាការពិត ប្រាកដជាមានផលប៉ះពាល់ដល់តម្លៃថាមពល ប៉ុន្តែក៏នឹងជះឥទ្ធិពលដល់កំណើនផងដែរ ដែលជាលទ្ធផលនៃការកាត់បន្ថយប្រាក់ចំណូល និងអាចជាលទ្ធផលនៃការកាត់បន្ថយការប្រើប្រាស់ និងការបង្វែរការវិនិយោគ»។

| | |
|---|---|
| **រុស្ស៊ី** | រុស្ស៊ីគឺជាអ្នកផ្គត់ផ្គង់ថាមពលដ៏ធំបំផុតរបស់សហភាពអឺរ៉ុប។ ប្រមាណ ៤០ភាគរយ នៃការនាំចូលឧស្ម័នធម្មជាតិ និងជិត ១ភាគ៣ នៃការនាំចូលប្រេងឆៅរបស់ប្លុកនេះគឺមកពីរុស្ស៊ី។ សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប កំពុងពិភាក្សាស្វែងរកប្រភពឧស្ម័នថ្មីប្រសិនបើរុស្ស៊ីកាត់ផ្តាច់ការផ្គត់ផ្គង់ឧស្ម័ន។ ស្តុកបម្រុងឧស្ម័នធម្មជាតិនៅអឺរ៉ុប គឺស្ថិតនៅកម្រិតទាបបំផុតក្នុងប្រវត្តិសាស្ត្រ ហើយក្នុងរយៈពេលប៉ុន្មានខែចុងក្រោយនេះតម្លៃឧស្ម័នបានកើនដល់កំណត់ត្រាខ្ពស់បំផុត ដែលបង្កើនឥទ្ធិពលរបស់រុស្ស៊ីនៅអឺរ៉ុប។ ក្នុងករណីដែលសង្គ្រាមផ្ទុះឡើង អ្នកវិភាគជាច្រើននិយាយថា តម្លៃឧស្ម័ននៅអឺរ៉ុបអាចកើនដល់កម្រិតមិនធ្លាប់ឃើញពីមុនមក។ នៅពេលនោះសហភាពអឺរ៉ុបនឹងត្រូវធ្វើការសម្រេចដ៏លំបាក ក្នុងការទប់ស្កាត់តម្រូវការឧស្សាហកម្ម និងអ្នកប្រើប្រាស់ ដើម្បីរួចផុតពីការរំខានទ្រង់ទ្រាយធំនៃការផ្គត់ផ្គង់ឧស្ម័នរហូតដល់រដូវក្តៅ ។<br>ជាងនេះទៅទៀត ប្រទេសដូចជាអាល្លឺម៉ង់ មានវិសាលភាពតិចតួចក្នុងការប្តូរទៅប្រភពថាមពលផ្សេងទៀតក្នុងរយៈពេលខ្លី ដោយពួកគេបានបំបាត់ថាមពលនុយក្លេអ៊ែរ និងធ្យូងថ្មស្ទើរទាំងស្រុងទៅហើយ។ ទន្ទឹមនឹងនេះដែរ ក្រុមហ៊ុនប្រេងអឺរ៉ុបដូចជា BPTotal និងShell អាចប្រឈមមុខនឹងបាត់បង់គម្រោងបណ្តាក់ទុនរួមគ្នារបស់ពួកគេនៅក្នុងប្រទេសរុស្ស៊ី ប្រសិនបើការដាក់ទណ្ឌកម្មថ្មីត្រូវបានណែនាំ។ បន្ថែមពីលើនេះទៅទៀតប្រទេសរុស្ស៊ីគឺជាអ្នកនាំចេញវត្ថុធាតុដើមនាំមុខគេ សម្រាប់សហភាពអឺរ៉ុប។ ក្រុមហ៊ុនផលិតយន្តហោះ Airbus គឺពឹងយ៉ាងខ្លាំងលើការនាំចូលលោហៈទីតាញ៉ូមពីរុស្ស៊ី ហើយសូម្បីតែគូប្រជែងរបស់ខ្លួននៅអាមេរិក Boeing ក៏ពឹងយ៉ាងខ្លាំងលើការនាំចូលលោហៈនេះពីរុស្ស៊ីផងដែរ។ ក្រុមហ៊ុន Airbus បាននិយាយថាខ្លួននឹង «គោរពយ៉ាងម៉ឺងម៉ាត់នូវការដាក់ទណ្ឌកម្ម និងបទប្បញ្ញត្តិគ្រប់គ្រងការនាំចេញ»៕<br>*ភ្នំពេញប៉ុស្តិ៍, ថ្ងៃសុក្រ ទី១១ ខែកុម្ភៈ ឆ្នាំ២០២២, ទំព័រទី១៧* |
| **អត្ថបទវិភាគ** | **បទវិភាគអន្តរជាតិ ៖ អ្វីទៅនៅពីក្រោយភាពផ្អែមល្ហែមរវាង លោក ស៊ី ជិនពីង និងលោក ពូទីន?**<br>(ប៉េកាំង)៖ ខណៈបណ្តាប្រទេសលោកខាងលិចមួយចំនួន ដឹកនាំដោយសហរដ្ឋអាមេរិកនាំគ្នាធ្វើពហិការការទូត ប្រឆាំងនឹងព្រឹត្តិការណ៍កីឡាអូឡាំពិករដូវរងាទីក្រុងប៉េកាំងចិន និងរុស្ស៊ី បានយកឱកាសនៃការប្រារព្ធព្រឹត្តិការណ៍ដ៏ធំមួយនេះ បង្ហាញពីការកើនឡើងជាលំដាប់នៃទំនាក់ទំនងទ្វេភាគី នៃប្រទេសរបស់ពួកគេ។ លោកប្រធានាធិបតីរុស្ស៊ី វ្លាឌីមៀ ពូទីន បានបង្ហោះរូបភាពជាច្រើនសន្លឹក ដែលថតជាមួយលោកប្រធានាធិបតីចិន ស៊ី ជិនពីង នៅថ្ងៃបើកការប្រកួតព្រឹត្តិការណ៍កីឡាអូឡាំពិករដូវរងា ទីក្រុងប៉េកាំង ឆ្នាំ២០២២។ មិនតែប៉ុណ្ណោះ លោក ពូទីន ផ្ទាល់ថែមទាំងប្រកាសពីភាពជាដៃគូយុទ្ធសាស្ត្រគ្មានព្រំដែនដើម្បីទប់ទល់នឹងការពង្រីកឥទ្ធិពលរបស់អង្គការ NATO ព្រមទាំងបានអំពាវនាវឱ្យលោកខាងលិច បោះបង់ចោលមនោគមន៍វិជ្ជាសម័យសង្គ្រាមត្រជាក់។ នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយ លោក ពូទីន និងលោក ស៊ី ជិនពីន ក៏បាននិយាយដែរថា NATO ត្រូវតែគោរពដែនអធិបតេយ្យភាព, សន្តិសុខ និងផលប្រយោជន៍នៃបណ្តាប្រទេសទាំងឡាយ ហើយប្រកាន់ឥរិយាបថស្មើភាព ចំពោះការអភិវឌ្ឍដោយសន្តិវិធីរបស់បណ្តាប្រទេសនានា។ តើហេតុអ្វីបានជាចិន និងរុស្ស៊ី អាចសម្រេចបានទំនាក់ទំនងល្អដូចសព្វថ្ងៃ? បើតាមអ្នកជំនាញភាគច្រើន, ចិន និងរុស្ស៊ី មានទំនាក់ទំនងល្អ គឺដោយសារតែពួកគេចាត់ទុកលោកខាងលិច |

**អត្ថបទវិភាគ**

ជាពិសេសអាមេរិកជា «សត្រូវរួម» ហើយឈរលើគោលជំហរបែបនេះ ធ្វើឱ្យគេយល់ថាប្រទេសទាំង២ ដែលធ្លាប់មានជម្លោះមនោគមន៍វិជ្ជានឹងគ្នា ក្នុងសម័យសង្គ្រាមត្រជាក់ កំពុងឆ្ពោះទៅរកការប្រែក្លាយទំនាក់ទំនងរបស់ពួកគេឱ្យទៅជាប្រព័ន្ធសម្ព័ន្ធមិត្តតែម្តង។

***កិច្ចសហប្រតិបត្តិការយោធារវាងចិន និងរុស្ស៊ី ភាគច្រើនពាក់ព័ន្ធនឹងនយោបាយ**

ក្រុមអ្នកជំនាញលោកខាងលិច មើលឃើញកិច្ចសហប្រតិបត្តិការយោធារវាងចិន និងរុស្ស៊ី មានលក្ខណៈនយោបាយ ជាជាងការត្រៀមខ្លួនសម្រាប់ការចូលរួមក្នុងសកម្មភាពយោធារួមគ្នា។ កាលពីប៉ុន្មានខែមុន ទីក្រុងមូស្គូបានបង្ហាញការគាំទ្រត្រង់ៗរបស់ខ្លួន ចំពោះការប្រើប្រាស់កម្លាំងយោធារបស់ចិន ជាមធ្យោបាយដាក់សម្ពាធលើជប៉ុន និងកូរ៉េខាងត្បូង។ កាលពីខែតុលា ឆ្នាំ២០២១ កងទ័ពជើងទឹកចិន និងរុស្ស៊ី បានដឹកនាំការធ្វើប្រតិបត្តិការល្បាតរួមគ្នា ជុំវិញប្រទេសជប៉ុន ហើយនៅខែវិច្ឆិកា ឆ្នាំ២០២១, យន្តហោះទម្លាក់គ្រាប់បែកយុទ្ធសាស្ត្រជាច្រើនគ្រឿងនៃប្រទេសទាំង២ បានចូលរួមក្នុងប្រតិបត្តិការល្បាតអាកាសជាលើកទី៣ ពីលើតំបន់សមុទ្រជប៉ុន និងសមុទ្រចិនខាងកើត ដែលនេះត្រូវបានគេមើលឃើញថាចិន និងរុស្ស៊ី ចង់បង្ហាញថា ខ្លួនមានបំណងរួមដៃគ្នាដើម្បីទប់ទល់សម្ព័ន្ធមិត្តអាមេរិក-ជប៉ុន។ ប៉ុន្តែទីក្រុងប៉េកាំងវិញហាក់ដូចជាមិនបានធ្វើដូចរុស្ស៊ីនោះទេ ដោយពួកគេមានការស្ទាក់ស្ទើរបង្ហាញការគាំទ្រត្រង់ៗ ចំពោះសកម្មភាពយោធារុស្ស៊ីនៅក្នុងតំបន់អឺរ៉ុប។ កងទ័ពចិនមិនបានចូលរួមក្នុងការធ្វើសមយុទ្ធយោធាឈ្មោះថា Zapad-21 ដែលរៀបចំឡើងដោយរុស្ស៊ី និងបេឡារុសនោះទេ។ ផ្ទុយទៅវិញកងទ័ពរុស្ស៊ី បានចូលរួមក្នុងសមយុទ្ធយោធារួមនៅក្នុងប្រទេសចិន។ ការស្ទាក់ស្ទើររបស់ចិនក្នុងការបង្ហាញការគាំទ្រត្រង់ៗ ដល់សកម្មភាពយោធារុស្ស៊ីក្នុងតំបន់អឺរ៉ុបត្រូវបានគេបកស្រាយថា អាចមកពីចិនខ្លាចថាវាធ្វើឱ្យសហភាពអឺរ៉ុប កាន់តែខិតជិតទៅរកសហរដ្ឋអាមេរិក។ ម្យ៉ាងវិញទៀតខណៈរុស្ស៊ីគាំទ្រគោលនយោបាយចិនតែមួយចំពោះកោះតៃវ៉ាន់ ចិនវិញមិនដែលបានលើកឡើងពីបំណងជាក់លាក់ពាក់ព័ន្ធនឹងបញ្ហាអ៊ុយក្រែនឡើយ៕

*Fresh News, ថ្ងៃពុធ ទី០៩-០២-២០២២*

## តើចិនកំពុងទាកចេញពីវប្បធម៌លោកខាងលិច អំឡុងពេលប្រកួតប្រជែងជាមួយអាមេរិក?

ចិនចាប់ផ្តើមលើកតម្កើងវប្បធម៌របស់ខ្លួន និងងាកចេញ ពីឥទ្ធិពលការលំហូរចូលនៃលោកខាងលិច ខណៈពលដែលប្រទេសនេះ កំពុងតែមានភាពតានតឹងនៃការទូតកាន់តែខ្លាំងជាមួយនឹងអាមេរិក។ ខណៈពលព្រឹត្តិការណ៍អូឡាំពិករដូវរងាចាប់ផ្តើម នៅទីក្រុងប៉េកាំងនៅតាមដងផ្លូវនានា ក្នុងទីក្រុងប៉េកាំង និងទីក្រុងជិតខាងហៅថា ធានជីនគេសង្កេតឃើញថា មានការផ្លាស់ប្តូរពីឈ្មោះជាភាសាអង់គ្លេស អមជាមួយនឹងភាសាចិនទៅជាអក្សរសំនៀងចិនភីនអ៊ីន (pinyin) ទៅវិញ។ ឧទាហរណ៍ អាកាសយានដ្ឋានប៊ីនហៃធានជីនកាលពីមុនសរសេរជាភាសាអង់គ្លេសអមជាមួយភាសាចិនថា Tianjin BinhaiInternational Airport តែនៅពេលនេះគេផ្លាស់ប្តូរទៅជាអក្សរឡាតាំងសំនៀងចិនថា Binhai GuoJiJiChang ទៅវិញ។ សារព័ត៌មាន SouthChinaMorning Post បានចុះផ្សាយថា ការផ្លាស់ប្តូរភាសាបែបនេះ ធ្វើឱ្យជនបរទេសមួយចំនួនបង្ហាញពីការមិនសប្បាយចិត្តប៉ុន្មាននោះទេ។

| | |
|---|---|
| អត្ថបទវិភាគ | យ៉ាងណាក៏ដោយ អាជ្ញាធរទីក្រុងប៉េកាំងបានលើកឡើងថា ការផ្លាស់ប្តូរបែបនេះគឺជាការអនុវត្តតាមស្តង់ដាជាតិរបស់ចិនប៉ុណ្ណោះ។ ស្តង់ដានោះគឺផ្អែកតាមគោលការណ៍ណែនាំ ក្នុងការប្រើប្រាស់ភាសាអង់គ្លេសនៅតំបន់សេវាសាធារណៈឆ្នាំ២០១៧។ ការផ្លាស់ប្តូរនេះ ដែរមិនមែនផ្លាស់ប្តូរទាំងស្រុងនៅឡើយនោះទេ ដោយកន្លែងទេសចរណ៍សំខាន់ៗដូចជាវិមានរដូវក្តៅ (SummerPalace) និងសារមន្ទីរយោធា (Military Musuem) នៅតែរក្សាឈ្មោះជាភាសាអង់គ្លេសដដែល។ ទោះជាបែបនេះក្តី គេនៅមិនទាន់ច្បាស់ថា ហេតុអ្វីបានជាអាជ្ញាធរចិនផ្លាស់ប្តូរនៅពេលឥឡូវនេះទេ។ នេះជាឧទាហរណ៍មួយតូចប៉ុណ្ណោះ នៃការពង្រីកស្មារតីជាតិនិយម ក្នុងចំណោមសាធារណមតិជនជាតិចិន។ កាលពីឆ្នាំមុន រដ្ឋាភិបាលចិនបានធ្វើការហាមឃាត់មិនឱ្យប្រើប្រាស់សៀវភៅបរទេស ដើម្បីមកបង្រៀនសិស្សានុសិស្សជំនាន់ក្រោយឡើយ ស្របពេលដែលសាលាប្រើប្រាស់កម្មវិធីសិក្សាអន្តរជាតិវិញ ក៏រងការធ្វើទុក្ខបុកម្នេញខ្លាំងពីសំណាក់អាជ្ញាធរចិនផងដែរ។<br>ពាក់ព័ន្ធនឹងរឿងនេះដែរ សាស្ត្រាចារ្យចិនដ៏មានឥទ្ធិពល ១រូប គឺលោក Yan Xuetong បានលើកឡើងកាលពីខែមុនថា ក្មេងៗចិនកើតក្រោយឆ្នាំ២០០០ ចាប់ផ្តើមមានជំនឿចិត្តលើប្រទេសខ្លួនឯងជ្រុល និងចាត់ទុកលោកខាងលិចថាជាកម្លាំងធាតុអាក្រក់។ ស្មារតីជាតិនិយមមួយនេះ បង្កឡើងដោយអ្នកសរសេរវិចារណកថាល្បីៗនៅបណ្តាញអ៊ីនធឺណិតចិន ដោយការបញ្ចេញមតិរបស់ពួកគេទាំងនោះ មានលាយឡំនឹងព័ត៌មានមិនពិតមួយចំនួន។ នេះបើតាមការលើកឡើង របស់នាយកវិទ្យាស្ថានសិក្សាអន្តរជាតិនៃសាកលវិទ្យាល័យស៊ីងហួរ។ ជាមួយនឹងបញ្ហានេះដែរ លោក George Magnus អ្នកស្រាវជ្រាវជំនួយនៃមជ្ឈមណ្ឌលចិននៃសាកលវិទ្យាល័យ Oxford បានប្រាប់សារព័ត៌មាន SouthChinaMorning Post ថាការផ្លាស់ប្តូរផ្នែកតូចៗទាំងនេះ ប្រសិនបើសរុបចូលគ្នាអាចក្លាយជារបត់នយោបាយដ៏សំខាន់មួយ។ លោកបានសង្កត់ធ្ងន់ថាទំនោរនេះអាចជាផ្នែកមួយនៃ«អសកលភាវូបនីយកម្ម»។ លោកបានបន្ថែមថា លោកមិនមានភាពភ្ញាក់ផ្អើលទេនៃរបត់នយោបាយទាំងនេះ ដោយសារតែការប្រកួតប្រជែងរវាងប្រទេសមហាអំណាច សាយភាយទៅដល់ការប្រកួតប្រជែងលើគុណតម្លៃរវាងមហាអំណាចរៀងខ្លួន។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ទៅទៀតនោះ លោក Magnus យល់ឃើញថាចិនទំនងប្រើប្រាស់គោលនយោបាយ ហ្សេរ៉ូកូវីដដើម្បីជាការរឹតត្បិតដល់ការធ្វើដំណើរនានា ដែលបណ្តាលឱ្យទំនាក់ទំនងផ្លាស់ប្តូរវប្បធម៌រវាងចិន និងលោកខាងលិច កាន់តែសាត់ឆ្ងាយពីគ្នា។ «នេះបានបង្កជាភាពភ័យខ្លាច និងភ័យស្លន់ស្លោ សម្រាប់អ្នកដែលមិនអាចមកស្រុកចិនដោយសេរី។ សង្ឃឹមថាបញ្ហានេះនឹងបញ្ចប់ឱ្យបានកាន់តែឆាប់ នៅពេលដែលវានៅបន្ត នោះវានឹងបង្កឱ្យមានអត្តចរិតក្នុងការបិទខ្ទប់ជាជាងការបើកចំហប្រទេស»។ នេះជាការលើកឡើងរបស់ លោក Magnus៕<br>*ភ្នំពេញប៉ុស្តិ៍, ថ្ងៃព្រហស្បតិ៍ ទី១០ ខែកុម្ភៈ ឆ្នាំ២០២២,ទំព័រទី១៨* |
| | **បទវិភាគអន្តរជាតិ៖ ហេតុអ្វីអេមីរ៉ាតអារ៉ាប់រួម បង្កើនការទិញសព្វាវុធ?**<br>(ឌូបៃ)៖ ការវាយប្រហារជាច្រើនដោយគ្រាប់មីស៊ីល និងយន្តហោះដ្រូនរបស់ក្រុមឧទ្ទាមហ៊ូទី ដែលមានអ៊ីរ៉ង់ជាខ្នងបង្អែកលើប្រទេសអេមីរ៉ាតអារ៉ាប់រួម កាលពីពេលថ្មីៗនេះបានបង្ហាញថា ទីក្រុងជាច្រើននៃរដ្ឋក្នុងតំបន់ឈូងសមុទ្រពែក្សមួយនេះកំពុងស្ថិតនៅក្រោមហានិភ័យ។ អេមីរ៉ាត់អារ៉ាប់រួម ដែលស្ថិតនៅក្នុងក្រុមចម្រុះអារ៉ាប់ដឹកនាំដោយអារ៉ាប៊ីសាអូឌីត កំពុងប្រយុទ្ធជាមួយក្រុមឧទ្ទាមហ៊ូទី នៅយេម៉ែនផងនោះពឹងផ្អែក |

| | |
|---|---|
| អេមីរ៉ាត អារ៉ាប់រួម<br><br><br><br><br><br><br><br><br><br><br><br><br><br><br><br>អេមីរ៉ាត អារ៉ាប់រួម | យ៉ាងខ្លាំងលើអាវុធទិញពីសហរដ្ឋអាមេរិក ដូចជាប្រព័ន្ធមីស៊ីលស៊េរីចាស់ HAWK, Patriot PAC-3 និងប្រព័ន្ធមីស៊ីល THAAD ដែលត្រូវបានប្រើប្រាស់ជាលើកដំបូង ដើម្បីកម្ទេចមីស៊ីលរបស់ក្រុមហ៊ូទី នៅក្នុងឆ្នាំ២០២២នេះ។ ប្រព័ន្ធមីស៊ីលទាំងនេះ ត្រូវបានដំឡើងនៅតាមតំបន់យុទ្ធសាស្ត្រសំខាន់ៗ និងកំពុងការពារអាកាសយានដ្ឋាន, រោងចក្រប្រេង ឧស្ម័ន និងមូលដ្ឋានយោធា នៅអេមីរ៉ាតអារ៉ាប់រួម។ ប៉ុន្តែទោះប្រព័ន្ធមីស៊ីលទាំងនេះ មានសមត្ថភាពខ្ពស់ក៏ដោយ ប៉ុន្តែវាមិនអាចទប់ស្កាត់ការវាយប្រហារពីក្រុមឧទ្ទាមហ៊ូទីបានទាំងស្រុងនោះទេ។ ជាក់ស្តែងការវាយប្រហារកាលពីខែមករាកន្លងទៅ បានផ្តាច់ជីវិតមនុស្ស ៣នាក់ និងបង្កការខូចខាតដល់អាកាសយានដ្ឋាន និងឃ្លាំងស្តុកប្រេងមួយ ក្នុងទីក្រុងអាប៊ូដាប៊ី (Abu Dhabi)។ នេះបង្ហាញថាអេមីរ៉ាត់អារ៉ាប់រួម មិនអាចពឹងផ្អែកតែទៅលើប្រព័ន្ធមីស៊ីលអាមេរិកនោះទេ ដូច្នេះតើប្រទេសអារ៉ាប់មួយនេះបានទិញប្រព័ន្ធមីស៊ីលអ្វីខ្លះ និងមានមូលហេតុអ្វី?<br>***មីស៊ីលកូរ៉េខាងត្បូង**<br>អេមីរ៉ាតអារ៉ាប់រួមបានជ្រើសរើសកូរ៉េខាងត្បូង និងអ៊ីស្រាអែល សម្រាប់ការផ្គត់ផ្គង់ប្រព័ន្ធមីស៊ីល ដើម្បីបំពេញភាពខ្វះខាត និងបង្កើនសមត្ថភាពបន្ថែម លើប្រព័ន្ធមីស៊ីលដែលមានស្រាប់ដូចជា Patriot ជាដើម។ កូរ៉េខាងត្បូងបានព្រមព្រៀងលក់ប្រព័ន្ធមីស៊ីល Cheongung 2 និងប្រព័ន្ធរ៉ាដា មានតម្លៃ ៣.៥ពាន់លានដុល្លារ ឱ្យអេមីរ៉ាតអារ៉ាប់រួម ហើយកិច្ចព្រមព្រៀងនេះក៏មានរាប់បញ្ចូលផងដែរ នូវកិច្ចសន្យាបង្កើនកិច្ចសហប្រតិបត្តិការឱ្យកាន់តែជិតស្និទ្ធរវាងប្រទេសទាំង២ ក្នុងការអភិវឌ្ឍមីស៊ីល។ Cheongung 2 មានសមត្ថភាពប្រហាក់ប្រហែលនឹងមីស៊ីល S-400 របស់រុស្ស៊ី និងអាចកម្ទេចគោលដៅច្រើនក្នុងពេលតែមួយ នៅរយៈចម្ងាយ ៤០គីឡូម៉ែត្រ។<br>***អាវុធពីអ៊ីស្រាអែល**<br>អេមីរ៉ាតអារ៉ាប់រួម បានឈានដល់កិច្ចពិភាក្សាជាមួយអ៊ីស្រាអែល ដើម្បីទិញប្រព័ន្ធមីស៊ីលប៉ារ៉ាក់៨ (Barak 8) ឬ ស្ប៉ៃដ័រ (Spyder)។ ឥណ្ឌា និងអាស៊ែបៃហ្សង់ ក៏បានទិញប្រព័ន្ធមីស៊ីល Barak 8 នេះដែរ ហើយអាស៊ែបៃហ្សង់ត្រូវបានគេរាយការណ៍ថា បានប្រើប្រាស់ប្រព័ន្ធមីស៊ីលនេះ ដើម្បីបាញ់ទម្លាក់មីស៊ីល Iskander របស់អាមេនី នៅក្នុងសង្គ្រាមកាលពីឆ្នាំ២០២០ រវាងប្រទេសទាំង២។<br>***អាវុធក្នុងស្រុក**<br>ក្រៅតែពីបញ្ហាទិញអាវុធពីក្រៅស្រុក, អេមីរ៉ាតអារ៉ាប់រួម ក៏កំពុងអភិវឌ្ឍឧស្សាហកម្មអាវុធនៅក្នុងស្រុកផងដែរ តាមរយៈការចំណាយប្រាក់រាប់ពាន់លានដុល្លារក្នុងការសិក្សាស្រាវជ្រាវ។ កាលពីឆ្នាំ២០២១, ហាល់ខុន (Halcon) ជាក្រុមហ៊ុនផ្គត់ផ្គង់អាវុធមានមូលដ្ឋានក្នុងទីក្រុងអាប៊ូដាប៊ី (Abu Dhabi) បានបញ្ចេញអាវុធស៊េរីថ្មី SkyKnight ដែលជាប្រព័ន្ធមីស៊ីលការពារដែនអាកាសត្រូវបានរចនាឡើង ដើម្បីកម្ទេចឧទ្ធម្ភាគចក្រ, យន្តហោះដ្រូន និងគ្រាប់រ៉ុក្កែត។ លើសពីនេះទៅទៀត អេមីរ៉ាតអារ៉ាប់រួមមិនមែនកំពុងបង្កើនសមត្ថភាពប្រព័ន្ធមីស៊ីលការពារដែនអាកាសតែមួយមុខនោះទេ ពោលគឺរដ្ឋអារ៉ាប់មួយនេះ ក៏បានបញ្ជាទិញយន្តហោះចម្បាំងពីបារាំងដែរ។ កាលពីខែធ្នូ ឆ្នាំ២០២១ អេមីរ៉ាតអារ៉ាប់រួមបានប្រកាសពីការបញ្ជាទិញយន្តហោះចម្បាំង Rafale ចំនួន ៨០គ្រឿង ពីប្រទេសបារាំងក្នុងតម្លៃ ១៨ពាន់លានដុល្លារ។ បើតាមវិទ្យាស្ថានអន្តរជាតិសម្រាប់ការសិក្សាយុទ្ធសាស្ត្រ IISS, សព្វថ្ងៃអេមីរ៉ាត់អារ៉ាប់រួមមានយន្តហោះចម្បាំង ១៥៦គ្រឿង ហើយការ |

| | |
|---|---|
| | ទិញយន្តហោះ Rafale ៨០គ្រឿងពីបារាំង ត្រូវបានគេរំពឹងថា នឹងកាន់តែពង្រឹងសមត្ថភាពយោធាអេមីរ៉ាត អារ៉ាប់រួម ក្នុងការទប់ស្កាត់ការវាយប្រហារពីសត្រូវ និងធ្វើអន្តរាគមន៍យោធានៅក្នុងតំបន់៕<br>*Fresh News, ថ្ងៃព្រហស្បតិ៍ ទី១០-០២-២០២២* |
| **អាមេរិក** | **លោក McConnell ច្រានចោលគណៈកម្មាធិការបក្សសាធារណរដ្ឋ ដែលជំទាស់តំណាងរាស្ត្របក្ស ចំពោះការចូលរួមការស៊ើបអង្កេត ពីកុបកម្មកាពីតូល**<br>វ៉ាស៊ីនតោន៖ ព្រឹទ្ធសមាជិក លោក Mithch McConnell មេដឹកនាំក្រុមភាគតិចកាលពីថ្ងៃអង្គារ និយាយប្រឆាំងនឹងគណៈកម្មាធិការជាតិនៃគណបក្សសាធារណរដ្ឋ (RNC) សម្រាប់ការបោះឆ្នោតជំទាស់តំណាងរាស្ត្របក្ស លោកស្រី Liz Cheney និងលោក Adam Kinzinger ជុំវិញការចូលរួមរបស់អ្នកទាំង២ ក្នុងការស៊ើបអង្កេតសភាពីការវាយប្រហារនៅវិមានកាពីតូលថ្ងៃទី៦ មករា។<br>មេដឹកនាំក្រុមភាគតិចនៃបក្សសាធារណរដ្ឋរូបនេះ ក៏ច្រានចោលដាច់អហង្ការជុំវិញការលើកឡើងរបស់គណៈកម្មាធិការដដែល ដែលថាការស៊ើបអង្កេតរបស់សភាជា «ការធ្វើទុក្ខបុកម្នេញពលរដ្ឋសាមញ្ញក្នុងការចូលរួមធ្វើសកម្មភាពនយោបាយដោយស្របច្បាប់» ដោយនិយាយថា កុបកម្មគឺជាការបះបោរដោយហិង្សា។ លោក McConnell និយាយថា៖ «យើងបានឃើញវាកើតឡើង។ វាគឺជាការបះបោរយ៉ាងហិង្សាក្នុងគោលបំណងព្យាយាមទប់ស្កាត់ការផ្ទេរអំណាចដោយសន្តិវិធី បន្ទាប់ពីការបោះឆ្នោត ដែលមានការបញ្ជាក់ត្រឹមត្រូវពីរដ្ឋបាល១ទៅរដ្ឋបាល១»។<br>ការអត្ថាធិប្បាយរបស់ លោក McConnell គឺជាការស្តីបន្ទោសដល់គណបក្សសាធារណរដ្ឋ ដែលបដិសេធពីអំពើហិង្សាដែលកើតឡើង នៅវិមានកាពីតូលមុនការឡើងកាន់អំណាចរបស់លោកប្រធានាធិបតី ចូ បៃដិន (Joe Biden) ដែលធ្វើឱ្យមនុស្សយ៉ាងហោចណាស់១៥០នាក់រងរបួស ៥នាក់ស្លាប់ និងជិត៧៥០រងការចោតប្រកាន់ពីបទឧក្រិដ្ឋ។ ការអនុម័តការសម្រេចចិត្តជំទាស់ លោកស្រី Cheney តំណាងរាស្ត្ររដ្ឋ Wyoming និងលោក Kinzinger តំណាងរាស្ត្រនៅរដ្ឋ Illinois របស់ RNC ក្នុងកិច្ចប្រជុំកាលពីថ្ងៃសុក្រសប្តាហ៍មុន ក៏ធ្វើឱ្យសមាជិកគណបក្សសាធារណរដ្ឋមួយចំនួនតូច រិះគន់ការផ្លាស់ប្តូរនេះថាជាការរំខានផ្នែកនយោបាយ និងនាំភាពអាម៉ាស់ដល់គណបក្ស។ សេចក្តីសម្រេចនោះចែងថា RNC នឹង «លែងគាំទ្រពួកគេក្នុងនាមជាសមាជិកនៃគណបក្សសាធារណរដ្ឋទៀតហើយ»។<br>ប្រតិកម្មទៅលើការសម្រេចចិត្ត លោក McConnell និយាយថា៖ «តាមប្រពៃណីទស្សនៈរបស់គណៈកម្មាធិការជាតិ គឺគាំទ្រសមាជិកគណបក្សរបស់យើងទាំងអស់ ដោយមិនគិតពីតួនាទីរបស់ពួកគេលើបញ្ហាមួយចំនួនឡើយ។ ប៉ុន្តែបញ្ហាគឺថាតើ RNC គួរតែដកសមាជិកនៃគណបក្សដែលមានមតិខុសពីរភាគច្រើនរបស់យើងឬអត់នោះមិនមែនជាការងាររបស់ RNC ទេ។ ផ្ទុយពីព្រឹទ្ធសមាជិក McConnel តំណាងរាស្ត្ររដ្ឋកាលីហ្វ័រញ៉ា លោក Kevin McCarthy ដែលជាមេដឹកនាំក្រុមភាគតិច ១រូប គាំទ្រសេចក្តីសម្រេចចិត្តរបស់បក្សដោយប្រាប់អ្នកយកព័ត៌មាន CNN ថាទង្វើនោះធ្វើឡើងដើម្បីថ្កោលទោស ការកំណត់គោលដៅរបស់គណៈកម្មាធិការសភាលើពួកអភិរក្សនិយម ដែលមិនមានវត្តមានក្នុងកុបកម្មថ្ងៃទី៦មករា ឆ្នាំ២០២១ |

| | |
|---|---|
| អាមេរិក | ហើយមិនមានជាប់ពាក់ព័ន្ធអ្វីទាំងអស់ មិនថាការវាយប្រហារ ឬកិច្ចខិតខំ ដើម្បីបដិសេធការបោះឆ្នោតឆ្នាំ២០២០។ ការជំទាស់ដោយជំរុញដោយសម្ព័ន្ធមិត្តរបបឯកបក្ស លោកប្រធានាធិបតី ដូណាល់ត្រាំ (Dolnald Trum) មានកម្រាស់ជាង ១ទំព័រ ប៉ុន្តែវាបានធ្វើឲ្យគណបក្សសាធារណរដ្ឋមានភាពចលាចល រួមទាំងការបង្ហាញពីភាពប្រេះស្រាំផ្ទៃក្នុងរបស់គណបក្ស ការជំទាស់នេះ ក៏បង្អាក់កិច្ចខិតខំប្រឹងប្រែងដោយសមាជិកសភាមកពីគណបក្សសាធារណរដ្ឋ ឲ្យបែរពីការនិយាយកុបកម្មនៅវិមានកាពីតូល ទៅផ្តោតលើអ្វីដែលពួកគេមើលឃើញថា ជាការបរាជ័យរបស់ លោក បៃដិន នឹងគណបក្សប្រជាធិបតេយ្យវិញ។<br>តំណាងរាស្ត្រនៃរដ្ឋញូវយ៉ក ១រូប គឺលោកស្រី Ellie Stefanik និយាយថា អ្នកសាធារណរដ្ឋមានភាពច្បាស់លាស់ យើងថ្កោលទោសអំពើហិង្សានៅថ្ងៃទី៦ ខែមករា យើងក៏ថ្កោលទោសអំពើហិង្សាក្នុងឆ្នាំ២០២០ផងដែរ ដោយសារឧក្រិដ្ឋជនហិង្សាបានវាយប្រហារអគារសម្ព័ន្ធ រួមទាំងផ្នែកខ្លះនៃរដ្ឋធានីវ៉ាស៊ីនតោនឌីស៊ី។ លោកស្រីនិយាយបែបនេះ ដោយសំដៅលើអំពើហិង្សារបស់បក្សសាធារណរដ្ឋ ដែលអង្កេតពីកុបកម្មកាពីតូលដែលកើតឡើងក្នុងបាតុកម្ម ទាមទារឱ្យបញ្ឈប់ការរើសអើងពូជសាសន៍ ពណ៌សម្បុរ ដែលធ្វើឡើងបន្ទាប់ពីការស្លាប់របស់ លោក George Floyd ដោយបន្ថែមថា យើងជឿថាគណៈកម្មការថ្ងៃទី៦ ខែមករា គឺជាល្ខែននយោបាយអំពីការដាក់ទណ្ឌកម្មលើក្រុមប្រឆាំង។ សមាជិកគណបក្សសាធារណរដ្ឋមួយចំនួន ការពារសេចក្តីសម្រេចចិត្តចំពោះ លោកស្រី Cheney និងលោក Kinzinger ដោយកត់សម្គាល់ថាវាបង្កប់នូវទស្សនៈរបស់គណបក្ស អំពីអ្វីដែលកើតឡើងនៅថ្ងៃទី៦ ខែមករា។ លោក Josh Hawley សមាជិកព្រឹទ្ធសភាមកពីរដ្ឋ Missouri នៃបក្សសាធារណរដ្ឋនិយាយថា ការបោះឆ្នោត RNC ឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកបោះឆ្នោតភាគច្រើននៃគណបក្សសាធារណរដ្ឋ។ យ៉ាងណាមិញព្រឹទ្ធសមាជិក Mitt Romney មកពីគណបក្សសាធារណរដ្ឋនៃរដ្ឋ Utah ដែលចាត់ទុកការសម្រេចចិត្តថា ជាការអាម៉ាស់កាលពីថ្ងៃសុក្រមុនការបោះឆ្នោតរបស់គណបក្ស បាននិយាយថា អ្វីដែលគណបក្សខ្ញុំធ្វើដូចការល្ងីល្ងើនោះ មិនអាចជួយយើងបាននោះទេ។ សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិនៃគណបក្សសាធារណរដ្ឋ ដំបូងឡើយចាប់ផ្តើមជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបណ្តេញ លោកស្រី Cheney Saint Kinzinger ដែលធ្លាប់បោះឆ្នោតឱ្យទម្លាក់ លោក ត្រាំ ចេញពីដំណែងចេញពីសន្និសីទសភានៃបក្សសាធារណរដ្ឋ។ ប៉ុន្តែសមាជិកគណៈកម្មាធិការ សម្រេចចិត្តប្រឆាំងនឹងការអំពាវនាវឱ្យមានចំណាត់ការបែបនេះ ហើយជំនួសមកវិញដោយជាការជំទាស់។<br>សេចក្តីព្រាងដំបូងថ្កោលទោសតំណាងរាស្ត្រទាំង២ ចំពោះការចូលរួមក្នុងការធ្វើទុក្ខបុកម្នេញដឹកនាំដោយគណបក្សប្រជាធិបតេយ្យ លើប្រជាពលរដ្ឋសាមញ្ញ ដែលចូលរួមក្នុងសកម្មភាពនយោបាយអហិង្សា និងផ្លូវច្បាប់។ ប៉ុន្តែចុងក្រោយពាក្យអហិង្សា និងផ្លូវច្បាប់ ត្រូវបានដកចេញវិញ ហើយជំនួសដោយស្របច្បាប់។ នេះបើតាមការចុះផ្សាយរបស់កាសែតញូវយ៉កថាមស៍ ដែលស្រង់សម្តីជាអនាមិកពីប្រភពដែលដឹងពីព័ត៌មាននេះច្បាស់។ សមាជិកមួយចំនួននៃគណៈកម្មាធិការអះអាងថាពាក្យ «ពលរដ្ឋសាមញ្ញ" និងការចូលរួមធ្វើនយោបាយដោយស្របច្បាប់» សំដៅទៅលើមនុស្សមួយចំនួនដូចជា អ្នកស្រី Kathy Berden សមាជិកគណៈកម្មាធិការមកពីរដ្ឋ Michigan ដែលចុះហត្ថលេខាលើវិញ្ញាបនបត្រខុសច្បាប់អះអាងថា លោក ត្រាំ ឈ្នះឆ្នោត។ |

| | |
|---|---|
| **អាមេរិក** | សមាជិកគណៈកម្មាធិការជាតិដដែលគិតថា លោកស្រី Berden ជាជនរងគ្រោះស្លូតត្រង់នៃការស៊ើបអង្កេតប្រកបដោយភាពហួសចិត្តមួយ ដោយកត់សម្គាល់ថា លោកស្រីមានវ័យចំណាស់ និងជាស្ត្រីមេម៉ាយ។ យ៉ាងណាមិញ លោកស្រីត្រូវបានគណៈកម្មាធិការស៊ើបអង្កេតការវាយប្រហារវិមានកាពីតូលចេញដីកាកោះហៅ កាលពីខែមករានេះ ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីស្វែងរកថា អ្នកណាជាអ្នករៀបចំការជំរុញផែនការដែលជាឧក្រិដ្ឋកម្មនេះ៕<br>*ភ្នំពេញប៉ុស្តិ៍ ថ្ងៃសុក្រ ទី១១ ខែកុម្ភៈ ឆ្នាំ២០២២* |